**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# សន្តិកម្មតាមច្បាប់

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ថូ វិសាល**

**ចេង អង្គារនួន**

សាស្ត្រាចារ្យណែនាំ

លោកជំទាវ **ម៉ឹយ ធីតា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទនិស្សិត **ថូ វិសាល** និង **ចេង អង្គារឆ្នួង** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២១ ក្រុម L4A6 ក្នុងឆ្នាំសិក្សា ២០២០-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។

**យើងខ្ញុំសូមក្រាបប្រណិប័តន៍ និងសម្តែងនូវកតញ្ញូតាធម៌ កតវេទី យ៉ាងជ្រាលជ្រៅចំពោះ៖**

- អ្នកមានគុណរបស់ពួកខ្ញុំទាំងពីររូប ដែលលោកពិតជាមានគុណយ៉ាងធំធេងដល់រូបយើងខ្ញុំ លោកបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា ទូន្មានប្រៀនប្រដៅ និងព្យាយាមអស់ពីកម្លាំងកាយចិត្តតស៊ូ មិនខ្លាចហត់នឿយក្តៅរងា។ លោកពិតជាបានជួបនូវការលំបាកជាច្រើន ទម្រាំចិញ្ចឹមបីបាច់ថែរក្សាកូនមកដល់ពេលនេះ កូនសូមសន្យាថានឹងធ្វើជាមនុស្សល្អ ពលរដ្ឋល្អនៅក្នុងសង្គម និងបន្តអនាគតដ៏ភ្លឺថ្លាមិនឱ្យលោកអស់សង្ឃឹមឡើយ។
- **ឯកឧត្តមសាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង លោក លោកស្រី សាស្ត្រាចារ្យបុគ្គលិក**នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចគ្រប់ជាន់ថ្នាក់ទាំងអស់ ។
- លោកជំទាវ **ម៉ុយ ធីតា** ដែលជាព្រឹទ្ធបុរសរងមហាវិទ្យាល័យនីតិសាស្ត្រ និងជាទីប្រឹក្សាអមក្រសួងយុត្តិធម៌ ព្រមទាំងជាសាស្ត្រចារ្យណែនាំលើប្រធានបទសារណានេះ ដោយលោកជំទាវ បានជួយអប់រំ បង្ហាញទិសដៅ និងលះបង់ពេលវេលាដ៏មានតម្លៃជួយណែនាំក្នុងការសរសេររបាយការណ៍ស្រាវជ្រាវនេះប្រកបដោយជោគជ័យ។ ប្រសិនបើគ្មានលោកជំទាវទេ ប្រធានបទនេះក៏មិនអាចចេញជារូបរាងឡើយ។
- គណៈគ្រប់គ្រង ព្រមទាំងបុគ្គលិកនៃ **បណ្ណាល័យនីតិសាស្ត្រ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានរៀបចំ និងគ្រប់គ្រងសៀវភៅ ព្រមទាំងបង្កភាពងាយស្រួលដល់ការស្រាវជ្រាវរបស់សិស្សនិស្សិតនៃសាកលវិទ្យាល័យទាំងមូល។

ជាចុងក្រោយនេះ យើងខ្ញុំសូមប្រសិទ្ធិពរជ័យដល់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងលោក លោកស្រី សាស្ត្រាចារ្យ**ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចសូមឱ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្ត អស់រយៈពេលបួនឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចរួមមក យើងខ្ញុំពិតជាទទួលបាននូវចំណេះដឹងយ៉ាងច្រើន រួមទាំងតាមរយៈការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យច្បាប់ ជាហេតុធ្វើឱ្យផ្នត់គំនិត និងការពិចារណារបស់ខ្ញុំបាទទាំងពីរមានការអភិវឌ្ឍន៍ និងរីកចម្រើនជាងមុន។ នៅក្នុងវិធានគតិយុត្តនៃនីតិរដ្ឋប្បវេណី យើងខ្ញុំទាំងពីរនាក់បានចាប់អារម្មណ៍លើផ្នែកសន្តតិកម្មដែលមានចែងនៅក្នុងគន្ថីទី ៨ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។ ដោយឃើញថាស្ថានភាពនៃការបែងចែកទ្រព្យសម្បត្តិនៅកម្ពុជាគឺមានភាពស្មុគស្មាញ ដែលជាហេតុនាំឱ្យយើងខ្ញុំទាំងពីរនាក់មានឱកាស និងទទួលបានសិទ្ធិក្នុងការសរសេរ និងចងក្រងសារណាបញ្ចប់ការសិក្សា ដែលទាក់ទងទៅនិងប្រធានបទ "**សន្តតិកម្មតាមច្បាប់**" នេះឡើង ក្នុងគោលបំណង ដើម្បីបំពេញក្រេឌីតនៃកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្របញ្ចប់ការសិក្សានីតិសាស្រ្តផង និងដើម្បីបំពេញបន្ថែមនូវតម្រូវការស្រាវជ្រាវចំពោះនិស្សិតជំនាន់ក្រោយៗទៀត ក៏ដូចជាទុកជាឯកសារសម្រាប់ជាចំណេះដឹងដល់ប្រជាពលរដ្ឋទូទៅផងដែរ។ ទោះបីជាការស្រាវជ្រាវទាក់ទងនឹងប្រធានបទ សន្តតិកម្ម ខាងលើនេះ មិនអាចចាត់ទុកជាស្នាដៃល្អឥតខ្ចោះក៏ពិតមែន ក៏ប៉ុន្តែស្នាដៃនេះក៏ជាបច្ច័យដល់ការយល់ដឹង និងការវាយតម្លៃអំពីចំណេះដឹងយើងខ្ញុំទាំងពីរនាក់ដែលបានចំណាយពេលសិក្សារយៈពេលបួនឆ្នាំកន្លងមក។

ជាចុងបញ្ចប់យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការសិក្សាស្រាវជ្រាវខាងលើនេះអាចចូលរួមចំណែកនៅក្នុងការពង្រីកចំណេះដឹងដល់អ្នកដែលមានបំណងនៅក្នុងការសិក្សាស្វែងយល់បន្ថែម។ ទោះបីជាយ៉ាងណាក៏ដោយកិច្ចការស្រាវជ្រាវនេះប្រាដកជាមានកំហុសឆ្គង ឬ មានចំណុចខ្វះខាតត្រង់កន្លែងណាមួយជាក់ជាមិនខាន ក្នុងការតាក់តែងអត្ថបទនេះឡើង ដែលតម្រូវឱ្យមានការរិះគន់ចាំបាច់នៅក្នុងន័យស្ថាបនា ពីសំណាក់ លោកគ្រូ អ្នកគ្រូសាស្រ្តាចារ្យ និងសិស្សនិស្សិតដែលសិក្សាស្រាវជ្រាវបន្តដើម្បីធ្វើការកែតម្រូវនូវចំណុចខ្វះខាតទាំងអស់។ យើងខ្ញុំសូមអភ័យទោសនូវរាល់កំហុសឆ្គងពាក្យពេចន៍អក្ខរាវិរុទ្ធមួយចំនួន ឬ រាល់ចំណុចខ្វះខាតទាំងឡាយណាដែលកើតមានឡើងដោយចេតនាក្តី និង អចេតនាក្តី។ យើងខ្ញុំរង់ចាំទទួលនូវការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យអត្ថបទនេះកាន់តែល្អប្រសើរឡើង។ យើងខ្ញុំក៏សូមធានាថាសារណាដែលបានសរសេរឡើងនេះ គឺពុំបានចម្លងពីស្នាដៃរបស់បុគ្គលណាមួយឡើយ។

# មាតិកា

* * * * * *

**ទំព័រ**

**សេចក្តីផ្តើម** ........................................................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់**

**១.១. បទដ្ឋានគតិយុត្តពាក់ព័ន្ធ** ........................................................ ៤

១.១.១. រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ........................................................ ៤

១.១.២. ច្បាប់ភូមិបាល ឆ្នាំ២០០១ ........................................................ ៥

១.១.៣. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ........................................................ ៥

**១.២. សញ្ញាណគតិយុត្តនៃសន្តតិកម្ម** ........................................................ ៦

**១.៣. លក្ខណៈសម្បត្តិនៃសន្តតិជន** ........................................................ ៨

១.៣.១. ជនមានជីវិតពេលចាប់ផ្តើមសន្តតិកម្ម ........................................................ ៨

ក. រូបវន្តបុគ្គល ........................................................ ៨

ខ. ជនបរទេស ........................................................ ៩

១.៣.២. មិនមែនជាអភ័ព្វបុគ្គល ........................................................ ១០

១.៣.៣. មិនមែនជាជនដែលត្រូវបានផ្តាច់ចេញពីមត៌ក ........................................................ ១១

១.៣.៤. ទារកក្នុងគភ៌ ........................................................ ១១

**១.៤. ការចាប់ផ្តើមសន្តតិកម្ម** ........................................................ ១១

១.៤.១. ពេលវេលាបើកសន្តតិកម្ម ........................................................ ១២

ក. មរណភាពនៃបុគ្គល ........................................................ ១២

ខ. ករណីបាត់ខ្លួន ........................................................ ១២

១.៤.២. ទីកន្លែងបើកសន្តតិកម្ម ........................................................ ១៣

**១.៥. របបគតិយុត្តនៃការគ្រប់គ្រងមត៌ក** ........................................................ ១៣

១.៥.១. ការគ្រប់គ្រងមត៌ក ........................................................ ១៤

**១.៦. សន្តតិជនដែលច្បាប់បានកំណត់** ........................................................ ១៥

១.៦.១. សន្តតិជនលំដាប់ទី១ ........................................................ ១៥

១.៦.២. សន្តតិជនលំដាប់ទី២ ........ ១៦
១.៦.៣. សន្តតិជនលំដាប់ទី៣ ........ ១៦
១.៦.៤. សន្តតិជនជានិច្ច ........ ១៧
១.៦.៥. សន្តតិជនជំនួស ........ ១៨

## ជំពូកទី២
## នីតិវិធីបែងចែកមត៌កតាមច្បាប់

**២.១. វិធីបែងចែកមត៌ក** ........ ២០
២.១.១. ការពិភាក្សាបែងចែកមត៌ក ........ ២០
២.១.២. មូលដ្ឋាននៃការបែងចែក ........ ២១
២.១.៣. ការសម្រួលរវាងម្ចាស់បំណុល ........ ២២
២.១.៤. ការបែងចែកដោយតុលាការ ........ ២៣
២.១.៥. អានុភាពនៃការបែងចែក ........ ២៤
២.១.៦. ករណីពិសេស ........ ២៥
**២.២.ការយល់ព្រម និងការបោះបង់សន្តតិកម្ម** ........ ២៦
២.២.១. ការយល់ព្រមទទួលសន្តតិកម្ម ........ ២៧
២.២.១.១. ការយល់ព្រមទាំងស្រុង ........ ២៧
២.២.១.២. ការយល់ព្រមមានកម្រិត ........ ២៨
ក. វិធី ........ ២៩
ខ. អានុភាព ........ ២៩
២.២.២. ការបោះបង់សន្តតិកម្ម ........ ២៩
**២.៣. ការបែងចែកមត៌កតាមលំដាប់សន្តតិជន** ........ ៣០
២.៣.១. ករណីមានសន្តតិជនប៉ុន្តែគ្មានសន្តតិជនជានិច្ច ........ ៣០
ក. សន្តតិជនលំដាប់ទី១ ........ ៣០
ខ. សន្តតិជនលំដាប់ទី២ ........ ៣២
គ. សន្តតិជនលំដាប់ទី៣ ........ ៣៣
២.៣.២. ករណីមានសន្តតិជន និងសន្តតិជនជានិច្ច ........ ៣៤

ក. សហព័ន្ធ និងសន្តតិជនលំដាប់ទី១ ........ ៣៤
ខ. សហព័ន្ធ និងសន្តតិជនលំដាប់ទី២ ........ ៣៦
គ. សហព័ន្ធ និងសន្តតិជនលំដាប់ទី៣ ........ ៣៧
**២.៤. ការសម្រួលចំណែកមត៌ក** ........ ៣៨
២.៤.១. ផលប្រយោជន៏ពិសេស ........ ៣៩
ក. ផលប្រយោជន៏ពិសេសមានតម្លៃតិចជាងចំណែកមត៌ក ........ ៣៩
ខ. ផលប្រយោជន៏ពិសេសមានតម្លៃស្មើនឹងចំណែកមត៌ក ........ ៤០
គ. ផលប្រយោជន៏ពិសេសមានតម្លៃលើសពីចំណែកមត៌ក ........ ៤០
២.៤.២. ភាគនៃវិភាគទាន ........ ៤២
២.៤.៣. ប្រទានកម្ម ........ ៤៤
**២.៥. ស្ថានភាពពិសេស** ........ ៤៥
២.៥.១. នត្ថិភាពនៃសន្តតិជន ........ ៤៦
ក. នីតិបុគ្គលមត៌ក ........ ៤៦
ខ. ចំណែកចំពោះជនដែលមាននិស្ស័យពិសេស ........ ៤៧
គ. មត៌កដែលក្លាយជារបស់រដ្ឋ ........ ៤៧
២.៥.២. ការធ្វើបដិទាននៃសន្តតិកម្ម ........ ៤៨
**សេចក្តីសន្និដ្ឋាន** ........ ៥០
**អនុសាសន៍** ........ ៥២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ក្រោយពីផ្លាស់ប្តូររបបដឹកនាំជាច្រើនសម័យកាល និងឆ្លងកាត់នូវភ្លើងសង្គ្រាមជាច្រើនទសវត្សរ៍ កន្លងមក ធ្វើឱ្យប្រទេសកម្ពុជាទទួលរងនូវការបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងលើគ្រប់វិស័យ។ ក្រោយពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅ ឆ្នាំ១៩៩១ ប្រទេសកម្ពុជាបានបង្កើតរបបថ្មីមួយគឺរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញតាមរយៈការបោះឆ្នោតនៅឆ្នាំ១៩៩៣។ ទោះបីយ៉ាងនេះក្តី ក៏យើងពុំទាន់ទទួលបានពេញលេញនូវសុខសន្តិភាពនៅឡើយរហូតដល់ឆ្នាំ១៩៩៨ ទើបកម្ពុជាទទួលបាននូវសន្តិភាពទូទាំងប្រទេសពេញលេញ។

ដើម្បីដើរឱ្យទាន់នូវសម័យទំនើបនេះ កម្ពុជាបានធ្វើទំនើបកម្មច្បាប់ជាច្រើនផ្សេងៗគ្នា ក្នុងគោលបំណងឱ្យមានភាពសមស្របទៅតាមតថភាពសង្គមបច្ចុប្បន្ន។ នៅក្នុងឆ្នាំ១៩៩៣ កម្ពុជាបានបង្កើតរដ្ឋធម្មនុញ្ញមួយដែល ហៅថា រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ដោយរដ្ឋធម្មនុញ្ញខ្លួនឯងជាអ្នកចែងថា ច្បាប់ ឬ បទដ្ឋានគតិយុត្តទាំងអស់នៅពេលដែលបង្កើតឡើងត្រូវគោរពតាមបទបញ្ញត្តិដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ក្រោយមក យើងឃើញមានការតាក់តែង ចងក្រងច្បាប់សំខាន់ៗជាច្រើនដូចជាច្បាប់ភូមិបាល ឆ្នាំ២០០១ ក្រមទាំងបួនរួមមាន ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ និងក្រមនិតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ជាដើម។ ក្រមព្រហ្មទណ្ឌ គឺចែងទាក់ទងទៅនឹងការការពារសណ្តាប់ធ្នាប់សង្គម ពោលគឺទាក់ទងទៅនឹងទំនាក់ទំនងសាធារណៈដែលហៅថា នីតិសាធារណៈ។ ចំណែកឯក្រមរដ្ឋប្បវេណី គឺចែងអំពីទ្រព្យសម្បត្តិ និងទំនាក់ទំនងញាតិ ពោលគឺគ្របដណ្តប់ទៅដល់ជីវភាព និងជីវិតបុគ្គលឯកជន ដែលហៅថា នីតិឯកជន[1]។ ទោះបីជាចែងខុសគ្នាទៅលើផ្នែកទំនាក់ទំនងសាធារណៈ និងឯកជនក៏ដោយ ក៏នូវមានចំណុចរួមតែមួយផងដែរ ដោយក្រមទាំងពីរនេះគឺនៅតែគោរពបទប្បញ្ញត្តិដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដោយមិនអាចចែងផ្ទុយបាន។ នៅក្នុង ជំពូកទី ៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងអំពីសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ដែលមានសិទ្ធិស្មើគ្នាមិនថាក្មេង ចាស់ ប្រុស ស្រី និងទទួលស្គាល់ទៅលើកម្មសិទ្ធិឯកជនទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ដែលមានសិទ្ធិក្នុងការចាត់ចែង ប្រើប្រាស់ និងអាស្រ័យផលលើទ្រព្យរបស់ខ្លួន នៅពេលដែលបុគ្គលនោះនៅមានជីវិត ដែលស្ថិតនៅក្នុងកម្រិតដែលច្បាប់ចែង ទោះបីជាទទួលមរណភាព ក៏ទ្រព្យសម្បត្តិទាំងនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ច្បាប់ផងដែរ។ ការចាត់ចែងទ្រព្យសម្បត្តិពីបុគ្គលដែលទទួលមរណភាព (មតកជន) ទៅបុគ្គលដែលមាន

[1] មាត្រា១ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

សិទ្ធិទទួលបាននូវទ្រព្យសម្បត្តិ (សន្តតិជន) ដែលនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ហៅរបបនៃការចាត់ចែងទ្រព្យសម្បត្តិបែបនេះថា "**សន្តតិកម្ម**"។

របបគតិយុត្តសន្តតិកម្ម មិនមែនទើបតែមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ នោះទេ ប៉ុន្តែរបបនេះគឺមានចែងតាំងពីក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ មកម្ល៉េះ ដោយការផ្ទេរនូវមត៌កពីអ្នកជំនាន់មុនទៅកាន់អ្នកជំនាន់ក្រោយ ដូចជាពីឪពុកម្តាយទៅ កូន ចៅ ជំនាន់ក្រោយ នៅក្នុងពូជពង្សវង្សត្រកូល ដើម្បីបន្តគ្រប់គ្រងទ្រព្យសម្បត្តិ ក៏ដូចជាបន្តនូវវង្សត្រកូលបន្ទាប់ពីអ្នកជំនាន់មុនៗ។ ទំលាប់បែបនេះបានបន្តរហូតមកដល់ពេលបច្ចុប្បន្ន ហើយក៏មានការតាក់តែងចេញជាច្បាប់ ដែលស្ថិតនៅក្នុង ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាត្រង់ គន្ថីទី ៨ ដែលចែងអំពី សន្តតិកម្ម។

របបសន្តតិកម្មនៅក្នុងពិភពលោកនេះ បែងចែកជា ២ ប្រភេទ គឺ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ និងគោលការណ៍ជម្រះបញ្ជី។[2] គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ គឺជាគោលការណ៍ដែលសន្តតិជនត្រូវទទួលទាំងស្រុងនូវសិទ្ធិ និងករណីយកិច្ចទាំងអស់របស់មតកជន។ ដូច្នេះ សន្តតិជនបានទទួលបន្តនូវឋានៈរបស់មតកជនតែម្តង។ ក្នុងករណីដែលមតកជននោះបានបន្សល់ទុកកាតព្វកិច្ចច្រើនពេក (ទ្រព្យអកម្ម) ប្រសិនបើសន្តតិជនទទួលបន្តនូវកាតព្វកិច្ចទាំងនោះ នឹងធ្វើឱ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរដោយសារសន្តតិកម្ម។ ដូច្នេះហើយបានជាយើងបង្កើតឱ្យមានរបបបោះបង់នូវសន្តតិកម្ម ឬ ការយល់ព្រមដោយមានកម្រិត ដើម្បីជៀសវាងនូវស្ថានភាពនេះ។ លើសពីនេះទៅទៀត មានស្ថានភាពមួយចំនួនដែលមានសហសន្តតិជន និងមានជនដែលបានទទួលទ្រព្យដោយប្រទានកម្ម ជាអាទិ៍ នៅពេលដែលមតកជននៅរស់ ដើម្បីធ្វើឱ្យមានសមភាពជាក់ស្តែងទាមទារឱ្យមានមធ្យោបាយសម្រួលចំណែកមត៌ក ដែលគាំទ្រដោយច្បាប់។ គោលការណ៍ជម្រះបញ្ជី គឺត្រូវជម្រះបញ្ជីទាំងអស់នូវសិទ្ធិលើបំណុល និងកាតព្វកិច្ចរបស់មតកជន ពេលដែលសន្តតិកម្មកើតមានឡើង ហើយសន្តតិជននឹងស្នងទ្រព្យនោះតែក្នុងករណីដែលមានទ្រព្យសកម្មប៉ុណ្ណោះ ហើយក្នុងករណីដែលមានកាតព្វកិច្ចធ្ងន់ធ្ងរហួសហេតុ ត្រូវប្រកាសក្ស័យធននៃមត៌កនោះដើម្បីកុំឱ្យសន្តតិជនទទួលនូវបន្ទុកកាតព្វកិច្ចនោះ។ នេះជាគោលការណ៍មួយដែលស្របទៅតាមសមភាពរវាងម្ចាស់បំណុលរបស់មតកជន និងសន្តតិជន ក៏ប៉ុន្តែមានការលំបាកដូចជា នីតិវិធីស្មុគស្មាញ អស់សោហ៊ុយ និងចំណាយពេលវេលាច្រើន។ ហេតុនេះហើយ នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ស្តីពីសន្តតិកម្ម គឺទទួលស្គាល់គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ។[3]

[2] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគទី ៦ ជំពូកទី ៩, ទំព័រ ២៩

[3] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគទី ៦ ជំពូកទី ៩, ទំព័រ ២៩

នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានដាក់របបសន្តតិកម្ម នៅដាច់ដោយឡែក ដោយបានបែងចែកសន្តតិកម្មជា ពីរប្រភេទ គឺ សន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍។ សន្តតិកម្មតាមមតកសាសន៍ គឺជាសន្តតិកម្មដែលធ្វើឡើងដោយផ្អែកទៅតាមឆន្ទៈរបស់មតកជន។ ចំណែកសន្តតិកម្មតាមច្បាប់ គឺជាសន្តតិកម្មដែលបង្កើតឡើងផ្អែកតាមបញ្ញត្តិនៃច្បាប់។ ឃើញថាការយល់ដឹងរបស់ប្រជាពលរដ្ឋកម្ពុជានៅមានកម្រិត ទាក់ទងទៅនឹងការបែងចែកមត៌កដោយសន្តតិកម្ម ទើបក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាត្រង់ គន្ថីទី ៨ បានចែងអំពី សន្តតិកម្ម ដែលមានសារៈសំខាន់នៅក្នុងជីវភាពប្រចាំថ្ងៃ ជាពិសេសសម្រាប់អ្នកច្បាប់ និងសិស្សនិស្សិតច្បាប់ ដែលកំពុងសិក្សាលើមុខជំនាញនីតិសាស្ត្រ។ ការសិក្សាស្រាវជ្រាវនេះគឺក្នុងគោលបំណង ចងក្រងជាឯកសារ ដើម្បីជាជំនួយឱ្យសិស្សនិស្សិតច្បាប់ងាយស្រួលក្នុងការរកឯកសារស្រាវជ្រាវ ដើម្បីពង្រីក និងពង្រឹងលើសមត្ថភាពយល់ដឹងផ្នែកច្បាប់កាន់តែទូលំទូលាយបន្ថែម និងបង្ហាញនូវស្មារតីនៃច្បាប់ទាក់ទងនឹង"**សន្តតិកម្មតាមច្បាប់**"។

ដើម្បីបកស្រាយអំពីប្រធានបទ "**សន្តតិកម្មតាមច្បាប់**" ឱ្យបានក្បោះក្បាយ ស៊ីជម្រៅ និងច្បាស់លាស់ យើងខ្ញុំសូមធ្វើការបែងចែកការសិក្សាស្រាវជ្រាវដូចខាងក្រោម៖

**ជំពូកទី១ សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់**

**ជំពូកទី២ នីតិវិធីបែងចែកមត៌កតាមច្បាប់**

# ជំពូកទី១
# សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់

សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់នេះ យើងនឹងសិក្សាលើទិដ្ឋភាពទូទៅរួម ក្នុងនោះយើងបាន បែកចែកជា ៦ ចំណុច ដើម្បីងាយស្រួលក្នុងការលំអិតលើប្រធានបទ រួមមានចំណុច ១.១ បទដ្ឋានគតិយុត្ត ពាក់ព័ន្ធ ១.២ សញ្ញាណគតិយុត្តនៃសន្តតិកម្ម ១.៣. លក្ខណៈសម្បត្តិនៃសន្តតិជន ១.៤ ការចាប់ផ្តើមសន្តតិកម្ម ១.៥ របបគតិយុត្តនៃការគ្រប់គ្រងមត៌ក និង ១.៦ សន្តតិជនដែលច្បាប់បានកំណត់។ ដូចនេះយើងនឹងពិភាក្សា លំអិតនៅខាងក្រោមៈ

## ១.១. បទដ្ឋានគតិយុត្តពាក់ព័ន្ធ

តាមរយៈការសង្កេតទៅលើបទដ្ឋានគតិយុត្ត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឃើញថា ច្បាប់ និងវិធាន ដែលជាបទដ្ឋានគតិយុត្តមានច្រើន ដែលត្រូវបាននីតិករៀបចំតាក់តែងឡើង ដើម្បីគ្រប់គ្រងលើវិស័យនីមួយៗ។ លើសពីនេះទៅទៀត រាល់បទដ្ឋានគតិយុត្តទាំងនោះ សុទ្ធសឹងតែមានគោលដៅ និងគោលបំណងច្បាស់លាស់ សម្រាប់គាំទ្រទៅតាមវិស័យនានា។ ដោយឡែក ទាក់ទងនឹងប្រធានបទ "**សន្តតិកម្មតាមច្បាប់**" នេះវិញ ឃើញថា មានបទដ្ឋានគតិយុត្តមួយចំនួនដែលបានចូលរួមចំណែកក្នុងការគាំទ្រ និងដោះស្រាយបញ្ហាមួយចំនួន ដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិ និងទំហំញាតិ។ បទដ្ឋានដែលពាក់ព័ន្ធទាំងនោះរួមមាន៖ រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ច្បាប់ភូមិបាល ឆ្នាំ២០០១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១។

ដើម្បីធ្វើការសិក្សាស្វែងយល់ទៅលើប្រធានបទ "**សន្តតិកម្មតាមច្បាប់**" ឱ្យបានស៊ីជម្រៅ យើងគប្បី យល់ដឹងអំពីបទដ្ឋានគតិយុត្តិមួយចំនួនដែលពាក់ព័ន្ធរួមមាន៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ច្បាប់ភូមិបាលឆ្នាំ ២០០១ និងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។

### ១.១.១. រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា។ រាល់ច្បាប់ និងឯកសារគតិយុត្តទាំងឡាយ របស់ព្រះរាជាណាចក្រកម្ពុជាត្រូវអនុលោមទៅតាមរដ្ឋធម្មនុញ្ញ បើពុំនោះសោត ច្បាប់ និងឯកសារគតិយុត្តទាំង នោះនឹងអធម្មនុញ្ញភាព។ ហេតុដែលនាំឱ្យរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ទាក់ទងនឹងប្រធានបទនៃកិច្ចការស្រាវជ្រាវនេះ គឺសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ។ រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សតាម រយៈផ្តល់ឱ្យប្រជាពលរដ្ឋមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយ

មិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ឋានៈសង្គម ឬ ស្ថានភាពឯទៀតឡើយ។[4] លើសពីនេះទៀត រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មានការទទួលស្គាល់សិទ្ធិលើដីធ្លី តាមរយៈជនណាក៏ដោយ ទោះបីជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ ប៉ុន្តែមានតែរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។[5]

**១.១.២. ច្បាប់ភូមិបាល ឆ្នាំ២០០១**

ក្រៅពីរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ដែលជាច្បាប់កំពូលបានបញ្ញត្តទាក់ទងទៅនឹងការគោរពសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ និងការទទួលស្គាល់កម្មសិទ្ធិឯកជនស្របច្បាប់លើដីធ្លី។ ឃើញថា មានបទប្បញ្ញត្តិដោយឡែកមួយទៀត ក៏បានចែងអំពី កម្មសិទ្ធិឯកជនស្របច្បាប់លើដីធ្លី ហើយបទដ្ឋានគតិយុត្តនោះគឺច្បាប់ភូមិបាលឆ្នាំ២០០១។

ច្បាប់ភូមិបាល ឆ្នាំ២០០១ បានបង្កើតឡើង ក្នុងគោលបំណងកំណត់អំពីរបបកម្មសិទ្ធិលើអចលវត្ថុទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងធានាការពារសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលវត្ថុស្របតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជា។[6] ទន្ទឹមនឹងការការពារកម្មសិទ្ធិស្របច្បាប់លើដីធ្លី ច្បាប់ភូមិបាល ឆ្នាំ២០០១ បានផ្តល់សិទ្ធិដល់ជនគ្រប់រូបត្រូវតែគោរពទ្រព្យសម្បត្តិរដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ។ លើសពីនេះទៅទៀត មានតែរូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរទេ ទើបមានសិទ្ធិកម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។[7]

**១.១.៣. ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧**

បទដ្ឋានគតិយុត្តដោយឡែកមួយទៀតដែលទាក់ទងនឹងប្រធានបទនៃកិច្ចការស្រាវជ្រាវនេះ គឺក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ ដើម្បីសម្រេចបាននូវ សិទ្ធិឯកជនរបស់បុគ្គលនីមួយៗ ដែលត្រូវបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបង្កើតឡើងនូវគោលការណ៍មួយចំនួនដូចតទៅ៖

- គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ(ទាក់ទងនឹងបុគ្គល) សំដៅដល់គ្រប់រូបវន្តបុគ្គល មានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច មានន័យថា ក្នុងឋានៈជាមនុស្ស មិនត្រូវមានការរើសអើងវណ្ណៈ ភេទ អាយុ មុខរបរ សាសនាឡើយ។

[4] មាត្រា ៣១ កថាខណ្ឌទី២ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[5] មាត្រា ៤៤ កថាខណ្ឌទី១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[6] មាត្រា ១ នៃច្បាប់ភូមិបាល ឆ្នាំ២០០១

[7] មាត្រា ៨ នៃច្បាប់ភូមិបាល ឆ្នាំ២០០១

- គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន គោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល ទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជន សេរីភាពនៃលក្ខណៈបុគ្គលតាមច្បាប់ សេរីភាពនៃការប្រើប្រាស់ និងអាស្រ័យផល និងចាត់ចែងទ្រព្យ និងសេរីភាពក្នុងការធ្វើកិច្ចសន្យា។
- គោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់ សំដៅដល់ការបង្កើតសិទ្ធិប្រត្យក្សបានតែតាមប្រភេទ និងខ្លឹមសារដែលត្រូវបានទទួលស្គាល់ដោយក្រម និងច្បាប់ពិសេសតែប៉ុណ្ណោះ។ យោងតាមមាត្រា ១៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានឱ្យនិយមន័យ សិទ្ធិប្រត្យក្ស ថាសំដៅទៅលើសិទ្ធិគ្រប់គ្រងលើវត្ថុដោយចំពោះ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន។ ហេតុនេះហើយបានជាក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បង្កើតនូវគោលការណ៍នៃការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្ស ក្នុងគោលបំណងដើម្បីធ្វើការផ្ទេរទ្រព្យសម្បត្តិពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ដោយរួមទាំងការផ្ទេរទ្រព្យសម្បត្តិពីបុគ្គលដែលស្លាប់ទៅបុគ្គលដែលនៅរស់ ដោយហេតុថាមុនពេលស្លាប់បុគ្គលនោះមានទ្រព្យសម្បត្តិ ហើយមានញាតិជាអ្នកស្នងបន្ត ទើបក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ត្រង់គន្ថីទី ៨ បានបញ្ញត្តិអំពី **“សន្តតិកម្ម”** ឡើងមក ដើម្បីការពារឆន្ទៈបុគ្គលដែលបានស្លាប់ និងបុគ្គលដែលស្នងបន្តនូវមត៌ក។ ដោយហេតុថាជាទម្លាប់ការផ្ទេរសិទ្ធិកម្មសិទ្ធិពីបុគ្គលដែលទទួលមរណភាពទៅបុគ្គលដែលនៅរស់ ក្រៅអំពីការសម្ដែងឆន្ទៈតាមរយៈមតកសាសន៍ ច្បាប់បានការពារផលប្រយោជន៍ដល់បុគ្គលទាំងឡាយដែលជាញាតិតាមផ្លូវច្បាប់របស់មតកជន។ ហេតុនេះ គន្ថីទី ៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដើរតួនាទីសំខាន់ក្នុងការកំណត់សន្តតិជនតាមច្បាប់។

### ១.២. សញ្ញាណគតិយុត្តនៃសន្តតិកម្ម

យោងសន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រង់លេខរៀន ១៤៣ បានឱ្យនិយមន័យ និងពន្យល់ពាក្យ **“សន្តតិកម្ម”** ថា ជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬ ច្រើននាក់តាមឆន្ទៈ ឬ តាមច្បាប់។ ដោយឡែកផ្អែកតាមមាត្រា១១៤៥ នៃក្រមដដែលបានចែងថា សន្តតិកម្មដែលផ្អែកតាមឆន្ទៈរបស់ មតកជន (បណ្ដាំខ្មោច) ហៅថា **“សន្តតិកម្មមានបណ្ដាំ”**។ ប្រសិនបើកាលម្ចាស់ទ្រព្យស្លាប់ទៅដោយមិនបានធ្វើបណ្ដាំទេ នោះជាស្វ័យប្រវត្តិត្រូវអនុវត្តច្បាប់ដែលគេហៅថា **“សន្តតិកម្មតាមច្បាប់”**។

ម្យ៉ាងទៀត ចំពោះពាក្យ **“សន្តតិកម្មតាមច្បាប់”** ផ្អែកតាមមាត្រា ១១៤៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តថា គឺជាសន្តតិកម្មទាំងឡាយណាដែលធ្វើឡើងតាមបញ្ញត្តិច្បាប់។ ដោយអាស្រ័យតាមការពន្យល់ពាក្យខាងលើ យើងអាចសន្និដ្ឋានបានថា សន្តតិកម្មតាមច្បាប់ គឺជាការបែងចែកមត៌កទៅឱ្យសន្តតិជនទៅតាមចំណែក និងវិធីដែលបានកំណត់ដោយច្បាប់។ មូលហេតុដែលមត៌កត្រូវបែងចែកតាម

ច្បាប់ គឺមតកជនមិនបានផ្ដែផ្ដាំមុនពេលស្លាប់ ឬ មិនបានបន្សល់ទុកនូវបណ្ដាំមត៌ក ឬ បណ្ដាំមត៌កត្រូវបានលុបចោលដោយបណ្ដាំមត៌កនោះបានធ្វើខុសពីទម្រង់ដែលច្បាប់បានកំណត់ជាដើម។

ដូចនេះយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក្នុងគន្ថីទី៨ ជំពូកទី២ ផ្នែកទី១ ចាប់ពីមាត្រា ១១៥៦ រហូតដល់មាត្រា១១៦៧ គឺជាបទប្បញ្ញត្តិដែលមានចែងអំពី “**សន្តតិកម្មតាមច្បាប់**”។

សន្តតិកម្មតាមច្បាប់ មានមូលហេតុកើតឡើងដូចដែលបានរៀបរាប់ខាងលើ ហើយស្មារតីនៃច្បាប់គឺមានលក្ខណៈដាច់ខាតត្រូវតែអនុវត្តតាម ប៉ុន្តែត្រូវគោរពតាមឆន្ទៈរបស់បុគ្គលឯកជន (សន្តតិជន) ដែលជាអញ្ញត្រកម្មអាចឱ្យសន្តតិជនបង្ហាញឆន្ទៈទទួលយក ឬ បដិសេធមិនទទួលយកនូវទ្រព្យសម្បត្តិដែលជាចំណែកមត៌ករបស់មតកជន ទោះបីផ្នែកណាមួយ ឬ ទាំងអស់នៃចំណែកមតកក៏ដោយ ឬ អាចទាមទារភាគនៃវិភាគទានដែលខ្លួនបានជួយទំនុកបម្រុង បង្កើន ឬ ថែរក្សាផ្នែកសេដ្ឋកិច្ចទៅលើមតកជន។ មូលហេតុដែលច្បាប់បញ្ញត្តបែបនេះគឺដើម្បីរក្សាការពារផលប្រយោជន៍ដល់សន្តតិជន។ ប្រសិនបើសន្តតិជនបង្ហាញឆន្ទៈទទួលយកមត៌ក នោះសន្តតិជនត្រូវទទួលបានទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម (បំណុល)។ ករណីខ្លះចំណែកមត៌កដែលជាទ្រព្យអកម្ម (បំណុល) មានច្រើនជាងទ្រព្យសកម្ម ដែលបណ្ដាលឱ្យប៉ះពាល់ដល់សន្តតិជនក្នុងការស្នងបន្ត។ សន្តតិជននោះមានសិទ្ធិបង្ហាញឆន្ទៈថានឹងយល់ព្រមទទួលយក ឬ មិនទទួលយកមត៌កនោះ។

មុនឈានដល់ការបកស្រាយចំណុចបន្ទាប់ទៀត យើងគួរស្វែងយល់នូវសញ្ញាណគតិយុត្តមួយចំនួនរួមមាន មត៌ក មតកជន ទ្រព្យសម្បត្តិសកល ទ្រព្យសកម្ម និងទ្រព្យអកម្ម ជាមុនសិន។

- មត៌ក គឺជាទ្រព្យសម្បត្តិជាកេរទាំងឡាយ ដែលបុគ្គលម្នាក់(មតកជន) បានបន្សល់ទុកក្រោយពេលស្លាប់[8]។
- មតកជន គឺជាជនដែលបានស្លាប់ទៅហើយ[9]។
- ទ្រព្យសម្បត្តិសកល គឺជាទ្រព្យសម្បត្តិទាំងអស់របស់បុគ្គលណាម្នាក់រួមមានទ្រព្យសកម្ម និងទ្រព្យអកម្ម[10]។

[8] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, លេខ ១១៦ ទំ. ១៧

[9] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, លេខ ១១៧ ទំ. ១៧

[10] ដកស្រង់ចេញពី សទ្ទានុក្រមពាក្យច្បាប់ ខ្មែរអង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ដែលត្រូវបានរៀបចំដោយគណៈកម្មាការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០០៧

- ទ្រព្យសកម្ម គឺជាទ្រព្យសម្បត្តិ ដែលនីតិបុគ្គលមាន[11]។ ទ្រព្យសកម្ម គឺសំដៅទៅសិទ្ធិដែលមានលើទ្រព្យ។ ទ្រព្យសកម្មអាចជា អចលនវត្ថុ ចលនវត្ថុ មាសប្រាក់ លុយកាក់ ភាគហ៊ុន វត្ថុមានតម្លៃផ្សេងៗជាដើម[12]។
- ទ្រព្យអកម្ម គឺសំដៅទៅលើករណីយកិច្ច។ ទ្រព្យអកម្ម អាចជាបំណុលរបស់មតកជនដែលខ្លួន (មតកជន)ត្រូវបំពេញ ប៉ុន្តែមិនទាន់បំពេញ។

## ១.៣. លក្ខណៈសម្បត្តិនៃសន្តតិជន

បន្ទាប់ពីបានសិក្សាស្វែងយល់អំពីបទដ្ឋានគតិយុត្តទាក់ទងទៅនឹងសន្តតិកម្មតាមច្បាប់រួចមក យើងនឹងសិក្សាទៅលើលក្ខណៈសម្បត្តិដែលអាចក្លាយជាសន្តតិជន។ លក្ខណៈសម្បត្តិដែលអាចក្លាយជាសន្តតិជនត្រូវកំណត់ដោយយកពេលចាប់ផ្តើមសន្តតិកម្មជាមូលដ្ឋាន។ នៅពេលចាប់ផ្តើមសន្តតិកម្ម ជនដែលអាចទទួលបានទទួលមត៌ករួមមាន ១.៣.១ ជនមានជីវិតពេលចាប់ផ្តើមសន្តតិកម្ម ១.៣.២ មិនមែនជាអភ័ព្វបុគ្គល ១.៣.៣ មិនមែនជាជនដែលត្រូវបានផ្តាច់ពីមត៌ក និង ១.៣.៤ ទារកក្នុងគភ៌។

### ១.៣.១. ជនមានជីវិតពេលចាប់ផ្តើមសន្តតិកម្ម

យោងតាមមាត្រា ១១៤៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចក្លាយជាសន្តតិជនបាន លុះត្រាតែជននោះមានជីវិតរស់នៅនាពេលចាប់ផ្តើមសន្តតិកម្ម។ [13] ជនដែលអាចក្លាយជាសន្តតិជនបានគឺរូបវន្តបុគ្គល។ ចំពោះសន្តតិជនដែលមានសញ្ជាតិបរទេស មានលក្ខខណ្ឌពិសេសមួយចំនួនត្រូវអនុវត្ត ដោយហេតុថារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ មិនអនុញ្ញាតឱ្យជនបរទេសមានសិទ្ធិលើដីធ្លីឡើយ ដូចនេះប្រសិនបើកម្មវត្ថុនៃមតកជាអចលនទ្រព្យសន្តតិជនជាជនបរទេស ត្រូវអនុវត្តនីតិវិធីផ្សេងដូចជាយកអចលនទ្រព្យនោះបំលែងទៅជាសាច់ប្រាក់វិញជាដើម។

#### ក. រូបវន្តបុគ្គល

យោងតាមមាត្រា ៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានចែងថា រូបវន្តបុគ្គលគ្រប់រូប មានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន។[14] បញ្ញត្តិនេះចែងអំពីសមត្ថភាពទទួលសិទ្ធិ និងការប្រកាសអំពីគោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ ដោយឱ្យតែរូបវន្តបុគ្គលនោះមាន

[11] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ៨, លេខ ៥៩

[12] ទិដ្ឋភាពទូទៅនៃសន្តតិកម្ម, សិក្ខាសាលាធំលើកទី ២ ថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១៣ សមិទ្ធផលរបស់ ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

[13] មាត្រា ១១៤៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[14] មាត្រា ៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ជីវិត មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈតាមផ្លូវច្បាប់បុគ្គលនោះមាននូវសិទ្ធិ និងកាតព្វកិច្ចទទួលខុសត្រូវចំពោះមុខច្បាប់។ បុគ្គលដែលមានសមត្ថភាពអាចទទួលខុសត្រូវចំពោះមុខច្បាប់បានគឺមានអាយុយ៉ាងតិច ១៨ ឆ្នាំ[15] ឬ អនីតិជនទទួលបានអគ្គាធិនភាព។[16] ចំពោះជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ និងជនស្ថិតនៅក្រោមរបបហិតូបត្ថម្ភ ក៏អាចក្លាយជាសន្តតិជនបានផងដែរលុះត្រាតែមានការយល់ព្រម ពីអ្នកអាណាព្យាបាលទូទៅ ចំពោះជននៅក្រោមអាណាព្យាបាលទូទៅ[17] និង មានការយល់ព្រមពីហិតូបត្ថម្ភកៈ ចំពោះជននៅក្រោមហិតូបត្ថម្ភ។[18]ប៉ុន្តែបញ្ញត្តិនេះមិនមានលក្ខណៈដាច់ណាត់ទេ ដោយហេតុថា ចំពោះសកម្មភាពដែលទទួលបានសិទ្ធិ ឬ រួចផុតពីកាតព្វកិច្ចសម្រាប់អនីតិជន មិនចាំបាច់មានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបាក៏បានដែរ។[19]

**ខ. ជនបរទេស**

ជនបរទេសត្រូវបានកម្រិតសិទ្ធិមួយចំនួនលើអចលនវត្ថុ ដូចមានចែងក្នុងមាត្រា ៤៤ នៃក្រមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ បានបញ្ញត្តិថា “មានតែរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លីបាន”។[20] ជាក់ស្តែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ បានបញ្ញត្តិថា “សិទ្ធិនៃកម្មសិទ្ធិដែលចែងក្នុងមាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ អនុវត្តទៅលើអចលនវត្ថុទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា តាមលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់នេះ”[21] ដែលជាការកំណត់ចែងឱ្យស្របគ្នារវាងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល និងច្បាប់ភូមិបាល។ ចំពោះសន្តតិជនដែលពុំមានសញ្ជាតិខ្មែរមិនអាចទទួលបានសន្តតិកម្មជាអចលនវត្ថុ (ដីធ្លី) ឬ អគារសហកម្មសិទ្ធិនៅជាន់ផ្ទាល់ដីបានឡើយ ប៉ុន្តែជនបរទេសមានសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិចាប់ពីជានទី ១(មួយ) ឡើងទៅ។[22] ក្នុងករណីសន្តតិជនទាំងអស់ជាជនបរទេសគ្មានសញ្ជាតិខ្មែរ ហើយចំណែកមត៌កជាអចលវត្ថុនោះនឹងត្រូវក្លាយជាទ្រព្យរបស់នីតិបុគ្គល ដែលហៅថា “នីតិបុគ្គលមត៌ក”។ នីតិបុគ្គលមត៌ក អាចក្លាយជាម្ចាស់សិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិដែលជាមត៌កនោះបានក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនលំដាប់ទី១បានយល់ព្រមទាំងស្រុង ឬ បានយល់ព្រមមានកម្រិត (ត្រឹមកម្រិតដែលទទួលបានមត៌ក)។ រីឯថ្លៃដែលទទួលបានពីការលក់ចំណែកមត៌កក្នុងនាមជា

[15] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[16] មាត្រា ២១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[17] មាត្រា ២៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[18] មាត្រា ៣០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[19] មាត្រា ១៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[20] មាត្រា ៤៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
[21] មាត្រា ៤ នៃច្បាប់ភូមិបាល ឆ្នាំ២០០១
[22] មាត្រា ៦ នៃច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស

នីតិបុគ្គលមត៌ក នឹងក្លាយជាចំណែកមត៌កត្រូវចែកឱ្យសន្តតិជនជាជនបរទេស ហើយនីតិបុគ្គលមត៌កត្រូវបញ្ចប់ភារកិច្ច និងត្រូវរំលាយចោល។[23] ប៉ុន្តែប្រសិនបើអំឡុងពេល ៣ (បី) ខែ បានកន្លងផុតហើយទ្រព្យសម្បត្តិដែលជាដីធ្លីនោះមិនអាចលក់បាន គិតចាប់ពីពេលមានការយល់ព្រមពីសន្តតិជនមានលំដាប់ទី១ នោះមត៌កដែលជាដីធ្លីនោះ ត្រូវបានធ្វើសន្តតិកម្មដោយសន្តតិជនដែលមានលំដាប់បន្ទាប់ដែលមានសញ្ជាតិខ្មែរ ហើយចំពោះនីតិបុគ្គលមត៌កវិញត្រូវបានចាត់ទុកថាគ្មានអត្ថិភាពតាំងពីពេលដែលមត៌កនោះមិនអាចចាត់ចែងក្នុងអំឡុងពេល ៣ (បី) ខែ។[24] ក្នុងករណីសន្តតិជនមានលំដាប់បន្ទាប់គ្មានសញ្ជាតិខ្មែរ នោះអចលនវត្ថុដែលជាចំណែកមត៌កនេះនឹងក្លាយជាកម្មសិទ្ធិរបស់រដ្ឋ។

**១.៣.២. មិនមែនជាអភ័ព្វបុគ្គល**

អភ័ព្វបុគ្គល គឺសំដៅដល់បុគ្គលដែលពុំអាចក្លាយជាសន្តតិជន ឬ ពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បាន[25] ពោលគឺជាប្រភេទបុគ្គលដែលច្បាប់កំណត់ថាមិនអាចទទួលបានទ្រព្យសម្បត្តិ (មត៌ក និងអច្ច័យទាន) ពីសន្តតិកម្ម។ អភ័ព្វបុគ្គលជាបុគ្គលដែលបានប្រព្រឹត្តិ ឬ ស្ថិតនៅក្នុងលក្ខខណ្ឌដូចខាងក្រោម៖

១. បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិជនមុន ឬ លំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬ ប្រយោលក្តី។

២. បុគ្គលដែលបានដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះមិនអាចវិនិច្ឆ័យល្អ ឬ អាក្រក់បាន ឬ ករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬ ញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ។

៣. បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ ការលុបចោល ឬ កែប្រែមតកសាសន៍ ដោយការឆបោក ឬ គម្រាមកំហែង។

៤. បុគ្គលដែលបានឱ្យមតកជនធ្វើ ឬ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង។

៥. បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬ លាក់ទុកនូវលិខិតមតកសាសន៍ស្តីពីសន្តតិកម្មរបស់មតកជន។[26]

[23] មាត្រា ១១៥៥ កថាខណ្ឌទី ៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[24] មាត្រា ១១៥៥ កថាខណ្ឌទី ៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[25] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ២៧, លេខ ១៩០

[26] មាត្រា ១១៥០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

### ១.៣.៣. មិនមែនជាជនដែលត្រូវបានផ្តាច់ចេញពីមត៌ក

ការផ្តាច់ចេញពីមត៌ក គឺជាការសម្រេចរបស់តុលាការតាមពាក្យសុំរបស់ម្ចាស់បណ្តាំ ឬ អ្នកប្រតិបត្តិមតកសាសន៍ អំពីការផ្តាច់មត៌កពីសន្តតិជនដែលមានសិទ្ធិលើភាគបម្រុង។ បុគ្គលដែលបានផ្តាច់ចេញពីមត៌ក មិនអាចទទួលបានចំណែកមត៌កទេ ដោយបុគ្គលប្រភេទនេះបានប្រព្រឹត្តិ ឬ ស្ថិតនៅក្នុងលក្ខខណ្ឌដូចខាងក្រោមះ

១. បានធ្វើបាបមតកជន។

២. ប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ។

៣. អាចមើលថែមតកជនបាននៅពេលមានជម្ងឺ ប៉ុន្តែមិនមើលថែទាំ។

៤. ទទួលបានសេចក្តីសម្រេចពីតុលាការ ដាក់ពន្ធនាគារមួយជីវិត។

៥. បានប្រព្រឹត្តិអំពើល្មើសធ្ងន់ធ្ងរ គួរឱ្យកត់សំគាល់ ជាអាទិ៍។[27]

### ១.៣.៤. ទារកក្នុងគភ៌

ជាគោលការណ៍ គឺមានតែបុគ្គលដែលមានជីវិតទើបអាចក្លាយជាសន្តតិជនបាន។ ប៉ុន្តែមាត្រា ៩ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តអំពីទារកដែលនៅក្នុងគភ៌ស្របពេលចាប់ផ្តើមសន្តតិកម្ម ប្រសិនបើទារកនោះមានកំណើតនៅពេលក្រោយ ទារកនោះអាចទទួលមត៌កបាន។[28] ករណីនេះ គឺជាអញ្ញត្រកម្ម ដោយគេយល់ឃើញថាទារកនៅក្នុងគភ៌ ឱកាសនៅក្នុងការរស់រានមានជីវិតមិនទាន់បានមួយរយភាគរយនៅឡើយទេ។ ប្រសិនបើបដិសេធទារកនៅក្នុងគភ៌ក្នុងការទទួលបានសិទ្ធិជាសន្តតិជន ដោយមូលហេតុទារកនោះមិនទាន់កើត គឺអាចប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ទារកនោះផងដែរ។ ដូចនេះទើបច្បាប់បញ្ញត្តិការពារដោយអាចឱ្យទារកនោះមានសិទ្ធិទទួលបានសន្តតិកម្ម កាលបើទារកនោះបានកើតមករស់រានមានជីវិត។

## ១.៤. ការចាប់ផ្តើមសន្តតិកម្ម

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានកំណត់នៅក្នុង ផ្នែកទី ១ ជំពូកទី ១ គន្តីទី ៨ ដែលបានចែងអំពី ការចាប់ផ្តើមសន្តតិកម្ម ដោយបានកំណត់យកពេលវេលា និងទីកន្លែងបើកសន្តតិកម្ម។ ក្នុងចំណុចនេះផងដែរ យើងនឹងធ្វើការសិក្សាទៅលំអិតទៅលើ ១.៤.១ ពេលវេលាបើកសន្តតិកម្ម និង ១.៤.២ ទីកន្លែងបើកសន្តតិកម្ម។

---

[27] មាត្រា ១១៥១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[28] មាត្រា ៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

### ១.៤.១. ពេលវេលាបើកសន្តតិកម្ម

ការចាប់ផ្តើមបើកសន្តតិកម្មតាមច្បាប់ជាគោលការណ៍លុះត្រាតែមតកជនទទួលមរណភាព ឬ ការបាត់ខ្លួនទើបសន្តតិកម្មត្រូវបានចាប់ផ្តើម។

#### ក. មរណភាពនៃបុគ្គល

ជាការពិតណាស់ ការទទួលមរណភាពរបស់បុគ្គលម្នាក់ទាល់តែត្រូវបានវាយតម្លៃដោយអ្នកជំនាញ និងមានការត្រួតពិនិត្យ និងការចេញលិខិតបញ្ជាក់អំពីការទទួលមរណភាពរបស់មន្ត្រីអត្រានុកូលដ្ឋាន។ ការស្លាប់គេសន្មតថាមានសាកសពមួយ ព្រោះសាកសពជាភស្តុតាងបង្ហាញថាមានការស្លាប់។

ជាគោលការណ៍ច្បាប់បានកំណត់យកពេលទទួលមរណភាព គឺជាពេលវេលាមូលដ្ឋានក្នុងការចាប់ផ្តើមសន្តតិកម្ម។[29]

#### ខ. ករណីបាត់ខ្លួន

ការបាត់ខ្លួនក៏ជាលក្ខខណ្ឌមួយដែលគេសន្មត់បានថាបុគ្គលនោះបានទទួលមរណភាពផងដែរ។ នៅក្នុងករណីដែលគេមិនអាចរកភស្តុតាងដែលបញ្ជាក់បានថាបុគ្គលម្នាក់ស្លាប់ ដោយសារមិនអាចរកសាកសពឃើញ។ តាមលក្ខខណ្ឌគតិយុត្ត ត្រូវចាំបាច់មានសាលក្រមប្រកាសពីការបាត់ខ្លួន ព្រោះសាលក្រមមានអានុភាពអាចចាត់ទុកថាជនដែលបានបាត់ខ្លួនស្លាប់បាត់ទៅហើយ។

លក្ខខណ្ឌនៃការបាត់ខ្លួនបែងចែកជា ពីរ ករណីដូចខាងក្រោម៖

១.ការបាត់ខ្លួនក្នុងលក្ខណៈធម្មតា គឺជាការបាត់ខ្លួនធម្មតាដែលត្រូវមានលក្ខខណ្ឌមិនដឹងថានៅរស់ឬទទួលមរណៈភាព រយៈពេលយ៉ាងតិច ៥ ឆ្នាំ ហើយតុលាការត្រូវប្រកាសអំពីការបាត់ខ្លួននោះតាមពាក្យសុំរបស់អ្នកដាក់ពាក្យសុំ។

២.ការបាត់ខ្លួនក្នុងលក្ខណៈពិសេស គឺជាការបាត់ខ្លួនក្នុងព្រឹត្តិការណ៍ពិសេស(គ្រោះថ្នាក់)ដូចជា សង្គ្រាម ការលិចនាវា ការរញ្ជួយផែនដី អគ្គីភ័យ ស៊ូណាមិ (រលកយក្ស) ការរអិលផ្ទាំងទឹកកកពីភ្នំ ជាអាទិ៍។ ដែលជាមូលហេតុនៃមរណភាពរបស់ជនដែលជួបប្រទះគ្រោះថ្នាក់ទាំងនេះ ហើយការមិនដឹងថារស់ ឬទទួលមរណភាពនោះមានអំឡុងពេលយ៉ាងតិច ១ ឆ្នាំ គឺជាលក្ខខណ្ឌនៃការប្រកាសអំពីការបាត់ខ្លួន។ តុលាការត្រូវប្រកាសអំពីការបាត់ខ្លួនតាមពាក្យសុំរបស់អ្នកដាក់ពាក្យសុំ។[30]

---

[29] មាត្រា ១១៤៥ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[30] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ១ គន្លឹះទី៨១-៣ មាត្រា ៤១, ទំ.៣៣-៣៤

កាលបរិច្ឆេទនៃការប្រកាសអំពីការបាត់ខ្លួន គឺជាពេលវេលានៃការបើកសន្តតិកម្មតាមច្បាប់។ ដោយសេចក្តីសម្រេចប្រកាសអំពីការបាត់ខ្លួន មានតម្លៃស្មើនឹងសំបុត្រមរណភាព។[31]

### ១.៤.២. ទីកន្លែងបើកសន្តតិកម្ម

ការចាប់ផ្តើមសន្តិកម្មតាមច្បាប់ត្រូវធ្វើឡើងនៅលំនៅឋានរបស់មតកជន។ [32] ដោយច្បាប់បានកំណត់យកលំនៅឋាន គឺជាកន្លែងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ។[33] ក្នុងករណីមតកជនមិនមានលំនៅឋានពិតប្រាកដទេ ឬ មានលំនៅឋានច្រើន ច្បាប់កំណត់យកទីសំណាក់ជាលំនៅឋាន។[34]

ការកំណត់យកលំនៅឋានរបស់មតកជនជាទីកន្លែងបើកសន្តតិកម្ម ដោយមូលហេតុក្នុងការងាយស្រួល នឹងមានប្រសិទ្ធិភាពក្នុងការជូនដំណឹងជាសាធារណៈព្រោះលំនៅឋានមានផ្ទុកនូវព័ត៌មានពាក់ពន្ធ័នឹងមតកជនកាលនៅរស់ និងងាយស្រួលក្នុងការកំណត់សមត្ថកិច្ចតុលាការក្នុងការចាប់ផ្តើមសន្តតិកម្ម។

## ១.៥. របបគតិយុត្តនៃការគ្រប់គ្រងមត៌ក

ជាទូទៅ មនុស្សគ្រប់រូបដែលកើតមកហើយតែងតែស្លាប់ទៅវិញ ដូចព្រះពុទ្ធមានពុទ្ធិកាថា "កើត ចាស់ ឈឺ ស្លាប់" ជាវាលវដ្តសង្សាររបស់សត្វលោក។ តាមទំនៀមទម្លាប់ប្រពៃណីខ្មែរ នៅពេលមានបុគ្គលណាម្នាក់ស្លាប់ គេតែងតែប្រារព្ធឡើងនូវពិធីបុណ្យសព ដើម្បីជាការដឹងគុណចំពោះសព។ ការប្រព្រឹត្តិពិធីបុណ្យសពនេះទៀតសោតតែងតែធ្វើទៅតាមសាសនានីមួយៗ ដោយហេតុថាសាច់ញាតិនៃសពមានភាពមមាញឹក និងកាន់ទុក្ខចំពោះសព ទើបមិនអាចគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់បុគ្គលដែលបានស្លាប់។ ការស្លាប់ គឺអាចបញ្ជាក់ថាបុគ្គលនោះបានបាត់បង់នូវបុគ្គលភាពគតិយុត្ត ដូច្នេះហើយទាក់ទងនឹងទ្រព្យសម្បត្តិរបស់បុគ្គលដែលស្លាប់នោះត្រូវមានការគិតគូរថាតើមានបុគ្គលណាផ្សេងទៀត នឹងទទួលបន្តជាម្ចាស់សិទ្ធិថ្មីលើទ្រព្យសម្បត្តិទាំងនោះដែរឬទេ? ហេតុនេះហើយបានជាក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ គន្ថីទី ៨ ជំពូកទី ៦ បានកំណត់អំពី របបនៃការគ្រប់គ្រងមត៌ករបស់មតកជន ដើម្បីឱ្យមានអ្នកគ្រប់គ្រងមត៌ក នៅពេលមតកជនបានទទួលមរណភាព ត្រូវរក្សាទុក និងគ្រប់គ្រងមត៌កនោះ រហូតដល់ពេលធ្វើការបែងចែក។

[31] មាត្រា ៤៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

[32] មាត្រា ១១៤៦ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

[33] មាត្រា ៣៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

[34] មាត្រា ៣៥ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០០៧

### ១.៥.១. ការគ្រប់គ្រងមត៌ក

របបនៃការគ្រប់គ្រងមត៌កចាំបាច់ត្រូវតែបង្កើតឡើង ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសន្តតិកម្ម នៅមុនពេលដែលសន្តតិជនសម្រេចចិត្តយល់ព្រម ឬ យល់ព្រមមានកម្រិត ឬ បោះបង់ ចំណែកមត៌ករបស់ខ្លួន។ នៅក្នុងរបបនៃការគ្រប់គ្រងមត៌កនេះមាន ៣ ករណី គឺ៖

**ករណីទី១៖** សន្តតិជនដែលកាន់កាប់មត៌ក នៅពេលដែលមតកជនបានទទួលមរណភាពត្រូវរក្សាទុក និងគ្រប់គ្រងមត៌កនោះ ដោយប្រុងប្រយ័ត្នប្រៀបដូចជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន (គោលការណ៍សុចរិត និងស្មោះត្រង់) រហូតដល់ពេលដែលធ្វើការបែងចែកមត៌ក។[35] ទោះបីជាសន្តតិជននោះបានបោះបង់នូវសិទ្ធិទទួលសន្តតិកម្មក៏ដោយ ក៏ត្រូវមានកាតព្វកិច្ចគ្រប់គ្រងទ្រព្យសម្បត្តិនោះដោយប្រុងប្រយ័ត្នផងដែរ ទោះបីជាទ្រព្យសម្បត្តិនោះមិនមែនជារបស់ខ្លួន ហើយការគ្រប់គ្រងនោះ គឺគ្រប់គ្រងរហូតដល់ពេលដែលអ្នកដែលបានក្លាយជាសន្តតិជនអាចធ្វើការគ្រប់គ្រងមត៌កនោះបាន។[36]

**ករណីទី២៖** ក្នុងករណីដែលសន្តតិកម្ម ធ្វើឡើងតាមរយៈមតកសាសន៍ និងបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើការគ្រប់គ្រងមត៌កនោះ លើកលែងតែមតកសាសន៍ចែងផ្សេងពីនេះ ឬ មានលក្ខណៈជាក់លាក់ចំពោះទ្រព្យណាមួយជាអាទិ៍។ អ្នកប្រតិបត្តិមតកសាសន៍ត្រូវគ្រប់គ្រងមត៌ក ពេលចាប់ផ្ដើមកាន់កាប់មុខងារ។ ករណីនេះគឺអនុវត្តបានតែកម្មវត្ថុនៃមត៌កជាទ្រព្យដែលបានកំណត់នៅក្នុងមតកសាសន៍ប៉ុណ្ណោះ ប្រសិនបើមិនមានកំណត់នៅក្នុងមតកសាសន៍ទេ គឺត្រូវអនុវត្តទៅតាមការរក្សាទុក និងការគ្រប់គ្រងមត៌ក។[37]

**ករណីទី៣៖** បើគ្មានអ្នកប្រតិបត្តិមតកសាសន៍គ្រប់គ្រងមត៌កទាំងមូលទេ សន្តតិជន ឬ អច្ច័យលាភី ឬ ម្ចាស់បំណុលរបស់មតកជនអាចដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្ដោះអាសន្ន រហូតដល់ពេលធ្វើការបែងចែកមត៌ក។[38]ពោលគឺតុលាការជាអ្នកចាត់ចែងអ្នកកាន់កាប់ជាបណ្ដោះអាសន្ន រហូតដល់ពេលការបែងចែករួចរាល់។ សោហ៊ុយដែលជាបន្ទុកនៃមត៌កត្រូវចំណាយចេញពីក្នុងទ្រព្យសម្បត្តិនោះ លើកលែងតែកើតចេញពីកំហុសរបស់សន្តតិជនជាអាទិ៍ នាំឱ្យជាបន្ទុករបស់បុគ្គលនោះ។[39]មានន័យថា រាល់ការចំណាយដើម្បីគ្រប់គ្រងទៅលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃមត៌ក ត្រូវកាត់ចេញពីតម្លៃនៃមត៌កនោះ។

[35] មាត្រា ១២៦២ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[36] មាត្រា ១២៦២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[37] មាត្រា ១២៦៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[38] មាត្រា ១២៦៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[39] មាត្រា ១២៦៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

## ១.៦. សន្តតិជនដែលច្បាប់បានកំណត់

ជាទូទៅការកំណត់សន្តតិជន គឺចង់សំដៅទៅលើជនដែលទទួលបានសិទ្ធិ និងករណីយកិច្ចបន្តពីមតកជនពោលគឺ "ម្ចាស់បណ្តាំ"។ វាក៏ជាវិធានមួយដែលមានលក្ខណៈកើតចេញពីទំនាក់ទំនងរវាងបុគ្គលដែលទទួលមរណភាព ហើយបានបន្សល់ទុកនូវទ្រព្យសម្បត្តិរបស់ខ្លួន និងបុគ្គលដែលត្រូវទទួលបានទ្រព្យរបស់មតកជនបន្សល់ទុក។ ម្យ៉ាងវិញទៀត បុគ្គលដែលមានសិទ្ធិ និងករណីយកិច្ចដែលទទួលទ្រព្យសម្បត្តិពីមតកជននោះមានសិទ្ធិក្នុងការបដិសេធមិនទទួលយកមត៌កពីមតកជនបានដោយគ្រាន់តែបង្ហាញឆន្ទៈ។ ហេតុនេះបានជាក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបញ្ញត្តិអំពីបុគ្គលដែលមានសិទ្ធិទទួលមត៌ករបស់មតកជន (ម្ចាស់បណ្តាំ ឬ ខ្មោច) នោះត្រូវតែជាញាតិរបស់មតកជនផ្ទាល់ ពោលគឺសំដៅទៅលើញាតិលោហិតមិនមែនញាតិពន្ធទេ។ យោងតាមមាត្រា៩៧២ នៃក្រមរដ្ឋប្បវេណី២០០៧ ញាតិតាមច្បាប់មានដូចជា ញាតិលោហិតក្នុង៦ថ្នាក់ សហព័ទ្ធ និងញាតិពន្ធក្នុង៣ថ្នាក់។ ក្នុងចំណោមញាតិដូចកំណត់ខាងលើ មានតែញាតិ៣លំដាប់ប៉ុណ្ណោះដែលជាបុគ្គលមានសិទ្ធិទទួលបានឋានៈជាសន្តតិជនតាមច្បាប់ និងសហព័ទ្ធដែលជាគោលការណ៍ក្រោយរៀបអាពាហ៍ពិពាហ៍អ្នកទាំងពីរមានសិទ្ធិ និងកាតព្វកិច្ចជាមួយគ្នារួមទាំងការបង្កើត បង្កើនទ្រព្យសម្បត្តិផងដែរ។ នេះជាហេតុផលដែលសហព័ទ្ធបានទទួលឋានៈជាសន្តតិជនជានិច្ច។

ច្បាប់បានកំណត់នូវលំដាប់សន្តតិជនរបស់មតកជន ដែលក្នុងនោះរួមមាន៖ សន្តតិជនលំដាប់ទី១ សន្តតិជនលំដាប់ទី២ និងសន្តតិជនលំដាប់ទី៣។ ក្រៅពីសន្តតិជនទាំងបីខាងលើនេះនៅមានសន្តតិជនដែលត្រូវទទួលបានមត៌កជានិច្ច ហៅថា "សន្តតិជនជានិច្ច" និងសន្តតិជនដែលត្រូវទទួលបន្ត ហៅថា "សន្តតិជនជំនួស"។

### ១.៦.១. សន្តតិជនលំដាប់ទី១

ដោយយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ សន្តតិជនលំដាប់ទី១ គឺចង់សំដៅទៅលើបុគ្គលដែលមានអត្ថិភាពក្នុងការទទួលបានចំណែកមត៌កមុនគេ បន្ទាប់ពីមរណភាពរបស់មតកជន។ ក្នុងន័យនេះ កូនបង្កើតរបស់មតកជន ដែលជាបច្ឆាញាតិថ្នាក់ទី ១ គឺជាសន្តតិជនលំដាប់ទី១[40] មានន័យថា កូនបង្កើត ឬ កូនសុំរបស់មតកជនដែលត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់ ឬ ដោយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់រវាងមតកជន និងសហព័ទ្ធ។ ករណីប្រសិនបើមតកជនពេលនៅរស់បានបង្កើតសុំកូនស្របច្បាប់ កូនសុំនោះត្រូវបានច្បាប់ទទួលស្គាល់ ករណីនេះទៀតសោតទោះបីជាកូនបង្កើតក្តី ឬ កូនសុំក្តីត្រូវទទួលឋានៈក្នុងគ្រួសារស្មើគ្នា

[40] មាត្រា ១១៥៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

និងត្រូវមានចំណែកមត៌កស្មើៗគ្នា។[41] ចំពោះកូនសុំពេញលេញ ញាតិភាពតាមផ្លូវច្បាប់ជាមួយនឹងឪពុកម្តាយបង្កើតត្រូវបានបញ្ចប់ ដូច្នេះកូនសុំពេញលេញមិនអាចក្លាយជាសន្តតិជនរបស់ឪពុកម្តាយបង្កើតទេ ពោលគឺអាចក្លាយជាសន្តតិជនចំពោះឪពុកម្តាយចិញ្ចឹមប៉ុណ្ណោះ។ ចំពោះកូនសុំនៃស៊ុំកូនធម្មតាវិញ អាចទទួលសន្តតិកម្មពីឪពុកម្តាយបង្កើតផង និងពីឪពុកម្តាយចិញ្ចឹមផង។[42]

### ១.៦.២. សន្តតិជនលំដាប់ទី២

សន្តតិជនលំដាប់ទី២ មានវត្តមានក្នុងករណីដែលគ្មានបច្ឆាញាតិផ្ទាល់ថ្នាក់ទី ១ (កូន) ជាសន្តតិជន នោះបុព្វញាតិខ្សែផ្ទាល់ថ្នាក់ទី ១ របស់មតកជន ត្រូវក្លាយជាសន្តតិជនលំដាប់ទី២។ សន្តតិជនលំដាប់ទី ២ គឺចង់សំដៅទៅលើបុព្វញាតិ រួមមានដូចជា ឪពុក ម្តាយ ឬ ជីដូនជីតារបស់មតកជន។ បុព្វញាតិខ្សែផ្ទាល់ ត្រូវទទួលបានចំណែកស្មើៗគ្នា។[43]

ក្នុងករណីមតកជន គ្មានសន្តតិជនលំដាប់ទី១ (កូន) លំដាប់បន្ទាប់ត្រូវធ្លាក់លើបុព្វញាតិដែលមានលំដាប់ជិតជាងគេរបស់មតកជន ពោលគឺករណីមតកជនមានឪពុក មានម្តាយ ព្រមទាំងជីដូនជីតាផង នោះអ្នកដែលអាចក្លាយជាសន្តតិជនលំដាប់ទី២ គឺឪពុកម្តាយ ដោយហេតុច្បាប់បានកំណត់យកបុព្វញាតិដែលមានថ្នាក់ញាតិជិតជាងគេរបស់មតកជន។ ក្នុងករណីមតកជនគ្មានឪពុកម្តាយ គឺជីដូនជីតានឹងក្លាយជាសន្តតិជនលំដាប់ទី ២។ ក្នុងនោះជីដូនជីតាអាចមានខាងឪពុក និងខាងម្តាយ នោះជីដូនជីតាទាំងខាងឪពុក និងខាងម្តាយក្លាយជាសហសន្តតិជន។ ការបែកចែកចំណែកមត៌កនេះ គឺត្រូវចែកចំណែកស្មើៗគ្នាទៅតាមចំនួនមនុស្ស។ ក្នុងករណីសន្តតិជនលំដាប់ទី ២នេះ បើមានវត្តមានសន្តតិជនជំនួស គឺច្បាប់មិនមានការទទួលស្គាល់ឡើយ ពីព្រោះថា ប្រសិនបើជាគ្មានបុព្វញាតិដែលជា ឪពុក ម្តាយ ឬជីដូនជីតាទេ នោះចំណែកមត៌កនឹងត្រូវធ្លាក់ទៅលើកូនរបស់បុព្វញាតិ និងជាញាតិថ្នាក់ទី ២ របស់មតកជន(បងប្អូនបង្កើតរបស់មតកជន)ដែលច្បាប់បានទទួលស្គាល់រួចជាស្រេចថាបងប្អូនបង្កើតជា សន្តតិជនលំដាប់ទី ៣។

### ១.៦.៣. សន្តតិជនលំដាប់ទី៣

ជាគោលការណ៍ច្បាប់បានកំណត់យកបច្ឆាញាតិផ្ទាល់(កូនរបស់តកជន) ជាសន្តតិជនលំដាប់ទី ១ ប្រសិនបើគ្មានសន្តតិជនលំដាប់ទី ១ នោះបុព្វញាតិផ្ទាល់នឹងក្លាយជាសន្តតិជនលំដាប់ទី ២ ប៉ុន្តែក្នុងករណីដែលមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់ នោះច្បាប់បានបញ្ញត្តិយកបងប្អូនបង្កើតរបស់មតកជន

[41] មាត្រា ១១៥៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[42] មាត្រា ១០២៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[43] មាត្រា ១១៥៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ជាសន្តតិជនលំដាប់ទី៣[44]។ ហើយចំណែកមត៌កត្រូវបែងចែកទៅតាមសមាមាត្រនៃចំនួនបងប្អូនបង្កើតរបស់មត៌កជន។ ផ្ទុយទៅវិញករណីបងប្អូនបង្កើតមានតែឪពុក ឬ ម្ដាយរួមតែម្ខាង ត្រូវទទួលបានចំណែកពាក់កណ្ដាលនៃចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុកម្ដាយរួមទាំងសងខាងដូចគ្នា។[45]

### **១.៦.៤. សន្តតិជនជានិច្ច**

សន្តតិជនជានិច្ច ឬ សន្តតិជនអចិន្ត្រៃយ៍ គឺជាសហព័ទ្ធរបស់មតកជន។[46] សន្តតិកម្មរបស់សហព័ទ្ធ ជាសិទ្ធិដែលសហព័ទ្ធត្រូវទទួលបាននូវចំណែកមត៌កពីសហព័ទ្ធម្ខាងទៀតរបស់ខ្លួនដែលបានស្លាប់ តាមការកំណត់របស់ច្បាប់ សហព័ទ្ធត្រូវក្លាយជាសន្តតិជនជានិច្ច។ យោងតាមមាត្រា ១១៦២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ សន្តតិជនជានិច្ច មានលំដាប់ដូចគ្នាទៅនឹងលំដាប់នៃសន្តតិជននីមួយៗ។ ករណីសហព័ទ្ធរបស់មតកជន និងបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធត្រូវក្លាយជាសន្តតិជន នោះចំណែកមត៌ករបស់សន្តតិជននឹងត្រូវបានបែងចែកតាមការកំណត់ដូចខាងក្រោម ៖

- បើសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់របស់មតកជននោះជាសន្តតិជន សហព័ទ្ធ និងកូននីមួយៗនឹងត្រូវទទួលចំណែកម៌តកស្មើគ្នា។
- បើសហព័ទ្ធ និងឪពុកម្ដាយរបស់មតកជនជាសន្តតិជន នោះចំណែកមត៌ករបស់សហព័ទ្ធត្រូវជា ១/៣ (មួយភាគបី) ឯចំណែកមត៌កឪពុកម្ដាយត្រូវជា ២/៣ (ពីរភាគបី)។ ប៉ុន្តែបើឪពុក ឬ ម្ដាយរបស់មតកជនតែម្នាក់នៅរស់ ឪពុកម្ដាយនោះ និងសហព័ទ្ធត្រូវបានចំណែកមត៌កស្មើគ្នា។
- បើសហព័ទ្ធ និងបុព្វញាតិផ្ទាល់ក្រៅពីឪពុកម្ដាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធត្រូវជា ១/២ (មួយភាគពីរ) ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ ក្រៅពីឪពុកម្ដាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសនោះត្រូវជា ១/២ (មួយភាគពីរ)។[47]

ប៉ុន្តែក្នុងករណីដែលជននោះជាអភ័ព្វបុគ្គល ឬ ជាបុគ្គលដែលត្រូវផ្ដាច់ពីសន្តតិកម្ម ជននោះមិនអាចទទួលសន្តតិកម្មបានឡើយ ទោះបីជាសហព័ទ្ធរបស់មតកជនក៏ដោយ។

---

[44] មាត្រា ១១៦០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[45] មាត្រា ១១៦០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[46] មាត្រា ១១៦១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[47] មាត្រា ១១៦២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

### ១.៦.៥. សន្តតិជនជំនួស

សន្តតិជនជំនួស អាចកើតមានឡើងក្នុងករណី ២ (ពីរ) គឺសន្តតិជនជាអភ័ព្វបុគ្គល ឬ ជនដែលផ្តាច់ពីមត៌ក និងករណីដែលសន្តតិជនទទួលមរណភាពមុន ឬ ស្របគ្នាជាមួយមតកជន។[48]ក្នុងករណីដែលសន្តតិជនជាអភ័ព្វបុគ្គល ឬ ជនដែលបានផ្តាច់ចេញពីចំណែកមត៌ក ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានបង្កើតឱ្យមាននូវសន្តតិជនជំនួស ដើម្បីទទួលបាននូវចំណែកមត៌កជំនួសពីជនដែលជាអភ័ព្វបុគ្គល ឬ ជនដែលបានផ្តាច់ចេញពីចំណែកមត៌ក។ សន្តតិជនជំនួស គឺជាបច្ឆាញាតិនៃជនដែលមិនមានលក្ខណៈសម្បត្តិអាចក្លាយជាសន្តតិជនបាន ពោលគឺសន្តតិជនជំនួសអាចជាកូន ឬ ចៅនៃអភ័ព្វបុគ្គល ឬ ជនដែលត្រូវបានផ្តាច់ពីមត៌ក។

ប្រសិនបើកូនរបស់មតកជនទទួលមរណភាពនៅមុន ឬ ស្របពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិក្លាយជាសន្តតិជន នោះកូនរបស់បុគ្គលនោះត្រូវក្លាយជាសន្តតិជនជំនួស ដែលជននោះត្រូវតែជាបច្ឆាញាតិផ្ទាល់របស់មតកជន។

សន្តតិជនជំនួស គឺទទួលបានចំណែកស្មើគ្នានៃចំណែកមត៌កដែលសន្តតិជនទទួលបាន ដោយមិនថាសន្តតិជនជំនួសនោះជាកូនបង្កើត ឬកូនសុំទេ។ ករណីកូនរបស់មតកជនជាកូនសុំ តាមរបបសុំកូនធម្មតា នោះមានករណី ២ គឺ៖

- **ទីមួយ៖** កូនដែលសុំមានកូនមុនពេលបង្កើតរបបសុំកូន និង
- **ទីពីរ៖** កូនដែលសុំមានកូនក្រោយពេលបង្កើតរបបសុំកូន។

ក្នុងករណីទីមួយ កូនរបស់កូនសុំនៃមតកជនដែលមានមុនពេលការសុំកូននេះកើតឡើង កូននោះមិនអាចក្លាយជាសន្តតិជនជំនួសបានទេ។ ចំណែកឯកូនរបស់កូនសុំនៃមតកជនដែលមានកំណើតបន្ទាប់ពីមានការបង្កើតការសុំកូន កូនរបស់កូនសុំនោះអាចក្លាយជាសន្តតិជនជំនួសបាន។[49]

សន្តតិកម្មជំនួស អាចធ្វើជាបន្តបន្ទាប់បានសម្រាប់បច្ឆាញាតិផ្ទាល់របស់មតកជន ប្រសិនបើមានហេតុដូចមានកំណត់ខាងលើ ដូចជាករណីចៅរបស់មតកជនបានទទួលមរណភាព នោះកូនរបស់ចៅ (ចៅទួតរបស់មកតជន) នឹងក្លាយជាសន្តតិជនជំនួស។[50]

---

[48] មាត្រា ១១៥៧(ថ្មី) កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[49] មាត្រា ១១៥៧(ថ្មី) កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[50] មាត្រា ១១៥៧(ថ្មី) កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

សន្តតិកម្មជំនួស អាចអនុវត្តចំពោះសន្តតិជនលំដាប់ទី ៣ បាន។ ប៉ុន្តែច្បាប់ទទួលស្គាល់តែមួយតំណប៉ុណ្ណោះ ហើយការអនុវត្តមិនអាចអនុវត្តជាបន្តបន្ទាប់បាននោះទេ។[51]

ក្រោយពីបានសិក្សាទៅលើសញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់រួចមក យើងនឹងធ្វើការសិក្សាបន្តអំពីនីតិវិធីបែងចែកមត៌កតាមច្បាប់នៅជំពូកទី២។

[51] មាត្រា ១១៦០ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

# ជំពូកទី២
# នីតិវិធីបែងចែកមត៌កតាមច្បាប់

# ជំពូកទី ២
# នីតិវិធីបែងចែកមត៌កតាមច្បាប់

បន្ទាប់ពីបានសិក្សាជំពូកទី ១ ទាក់ទងនឹងសញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់រួចមក នៅក្នុងជំពូកទី ២ នេះយើងនឹងសិក្សាអំពី នីតិវិធីនៃការបែងចែកមត៌កតាមច្បាប់។ ការបែងចែកមត៌កអាចធ្វើឡើងតាមរយៈការព្រមព្រៀងគ្នាពីសំណាក់សហសន្តតិជនទាំងអស់ ប៉ុន្តែប្រសិនបើការព្រមព្រៀងគ្នានោះពុំអាចធ្វើទៅបានទេ នោះការបែងចែកនឹងធ្វើឡើងដោយតុលាការ។ ម៉្យាងវិញទៀត ការបែងចែកនេះជាចំណុចក្នុងការកំណត់ចំណែករបស់សន្តតិជននីមួយៗ ដែលទទួលស្គាល់ដោយច្បាប់ ហេតុនេះហើយទើបក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានបញ្ញត្តិនៅក្នុង គន្ថីទី ៨ ជំពូកទី ៦ ផ្នែកទី ២ ស្តីអំពី "ការបែងចែកមត៌ក" នេះឡើង។

នៅក្នុងជំពូកទី ២ នេះផងដែរ យើងបានធ្វើការបែងចែកជា ៥ ចំណុចរួមមាន ២.១ វិធីបែងចែកមត៌ក ២.២ ការយល់ព្រម និងការបោះបង់សន្តតិកម្ម ២.៣ ការបែងចែកមត៌កតាមលំដាប់សន្តតិជន ២.៤ ការសម្រួលចំណែកមត៌ក និង ២.៥ ស្ថានភាពពិសេស។

## ២.១. វិធីបែងចែកមត៌ក

ការបែងចែកមត៌ក អាចធ្វើឡើងតាមរយៈការពិភាក្សា ឬ ប្រសិនបើការពិភាក្សាមិនអាចធ្វើទៅបាន គឺការបែងចែកអាចធ្វើឡើងតាមរយៈតុលាការ ដោយការបែងចែកមត៌កនាំឱ្យមានអានុភាពមួយជាក់លាក់តាមការកំណត់របស់ច្បាប់ និងមានស្ថានភាពមួយចំនួនទៀតដូចជាករណីពិសេសការទទួលស្គាល់សន្តតិជនក្រោយការបែងចែកមត៌កជាអាទិ៍។

### ២.១.១. ការពិភាក្សាបែងចែកមត៌ក

ជាគោលការណ៍ការបែងចែកមត៌កត្រូវធ្វើឡើងតាមការពិភាក្សាគ្នានៃសហសន្តតិជន ដោយសហសន្តតិជនអាចពិភាក្សាគ្នាបែងចែកមត៌កនៅពេលណាក៏បាន បើអំឡុងពេល ០១ (មួយ) ខែ បានកន្លងផុតទៅ ក្រោយពីការចាប់ផ្តើមសន្តតិកម្ម [52] ពោលគឺការពិភាក្សាបែងចែកសន្តតិកម្មអាចធ្វើបានបន្ទាប់ពីមតកជនទទួលមរណភាពរយៈពេល ០១ (មួយ) ខែ។ សហសន្តតិជន មានកាតព្វកិច្ចក្នុងការចូលរួមពិភាក្សាបែងចែកមត៌ក ទោះបីជាសន្តតិជននោះបានទទួលផលប្រយោជន៍ពិសេសច្រើន ក៏សន្តតិជននោះចាំបាច់ត្រូវចូលរួមផងដែរដើម្បីបញ្ជាក់អំពីការទទួលបាននូវប្រទានកម្មនោះដែរ។

[52] មាត្រា ១២៦៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ការផ្លាស់ប្តូរម្ចាស់សិទ្ធិលើមត៌ក ដោយសារលទ្ធផលនៃការបែងចែកមិនអាចធ្វើបានឡើយ បើអំឡុងពេលច្បាប់បានកំណត់មិនទាន់កន្លងហួស (អំឡុងពេល ០៣ ខែ នៃការបង្ហាញឆន្ទៈ បោះបង់ ឬ ទទួលយកសន្តតិកម្ម) លើកលែងមានភាពចាំបាច់ដើម្បីសងកាតព្វកិច្ចមតកជន ឬ មតកជនអាចបង្ហាញឆន្ទៈនៅក្នុងមតកសាសន៍អំពីអំឡុងពេលនៃការបែងចែកជាអាទិ៍។[53] ម្យ៉ាងវិញទៀត ដើម្បីផ្ទេរសិទ្ធិចំពោះការបែងចែកមត៌ក ត្រូវធ្វើឡើងតាមទម្រង់ចាំបាច់នៃការផ្ទេរសិទ្ធិនីមួយៗ ដូចជាលិខិតលាយលក្ខណ៍អក្សរ (ដីធ្លី) ករណីចំណែកកម្មសិទ្ធអវិភាគត្រូវបានផ្ទេរ ប៉ុន្តែដីធ្លីនោះត្រូវបានមតកជនដាក់ជាកម្មសិទ្ធិរបស់សន្តតិជនជាក់លាក់ណាមួយ ហើយដើម្បីចុះបញ្ជីអំពីការផ្ទេរនេះត្រូវធ្វើលិខិតយថាភូត។[54] ក្នុងករណីដែលមានសហព័ទ្ធណាម្ខាងបានទទួលមរណភាព នោះទ្រព្យសម្បត្តិពាក់កណ្តាលជារបស់សហព័ទ្ធដែលនៅរស់ ហើយពាក់កណ្តាលទៀតជាមត៌កគឺជាកម្មវត្ថុនៃការបែងចែក។ ប្រសិនបើកម្មវត្ថុនៃសន្តតិកម្មជាកម្មសិទ្ធិអវិភាគ ទ្រព្យសម្បត្តិរួមក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ច្បាប់បានកំណត់ថាសហព័ទ្ធជាសន្តតិជនមានអាទិភាពទទួលបាននូវចំណែកមត៌កដែលជាកម្មសិទ្ធិអវិភាគនោះ ច្រើនជាងសហសន្តតិជនផ្សេងទៀត។[55]ទ្រព្យសម្បត្តិសហព័ទ្ធណាម្ខាង ឬ ទាំងសងខាងបានធ្វើលទ្ធកម្ម ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍នោះទ្រព្យសម្បត្តិនោះ គឺជាទ្រព្យសម្បត្តិរួម។[56]

ម្យ៉ាងវិញទៀត ការបន្សល់ទុកមត៌ករបស់មតកជនមិនត្រឹមតែជាទ្រព្យសម្បត្តិនោះទេ អាចមានទាំងកាតព្វកិច្ចដែលត្រូវទទួលខុសត្រូវតាមសមាមាត្ររបស់សហសន្តតិជននីមួយៗ ហៅថា "គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ" មានន័យថាគឺជាការធ្វើសមាមាត្រមិនត្រឹមតែចំពោះទ្រព្យសម្បត្តិនោះទេ តែក៏អនុវត្តចំពោះកាតព្វកិច្ចផងដែរ ហើយមិនអាចប្តូរសមាមាត្រនៃបន្ទុកនេះបានទេ បើទោះបីជាមានការព្រមព្រៀងគ្នាក៏ដោយ។ ក្នុងករណីដែលមតកជនបានធ្វើអាជីវកម្ម ដោយមានទាំងទ្រព្យសកម្ម និងទ្រព្យអកម្មដើម្បីព្រមព្រៀងឱ្យសន្តតិជនណាម្នាក់ ឬ ច្រើននាក់ ទទួលកាតព្វកិច្ចពាក់ព័ន្ធនឹងអាជីវកម្មនោះជំនួសឱ្យការទទួលបន្តអាជីវកម្មលុះត្រាតែម្ចាស់បំណុលយល់ព្រមដោយពិចារណាទៅលើសមត្ថភាពរបស់សន្តតិជននោះ។[57]

### ២.១.២. មូលដ្ឋាននៃការបែងចែក

ដើម្បីអាចបែងចែកមត៌កបានត្រឹមត្រូវ និងស្របច្បាប់ជាគោលការណ៍ត្រូវមានវត្តមាននៃមូលដ្ឋាននៃការបែងចែក ក្នុងករណីពុំបានកំណត់វិធីនៅក្នុងការបែងចែកនៅក្នុងមតកសាសន៍នោះទេ ការបែងចែកមត៌កត្រូវធ្វើ

[53] មាត្រា ១២៦៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[54] មាត្រា ១២៦៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[55] មាត្រា ១២៦៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[56] មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[57] មាត្រា ១២៦៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ឡើងដោយពិចារណាទៅលើប្រភេទ លក្ខណៈនៃវត្ថុ សិទ្ធិដែលមាននៅក្នុងមត៌ក អាយុ មុខរបរ ស្ថានភាពផ្លូវកាយ ផ្លូវចិត្ត ស្ថានភាពជីវភាពរបស់សហសន្តតិជននីមួយៗ និងស្ថានភាពផ្សេងៗទៀតដោយមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ។[58] នៅក្នុងករណីការបែងចែកដែលបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃសហសន្តតិជនអាចឱ្យសហសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះបានដោយដាក់លក្ខខណ្ឌឱ្យបង់ប្រាក់សម្រួល ចំពោះសហសន្តតិជនផ្សេងទៀតតាមការពិភាក្សា[59] ដូចជាការបែងចែកវត្ថុដែលជាកម្មសិទ្ធិអវិភាគ ដំណោះស្រាយ គឺប្រាក់សំណង។

### ២.១.៣. ការសម្រួលរវាងម្ចាស់បំណុល

ម្ចាស់បំណុលរបស់មតកជន មានសិទ្ធិអនុវត្តដោយយកមត៌កមកបម្រុងទុក ឬ ម្ចាស់បំណុលរបស់សន្តតិជនមានសិទ្ធិលើបំណុលដែលអាចយកទ្រព្យផ្ទាល់របស់សន្តតិជននោះបាន។ ហេតុនេះច្បាប់បានកំណត់បញ្ញត្តិថា ម្ចាស់បំណុលរបស់មតកជនមានសិទ្ធិអនុវត្តដោយយកមត៌កមកទុកបម្រុង តាមរយៈការហាមឃាត់មិនឱ្យធ្វើការផ្ទេរកម្មសិទ្ធិពីមតកជនទៅឱ្យសន្តតិជន ហើយនៅក្នុងអំឡុងពេលនេះម្ចាស់បំណុលរបស់មតកជនអាចទាមទារឱ្យជ្រើសតាំងអ្នកគ្រប់គ្រងមត៌កប្រសិនបើគ្មានអ្នកប្រតិបត្តិមតកសាសន៍ ហើយម្ចាស់បំណុលអាចធ្វើការទាមទារឱ្យរក្សាការពារទ្រព្យសម្បត្តិទាំងអស់នោះ មានន័យថានៅក្នុងអំឡុងពេលនេះម្ចាស់បំណុលមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនចំពោះសន្តតិជនដោយផ្ទាល់បានឡើយ ប៉ុន្តែអាចរក្សាការពារទ្រព្យទាំងនេះបាន ដែលជាវិធានសម្របសម្រួលមួយ។ ដោយឡែក នៅក្នុងករណីដែលមានសន្តតិជនច្រើននាក់ បើមានការយល់ព្រមដោយមានកម្រិត តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក នៅក្នុងចំណោមសន្តតិជនទាំងនោះ ដោយអ្នកគ្រប់គ្រងនោះ ត្រូវបំពេញរាល់សកម្មភាពចាំបាច់ក្នុងការគ្រប់គ្រងមត៌ក និងសងកាតព្វកិច្ចដើម្បីខ្លួនឯងផ្ទាល់ និងជំនួសសហសន្តតិជនដទៃទៀត។[60]ករណីដែលសន្តតិជនបានបោះបង់សន្តតិកម្ម ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិដូចបានរៀបរាប់ខាងលើនោះទេ ហើយសន្តតិជនក៏មិនអាចទទួលចំណែកមត៌កនោះបានដែរ។

ករណីសន្តតិជនបានយល់ព្រមដោយមានកម្រិត សន្តតិជនត្រូវជូនដំណឹងជាសាធារណៈអំពីការយល់ព្រមដោយមានកម្រិតនេះទៅម្ចាស់បំណុលក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ដោយកំណត់អំឡុងពេលជាក់លាក់ណាមួយសម្រាប់ឱ្យម្ចាស់បំណុលដាក់ពាក្យស្នើសុំ និងចាប់ផ្តើមឱ្យមាននីតិវិធីជម្រះបញ្ជីដែរ។[61] ក្នុងអំឡុងពេលនេះ

[58] មាត្រា ១២៦៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[59] មាត្រា ១២៦៧ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[60] មាត្រា ១២៨៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[61] មាត្រា ១២៨១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

សន្តតិជនធ្វើការយល់ព្រមដោយមានកម្រិតត្រូវគ្រប់គ្រង ថែរក្សានូវមត៌ក ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត។[62] បន្ទាប់ពីអំឡុងពេលនៃការជូនដំណឹងបានផុតកំណត់ សន្តតិជនយល់ព្រមមានកម្រិតមានកាតព្វកិច្ចសងនូវបំណុលទាំងអស់ឱ្យទៅម្ចាស់បំណុល តាមសមាមាត្រនៃចំណែករបស់ខ្លួនធៀបនឹងសិទ្ធិលើបំណុលនោះ។ [63] ទោះបីជាសិទ្ធិលើបំណុលមិនទាន់បានមកដល់ថ្ងៃកំណត់ក៏ដោយ សន្តតិជនដែលទទួលខុសត្រូវមានកម្រិតអាចសងបំណុលទាំងនោះទៅម្ចាស់បំណុលបាន។[64]ក្នុងករណីសន្តតិជនទទួលខុសត្រូវមានកម្រិត មិនមានសមត្ថភាពក្នុងការអនុវត្តកាតព្វកិច្ចទេ អាចលក់មត៌កដែលជាវត្ថុ ដើម្បីសងទៅម្ចាស់បំណុលតាមវិធីលក់ដោយបង្ខំ ឬ លក់ក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ។[65] ក្នុងករណីនេះ ម្ចាស់បំណុល ឬ អច្ច័យលាភី អាចជាក្លាយអ្នកទិញមត៌កនោះបាន។[66]

### ២.១.៤. ការបែងចែកដោយតុលាការ

ចំពោះសន្តតិជនណាមិនបានយល់ព្រមក្នុងការបែងចែកតាមការពិភាក្សានោះទេ សន្តតិជននោះអាចដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការបែងចែកបាន។ ជាគោលការណ៍តុលាការធ្វើការបែងចែកមត៌កជំនួសឱ្យសន្តតិជន នៅក្នុងករណីដែលការពិភាក្សារបស់សហសន្តតិជននៅក្នុងការបែងចែកមត៌កពុំបានសម្រេច ឬ សហសន្តតិជនពុំអាចពិភាក្សាបាន តាមរយៈការដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការបែងចែកមត៌ក។[67] តុលាការធ្វើការបែងចែកដោយពិចារណាទៅលើលក្ខខណ្ឌមួយចំនួនដូចជា មូលដ្ឋាននៃការបែងចែក សំណងនៃកាតព្វកិច្ចរបស់មតកជន ទម្លាប់នៅក្នុងតំបន់ និងមតិលើសពីពាក់កណ្ដាល់របស់សហសន្តតិជន។[68]

ក្រោយពីមានការព្រមព្រៀងគ្នាធ្វើឡើងដោយតុលាការ ក្នុងការសម្របសម្រួលការបែងចែកចំណែកមត៌ក នោះតុលាការត្រូវធ្វើការបែងចែកទៅតាមសមាមាត្រនៃចំនួនសន្តតិជន។ ប៉ុន្តែក្នុងករណីទ្រព្យដែលជាកម្មវត្ថុនៃមត៌កមិនអាចបែងចែកបានដោយគ្មានការព្រមព្រៀង ឬ ក្នុងចំណោមសន្តតិជនដែលមានសិទ្ធិទទួលបានមត៌កមិនយល់ព្រម តុលាការអាចលក់ទ្រព្យនោះ ហើយធ្វើការបែងចែងប្រាក់ដែលទទួលបានពីការលក់តាមរបៀបនៃការលក់មត៌ក និងការបែងចែកប្រាក់ដែលទទួលបានក្រោយការលក់។ [69] នីតិវិធីនៃការលក់មត៌កនោះ

[62] មាត្រា ១២៨០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[63] មាត្រា ១២៨៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[64] មាត្រា ១២៨៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[65] មាត្រា ១២៨៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[66] មាត្រា ១២៨៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[67] មាត្រា ១២៧០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[68] មាត្រា ១២៧០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[69] មាត្រា ១២៧១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

មានដូចជាការបង្គាប់ដោយតុលាការឱ្យសហសន្តតិជនលក់តាមវិធីឡាយឡុង។[70] លើសពីនេះទៅទៀត ទ្រព្យដែលបានធ្វើលទ្ធកម្មដែលជាសិទ្ធិស្ថិតនៅក្នុងមត៌កនោះ (រាប់បញ្ចូលទាំងផលធម្មជាតិ និងផលស៊ីវិលដែលកើតឡើងពីមត៌ក) ត្រូវក្លាយជាកម្មវត្ថុនៃមត៌កផងដែរ។[71] នៅក្នុងចំណុចនេះ ទ្រព្យសម្បត្តិដែលត្រូវបានធ្វើលទ្ធកម្មចែកចេញជា ៣ គឺះ

1. **ទ្រព្យសម្បត្តិដែលបានធ្វើលទ្ធកម្មដោយផ្អែកលើសិទ្ធិនៅក្នុងមត៌ក:** គឺសំដៅទៅលើផលធម្មជាតិ ឬផលស៊ីវិល ដូចជាការប្រាក់ ឬ ប្រាក់បញ្ញើជាដើម។
2. **ទ្រព្យសម្បត្តិដែលត្រូវបានធ្វើលទ្ធកម្មដោយការសងជំនួសការបាត់បង់ ការខូចខាត ឬ ការបំពានកម្មវត្ថុមត៌ក:** សំដៅទៅលើសិទ្ធិលើបំណុលដែលអាចទាមទារសំណងនៃការខូចខាត ឬ ប្រាក់សំណងនៃការខូចខាត ក្នុងករណីដែលសហសន្តតិជនណាម្នាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ឬ តតិយជនណាមួយទទួលបន្ទុកនូវកាតព្វកិច្ចសងសំណងនៃការខូចខាតដោយការធ្វើឱ្យបាត់បង់មត៌កជាដើម។
3. **ទ្រព្យសម្បត្តិដែលត្រូវបានធ្វើលទ្ធកម្មតាមកិច្ចសន្យាដែលយកមត៌កជាកម្មវត្ថុ:** គឺសំដៅទៅលើប្រាក់ដែលបានមកពីការលក់មត៌កដោយសហសន្តតិជនទាំងអស់ ឬ ដោយតុលាការ។ ប្រាក់ទាំងអស់នេះសុទ្ធតែជាវត្ថុជំនួសមត៌ក ហើយជាភាគនៃមត៌ក ដូច្នេះអាចក្លាយជាកម្មវត្ថុនៃការបែងចែកបាន។[72]

### ២.១.៥. អានុភាពនៃការបែងចែក

ការបែងចែកមត៌កមានអានុភាពប្រតិសកម្ម គិតចាប់តាំងពីពេលដែលសន្តតិកម្មបានចាប់ផ្ដើម ប៉ុន្តែមិនអាចបំពានសិទ្ធិរបស់តតិយជនដែលបានចុះបញ្ជី ឬ មានលក្ខខណ្ឌតតាំងនោះឡើយ។[73] ហើយសហសន្តតិជនម្នាក់ៗ នឹងបានទទួលយកលិខិតបញ្ជាក់សិទ្ធិដែលទាក់ទងនឹងទ្រព្យសម្បត្តិដែលខ្លួនបានធ្វើលទ្ធកម្ម។[74] នៅពេលបានបែងចែកមត៌ក ប្រសិនបើទទួលស្គាល់នូវអានុភាពប្រតិសកម្មនេះ នោះមានន័យថាសន្តតិជននឹងទទួលមត៌កពីមតកជនផ្ទាល់ គឺមិនមែនទទួលពីសហសន្តតិជនផ្សេងទេ។ ម្យ៉ាងទៀត បើធ្វើដូច្នេះនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុ ក៏មិនចាំបាច់ឆ្លងកាត់តាមដំណាក់កាលចុះបញ្ជីនូវកម្មសិទ្ធិអវិភាគរបស់សហសន្តតិជនទេ គឺអាចជ្រើសរើសយកនីតិវិធីផ្ទេរកម្មសិទ្ធផ្ទាល់ពីមតកជន ទៅសន្តតិជនដែលបានលទ្ធកម្មដោយការបែងចែកនេះ។

[70] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្លឹះ៨-៩ មាត្រា ១២៧១ ទំ. ១៣៤
[71] មាត្រា ១២៧២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[72] សេចក្ដីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្លឹះទី៨-៩ មាត្រា ១២៧២, ទំ.១៣៥
[73] មាត្រា ១២៧៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[74] មាត្រា ១២៧៣ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ក្នុងករណីដែលអចលវត្ថុស្ថិតក្នុងស្ថានភាពកម្មសិទ្ធិអវិភាគតាមសហសន្តតិកម្ម នោះសហសន្តតិជនអាចប្រើប្រាស់ និង អាស្រ័យផលអចលនវត្ថុទាំងអស់ ដែលជាមត៌កនោះបានប៉ុន្តែមិនមែនចែកមួយភាគឱ្យសន្តតិជន A ហើយមួយភាគទៀតឱ្យសន្តតិជន B ប្រើប្រាស់ និងអាស្រ័យផលនោះឡើយ ពោលគឺសហសន្តតិជនទាំងអស់ត្រូវគ្រប់គ្រងអចលនវត្ថុទាំងអស់ដែលជាមត៌កនោះក្នុងលក្ខណៈត្រួតគ្នា។[75]ម៉្យាងទៀត ករណីដែលមត៌កស្ថិតនៅក្នុងកម្មសិទ្ធិអវិភាគ ការបែងចែករវាងសហសន្តតិជន គឺគិតតាមសមាមាត្រនៃចំណែករបស់សហសន្តតិជននោះមុនការបែងចែកមត៌ក ដោយសហសន្តតិជនអាចធ្វើអនុប្បទានចំណែករបស់ខ្លួនទៅឱ្យតតិយជនបាន ឬ ម្ចាស់បំណុលរបស់សន្តតិជនណាម្នាក់អាចរឹបអូសនូវចំណែកមត៌ករបស់សហសន្តតិជននោះបានផងដែរ។[76] ក្នុងករណីនេះច្បាប់បានបញ្ញត្តិការពារ ប្រសិនបើការទទួលស្គាល់អានុភាពប្រតិសកម្មនោះដោយគ្មានលក្ខខណ្ឌទេ វាអាចនឹងធ្វើឱ្យបាត់បង់នូវសុវត្ថិភាពក្នុងកិច្ចការជំនួញ ហេតុនេះ បានជាអានុភាពប្រតិសកម្មនៃការបែងចែកមត៌កនេះ មិនត្រូវបានទទួលស្គាល់ចំពោះតតិយជនដែលបានធ្វើនីតិវិធីចុះបញ្ជី ឬ មានលក្ខខណ្ឌតតាំងបានឡើយ។ តាមលទ្ធផលនៃការបែងចែកមត៌កអាចនឹងបាត់បង់អត្ថន័យ តែពេលនោះសហសន្តតិជនដែលបានទទួលឥទ្ធិពលដោយសារតែវត្តមានរបស់តតិយជន អាចទាមទារឱ្យសហសន្តតិជនដែលបានបង្កើតឱ្យមានមូលហេតុនេះទទួលខុសត្រូវបាន ឬ អាចលុបចោលនូវការបែងចែកមត៌កនេះ ដោយយកការភាន់ច្រឡំជាមូលហេតុ ហើយបែងចែកសារជាថ្មីឡើងវិញ។[77]

តាមលទ្ធផលនៃការបែងចែក សហសន្តតិជនដែលបានលទ្ធកម្មនូវសិទ្ធិដែលមានលិខិត ឬ ប័ណ្ណបញ្ជាក់សិទ្ធិអាចទទួលលិខិត ឬ ប័ណ្ណបញ្ជាក់សិទ្ធិនោះបាន ឧទាហរណ៍ថាសន្តតិជនដែលបានលទ្ធកម្មនូវសិទ្ធិលើប្រាក់បញ្ញើរបស់មតកជន អាចទទួលយកសៀវភៅគណនីធនាគារពីសន្តតិជនដែលបានរក្សាសៀវភៅគណនីនោះទុកបាន។

**២.១.៦. ករណីពិសេស**

ក្នុងករណីជនដែលបានក្លាយជាសន្តតិជន ដោយសារជននោះត្រូវបានទទួលស្គាល់ ក្រោយពេលមតកជនបានទទួលមរណភាពមានបំណងទាមទារបែងចែកមត៌ក បើសហសន្តតិជនផ្សេងទៀតបានបែងចែកមត៌ក ឬ បានធ្វើការចាត់ចែងផ្សេងទៀតចំពោះមត៌ក ជននោះមានសិទ្ធិទាមទារឱ្យសងត្រឹមតែតម្លៃប៉ុណ្ណោះ។[78]

---

[75] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្ថីទី៨-៩ មាត្រា ១២៧៣, ទំ.១៣៦

[76] មាត្រា ១១៤៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[77] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្ថីទី៨-៩ មាត្រា ១២៧៣, ទំ.១៣៥

[78] មាត្រា ១២៧៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ម្យ៉ាងទៀត ល័ក្ខខ័ណ្ឌតតាំងនៃការបែងចែកសិទ្ធិលើបំណុលរបស់មតកជននឹងត្រូវធ្វើការបែងចែក ទៅឱ្យសន្តតិជនទៅតាមសមាមាត្រដែលច្បាប់បានកំណត់ដោយស្វ័យប្រវត្តិ ហើយករណីមានការព្រមព្រៀងពីសំណាក់សហសន្តតិជន សិទ្ធិលើបំណុលនោះអាចយកមកធ្វើការបែងចែកជាមត៌កបានទៅតាមភាគក្រៅពីចំណែកមត៌កដែលបានកំណត់ដោយច្បាប់ ការបែងចែកមត៌កធ្វើឡើងដោយលិខិតយថាភូត ការបង្ហាញលិខិតយថាភូត ឬ ប្រគល់លិខិតចម្លងនៃលិខិតយថាភូតនេះទៅកូនបំណុលបាន ដើម្បីទទួលបានលក្ខខណ្ឌតតាំងចំពោះកូនបំណុលនៃមតកជន។ [79] ហើយកូនបំណុលនៃមតកជន ដែលបានសងសំណងតាមចំណែកដែលបានកំណត់ដោយច្បាប់ចំពោះសហសន្តតិជន នៅមុនពេលបានទទួលដំណឹង អាចតតាំងចំពោះសហសន្តតិជនដែលបានធ្វើលទ្ធកម្មលើបំណុលតាមការបែងចែកមត៌កនោះបាន។ [80] មួយវិញទៀតសហសន្តតិជនម្នាក់ៗត្រូវទទួលខុសត្រូវទៅតាមសមាមាត្រនៃចំណែកមត៌ក ដូចជាអ្នកលក់ចំពោះសហសន្តតិជនដទៃទៀត។[81]

## ២.២. ការយល់ព្រម និងការបោះបង់សន្តតិកម្ម

សន្តតិជនត្រូវធ្វើការយល់ព្រម ឬ បោះបង់សន្តតិកម្មទាំងស្រុង ឬ ដោយមានកម្រិតក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម ដោយអំឡុងពេលនេះអាចពន្យារពេលបានតាមរយៈការពាក្យសុំទៅតុលាការ ដើម្បីទុកលទ្ធភាពឱ្យសន្តតិជនធ្វើការស្រាវជ្រាវមត៌កនៅមុនពេលបង្ហាញឆន្ទៈយល់ព្រម ឬ បោះបង់។[82] ចំពោះតុលាការដែលទទួលបានពាក្យសុំនេះ ត្រូវធ្វើការកំណត់អំឡុងពេលដែលត្រូវពន្យារនេះដោយវិនិច្ឆ័យទៅតាមចំនួន ឬ គុណភាពនៃមត៌ក ឬ កាតព្វកិច្ចដែលទទួលបានដោយសន្តតិកម្មជាអាទិ៍។

ដោយឡែកករណីពិសេសនៃអំឡុងពេល បើសន្តតិជនបានទទួលមរណភាពមុនពេលធ្វើការយល់ព្រម ឬ បោះបង់នៅក្នុងអំឡុងពេលដែលបានកំណត់ដោយច្បាប់ ការគណនាអំឡុងពេលត្រូវគិតចាប់ពីពេលដែលសន្តតិជនរបស់សន្តតិជននោះបានដឹងថាសន្តតិកម្មចាប់ផ្តើមចំពោះខ្លួន។ [83] មួយវិញទៀតបើសន្តតិជនជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលដែលមានកំណត់នៅក្នុងច្បាប់ត្រូវគណនាដោយគិតចាប់ពីពេលអ្នកតំណាងដែលច្បាប់បានកំណត់នោះបានដឹងថាសន្តតិកម្មចំពោះជនដែលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅចាប់ផ្តើម មានន័យថាប្រសិនបើសន្តតិជនជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ

[79] មាត្រា ១២៧៥ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[80] មាត្រា ១២៧៥ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[81] មាត្រា ១២៧៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[82] មាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[83] មាត្រា ១២៤៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ការយល់ព្រម ឬ បោះបង់សន្តតិកម្មចាំបាច់ត្រូវឱ្យអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលទូទៅធ្វើការសម្រេចដើម្បីសាមីខ្លួន។[84]

ម្យ៉ាងវិញទៀតជាគោលការណ៍ ការយល់ព្រម ឬ ការបោះបង់សន្តតិកម្មមិនអាចលុបចោលបានឡើយ ដោយហេតុថាការបោះបង់ ឬ ការយល់ព្រមមានឥទ្ធិពលយ៉ាងខ្លាំងលើផលប្រយោជន៍របស់បុគ្គលពាក់ព័ន្ធដូចជា សន្តតិជន ឬ ម្ចាស់បំណុលរបស់មតកជនជាអាទិ៍ លើកលែងតែមានអត្ថិភាពនៃវិការៈក្នុងការបង្ហាញឆន្ទៈ។ ប្រសិនបើមានវិការៈនៃការបង្ហាញឆន្ទៈ សិទ្ធិនេះត្រូវធ្វើឡើងនៅក្នុងអំឡុងពេល ០៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិ ឬ នៅក្នុងអំឡុងពេល ០៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្មតាម រយៈការដាក់ពាក្យសុំទៅតុលាការ។[85] ក្នុងករណីសន្តតិជនមិនទាន់បានយល់ព្រម ឬ បោះបង់សន្តតិកម្ម ឬ អ្នកទទួលបន្តនៃសន្តតិកម្មមិនទាន់មានភាពច្បាស់លាស់ ក្នុងករណីម្ចាស់បំណុលរបស់មតកជនមានឆន្ទៈធ្វើបណ្តឹង ជាបឋមត្រូវទាមទារឱ្យជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្នសិន ទើបអាចចាប់ផ្តើមសកម្មភាពបណ្តឹងបានចំពោះអ្នកគ្រប់គ្រងនោះ។ ករណីមតកជនបានទទួលមរណភាពស្របពេលមានបណ្តឹងកំពុងចាត់ការ នោះនីតិវិធីបណ្តឹងត្រូវផ្អាករហូតដល់សន្តតិជនយល់ព្រមទទួលសន្តតិកម្មបន្ត ឬ ម្ចាស់បំណុលនៃមតកជននោះអាចទាមទារឱ្យមានអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្នសិន ប្រសិនបើចង់ឱ្យនីតិវិធីបណ្តឹងនោះមានភាពឆាប់រហ័ស។

### ២.២.១. ការយល់ព្រមទទួលសន្តតិកម្ម

ការយល់ព្រមទទួលបន្តនូវសន្តតិកម្ម គឺជាការយល់ព្រមទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចបន្តពីមតកជនក្នុងករណីសន្តតិជនបានយល់ព្រមទាំងស្រុង គឺសន្តតិជនត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជននោះ។[86] ការយល់ព្រមបែងចែកជា២ គឺការយល់ព្រមទាំងស្រុង និងការយល់ព្រមមានកម្រិត។

#### ២.២.១.១. ការយល់ព្រមទាំងស្រុង

ការយល់ព្រមទាំងស្រុង មានន័យថាសន្តតិជនត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន ដោយតម្រូវឱ្យបង្ហាញឆន្ទៈគឺគ្រប់គ្រាន់ហើយ ពោលមិនចាំបាច់ដាក់ពាក្យសុំទៅតុលាការនោះទេ។ ចំពោះ ការយល់ព្រមមានកម្រិត និងការបោះបង់ចោលសន្តតិកម្ម គឺតម្រូវឱ្យមានការដាក់ពាក្យសុំទៅតុលាការ។

[84] មាត្រា ១២៥០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[85] មាត្រា ១២៥២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[86] មាត្រា ១២៥៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ក្នុងករណីដែល សន្តតិជនបានធ្វើសកម្មភាពណាមួយក្នុងចំណោមសកម្មភាពខាងក្រោម ត្រូវចាត់ទុកថាសន្តតិជនបានយល់ព្រមទាំងស្រុង៖

- សន្តតិជនបានចាត់ចែងមត៌កនោះទាំងអស់ ឬ មួយភាគ។ ប៉ុន្តែលើកលែងចំពោះសកម្មភាពរក្សា និងសកម្មភាពត្រឹមតែជាការគ្រប់គ្រង។
- សន្តតិជនមិនបានយល់ព្រមដោយមានកម្រិត ឬ បោះបង់ នៅក្នុងអំឡុងពេល ០៣ (បី) ខែ គិតចាប់ពីថ្ងៃដែលបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្ដើម លើកលែងតែសុំពន្យារពេលទៅតុលាការ
- ទោះបីជាសន្តតិជនបានយល់ព្រមដោយមានកម្រិត ឬ បោះបង់ក៏ដោយ បើសន្តតិជនបានលាក់មត៌កទាំងអស់ ឬ មួយភាគ ឬ បានប្រើប្រាស់មត៌កនោះដើម្បីខ្លួន។ លើកលែងតែនៅពេលក្រោយដែលជនដែលបានក្លាយជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម។[87]

### ២.២.១.២. ការយល់ព្រមមានកម្រិត

ការយល់ព្រមដោយមានកម្រិត គឺជាករណីដែលសន្តតិជនយល់ព្រមដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និងអច្ច័យទានរបស់មតកជនត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម មានន័យថាសន្តតិជនក្លាយទៅជាកូនបំណុលដោយទទួលបន្ទុកនូវសន្តតិកម្មនៃកាតព្វកិច្ចទាំងអស់របស់មតកជន ប៉ុន្តែសន្តតិជនអាចកម្រិតការទទួលខុសត្រូវបានត្រឹមកម្រិតនៃមត៌ក លើកលែងតែសន្តតិជនយល់ព្រមសងកាតព្វកិច្ចដោយស្មគ្រ័ចិត្ត។[88] មួយវិញទៀតក្នុងករណីមានសហសន្តតិកម្ម ការយល់ព្រមដោយមានកម្រិតត្រូវធ្វើឡើងរួមទាំងអស់គ្នា ហើយចាំបាច់ត្រូវមាននីតិវិធីជម្រះបញ្ជី ដើម្បីឱ្យមានសមភាពក្នុងការសងចំពោះម្ចាស់បំណុលរបស់មតកជន សហសន្តតិជនត្រូវឯកភាពគ្នាក្នុងការសងនោះ។ ដោយហេតុថាប្រសិនបើមានតែសន្តតិជនមួយចំនួនបានយល់ព្រមទាំងស្រុង ហើយបានអះអាងនូវចំណែកមត៌កនោះ ការជម្រះបញ្ជីនូវមត៌កទាំងអស់អាចធ្វើទៅបាន ប៉ុន្តែគ្មានដំណើរការល្អទេ។[89] ប្រសិនបើសន្តតិជនមួយចំនួនបោះបង់សន្តតិកម្មនោះគ្មានបញ្ហានោះទេ ព្រោះជនដែលបានបោះបង់សន្តតិកម្មត្រូវចាត់ទុកថាមិនមែនជាសន្តតិជនតាំងពីដំបូង ហេតុនេះសន្តតិជនដែលនៅសល់អាចយល់ព្រមដោយមានកម្រិតរួមគ្នាបាន។ លើកលែងតែសន្តតិជនមួយចំនួនក្នុងចំណោមសន្តតិជនដែលយល់ព្រមដោយមានកម្រិត ដោយមានហេតុផលដូចមានកំណត់នៅក្នុងមាត្រា ១២៥៩ (ការយល់ព្រមដោយមានកម្រិត

[87] មាត្រា ១២៥៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[88] មាត្រា ១២៥៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[89] មាត្រា ១២៥៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

កើតឡើងមុនការយល់ព្រមតាមច្បាប់) ជាហេតុនាំឱ្យត្រូវទទួលខុសត្រូវដូចគ្នានឹងការយល់ព្រមទាំងស្រុង និង ប្រសិនបើមានស្ថានភាពបែបនេះមែន មត៌កទាំងអស់ត្រូវឆ្លងកាត់តាមនីតិវិធីជម្រះបញ្ជី។ ដូច្នេះសន្តតិជនដែលត្រូវទទួលខុសត្រូវតាមមាត្រា ១២៥៨ មិនអាចអះអាងថាខ្លួនមានចំណែកមត៌កសកម្ម ខណៈពេលដែលមិនទាន់បញ្ចប់នីតិវិធីនៃការជម្រះបញ្ជីឡើយ។ លើសពីនេះទៅទៀតដើម្បីធ្វើការយល់ព្រមដោយមានកម្រិតចំពោះសន្តតិកម្មដែលកើតមានឡើងចំពោះខ្លួន (សន្តតិជន) ត្រូវធ្វើតាមរបៀបដែលមានកំណត់ដូចខាងក្រោម៖

**ក. វិធី**

ដើម្បីធ្វើការយល់ព្រមដោយមានកម្រិតសន្តតិជនត្រូវដាក់ពាក្យសុំទៅតុលាការក្នុងអំឡុងពេល ០៣(បី) ខែ គិតចាប់ពីថ្ងៃដែលដឹងថាសន្តតិកម្មចាប់ផ្តើមចំពោះខ្លួន ប៉ុន្តែអំឡុងពេលនេះអាចពន្យារពេលដោយមានការអនុញ្ញាតពីតុលាការតាមរយៈពាក្យសុំរបស់សាមីខ្លួន។[90] មួយវិញទៀត ក្នុងករណីសហសន្តតិជនទាំងអស់ដាក់ពាក្យសុំទៅតុលាការដើម្បីធ្វើការយល់ព្រមដោយមានកម្រិត ការគណនាអំឡុងពេលត្រូវគិតចាប់ពីថ្ងៃសន្តតិជនបានដឹងអំពីការចាប់ផ្តើមសន្តតិកម្មក្រោយគេ។ នាពេលដាក់ពាក្យសុំទៅតុលាការ សន្តតិជនត្រូវដាក់បញ្ជីសារពើភ័ណ្ឌនៃមត៌ក ដោយបញ្ជាក់អំពីមត៌កសកម្ម និងមត៌កអកម្មដែលសន្តតិជនបានទទួល នាពេលចាប់ផ្តើមសន្តតិកម្ម ក្នុងកម្រិតលទ្ធភាពដែលខ្លួនបានដឹង។ ករណីមិនបានបញ្ជាក់ឱ្យច្បាស់លាស់ដោយចេតនាត្រូវចាត់ទុកថា “យល់ព្រមទាំងស្រុង”។

**ខ. អានុភាព**

អានុភាពនៃការយល់ព្រមដោយកម្រិត មានខ្លឹមសារថាម្ចាស់បំណុលរបស់មតកជនមិនអាចទាមទារឱ្យសន្តតិជនទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជនបានឡើយ។ ទោះបីជាដូច្នេះក៏ដោយតាមគោលការណ៍មត៌កត្រូវធ្លាក់ទៅលើសន្តតិជន ប៉ុន្តែជាលក្ខណៈសារធាតុទ្រព្យសម្បត្តិជាមត៌កត្រូវធ្វើការជម្រះបញ្ជីផ្សេងៗពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន ហេតុនេះសិទ្ធិលើបំណុល និងកាតព្វកិច្ចរបស់សន្តតិជន និងមតកជនមិនអាចរលត់ដោយព្យាកុលភាព[91]នោះទេ។[92]

### ២.២.២. ការបោះបង់សន្តតិកម្ម

ក្នុងករណីដែលសន្តតិជនមានឆន្ទៈបោះបង់ចោលចំណែកមត៌ករបស់ខ្លួន សន្តតិជនរូបនោះត្រូវដាក់ពាក្យស្នើសុំទៅកាន់តុលាការមិនឱ្យលើសអំឡុងពេល ០៣ (បី) ខែឡើយ ដោយគិតចាប់ពីពេលដែលដឹងអំពី

[90] មាត្រា ១២៥៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[91] សទ្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ លេខ១១០, ទំ.១៥

[92] មាត្រា ១២៥៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ពេលវេលានៃការចាប់ផ្តើមសន្តតិកម្ម។[93] បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថាបុគ្គលនោះមិនមែនជាសន្តតិជនទាំងពីដំបូងមកម្លេះ។ [94] ក្នុងចំណោមសហសន្តតិជន ប្រសិនបើមានជនមួយចំនួនបានបោះបង់សន្តតិកម្ម សន្តតិជនផ្សេងទៀតជាអ្នកទទួលសន្តតិកម្មបន្ត។ អ្នកដែលមានលំដាប់បន្ទាប់អាចទទួលសន្តតិកម្មបាន លុះត្រាតែសហសន្តតិជនលំដាប់មុនទាំងអស់បានបោះបង់។

## ២.៣. ការបែងចែកមត៌កតាមលំដាប់សន្តតិជន

ក្រោយពីបានសិក្សាអំពីលំដាប់នៃសន្តតិជននៅក្នុងជំពូកទី ១ រួចមក យើងនឹងសិក្សាទាក់ទងនឹងការបែងចែកចំណែកមត៌កតាមលំដាប់សន្តតិជន នៅក្នុងចំណុចនេះយើងធ្វើការបែងចែកជា ២ ចំណុចគឺ ២.៣.១ ករណីមានសន្តតិជនប៉ុន្តែគ្មានសន្តតិជនជានិច្ច និង២.៣.២ ករណីមានសន្តតិជន និងសន្តតិជនជានិច្ច។

### ២.៣.១. ករណីមានសន្តតិជនប៉ុន្តែគ្មានសន្តតិជនជានិច្ច

ក្នុងករណីនេះ មត៌កទាំងអស់ត្រូវបានបែងចែកត្រឹមកម្រិតនៃថ្នាក់ញាតិរបស់មតកជនតែប៉ុណ្ណោះ ដែលត្រូវទទួលបានទៅតាមលំដាប់នៃសន្តតិជនដែលច្បាប់បានកំណត់ ដែលរួមមាន បច្ឆាញាតិ (សន្តតិជនលំដាប់ទី ១) បុព្វញាតិ (សន្តតិជនលំដាប់ទី២) និងសាខាញាតិ(សន្តតិជនលំដាប់ទី ៣)។

#### ក. សន្តតិជនលំដាប់ទី១

ក្នុងករណីនេះសន្តតិជនលំដាប់ទី១ គឺជាបច្ឆាញាតិខ្សែផ្ទាល់ (កូន) របស់មតកជនត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា។ ក្នុងករណីកូនមានតែម្នាក់ គឺមិនចាំបាច់ធ្វើការបែងចែកទេ ប៉ុន្តែបើសិនជាមានច្រើននាក់ត្រូវបែកចែកស្មើៗគ្នាតាមចំនួនសន្តតិជន។ បច្ឆាញាតិផ្ទាល់(កូនបង្កើត) កូនសុំធម្មតា ឬ កូនសុំពេញលេញ គឺទទួលបានចំណែក មត៌កស្មើគ្នា លើសពីនេះទៅទៀតកូនក្រៅចំណងអាពាហ៍ពិពាហ៍ក៏ត្រូវទទួលបានចំណែកមត៌កស្មើគ្នាទៅនឹងកូនកើតដោយមានចំណងអាពាហ៍ពិពាហ៍ដែរ។[95]

រូបមន្តនៃការគណនាចំណែកមត៌ករបស់សន្តតិជននីមួយៗ យើងត្រូវយក មត៌កសរុបចែកនឹងចំនួនសន្តតិជនដែលមាន។[96]

**ចំណែកមត៌ករបស់សន្តតិជននីមួយៗ = មតកសរុប ÷ ចំនួនសន្តតិជនសរុប**

[93] មាត្រា ១២៦០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[94] មាត្រា ១២៦១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[95] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្លឹ៨-ទី៩ មាត្រា ១១៥៦, ទំ.១៤

[96] មាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

**ឧទាហរណ៍ទី១៖** មតកជនមានកូនបង្កើតចំនួន ៣នាក់ គឺ **ក**, **ខ**, និង **គ** ព្រមទាំងកូនស្មុំ ២នាក់ **X** និង **Y**។ ដោយកូនរបស់មតកជនមានចំនួន ៥ (ប្រាំ) នាក់ នោះកូនម្នាក់ៗទទួលបាន ១/៥ (មួយភាគប្រាំ) នៃចំណែកមត៌កសរុបទាំងអស់។




**ឧទាហរណ៍ទី២៖** មតកជនមានកូនបង្កើតចំនួន ៣នាក់ គឺ **ក**, **ខ** និង**គ** កូនស្មុំ ២នាក់ **X** និង **Y**។ នាពេលបើកសន្តតិកម្ម **គ** បានស្លាប់ ហើយ **គ** មានកូនចំនួន ២នាក់គឺ **គ១** និង **គ២**។ ចំណែកឯ **Y** គឺជាអភ័ព្វបុគ្គល ហើយមានកូនចំនួន ៣នាក់ គឺ **Y១, Y២ និង Y៣**។ ក្នុងករណីនេះយើងឃើញថា **គ** និង **Y** មិនអាចទទួលបានចំណែកមត៌កទេ។ ដោយយកគោលការណ៍សន្តតិជនជំនួសមកអនុវត្ត ដូចនេះកូនរបស់សន្តតិជនដែលបានទទួលមរណភាព និងអភ័ព្វបុគ្គល អាចក្លាយជាសន្តតិជនជំនួសបាន[97] ដូចនេះសន្តតិជនដែលត្រូវទទួលបានចំណែកមត៌កមានដូចជា៖

- ចំណែករបស់ **ក**, **ខ** និង **X** ទទួលបាន ១/៥
- ចំណែករបស់ **គ១** និង **គ២** ទទួលបាន ១/១០ (ដោយធ្វើការបែងចែកចំណែករបស់ **គ** ១/៥ ជា ២ ចំណែកឱ្យទៅ **គ១** និង **គ២**)។
- ចំណែករបស់ **Y១, Y២ និង Y៣** ទទួលបាន ១/១៥ (ដោយធ្វើការបែងចែកចំណែករបស់ **Y** ១/៥ ជា ៣ ចំណែកឱ្យទៅ **Y១, Y២ និង Y៣**)។

[97] មាត្រា ១១៥៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧




**ខ. សន្តតិជនលំដាប់ទី២**

ករណីមតកជនពុំមានបច្ឆាញាតិផ្ទាល់ទេ នោះបុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជនលំដាប់ទី២។[98] ច្បាប់បានកំណត់យកបុព្វញាតិផ្ទាល់ដែលមានលំដាប់ជិតជាងគេរបស់មតកជន ពោលគឺ ឪពុកម្តាយ។ ករណីមតកជនមានឪពុកម្តាយច្រើននាក់ (ឪពុកម្តាយចិញ្ចឹម) នោះចំណែកមត៌កត្រូវបែងចែកស្មើៗគ្នាទៅតាមចំនួននៃសន្តតិជនជាក់ស្តែង។[99] ករណីមតកជនមិនមាន ឪពុកម្តាយទេ នោះជីដូនជីតានឹងក្លាយជាសន្តតិជនបន្តដោយទទួលបាននូវចំណែកមត៌កស្មើៗគ្នា។

**ឧទាហរណ៍ទី១៖** មតកជនគ្មានកូន មានតែឪពុកម្តាយ។ នៅពេលបើកសន្តតិកម្ម នោះឪពុកម្តាយនឹងក្លាយជាសន្តតិជន ដែលត្រូវបានចំណែកមត៌កស្មើៗគ្នា គឺក្នុងម្នាក់ៗទទួលបាន ១/២ (មួយភាគពីរ) នៃចំណែកមត៌កសរុប។




**ឧទាហរណ៍ទី២៖** មតកជនមិនមានបុព្វញាតិថ្នាក់ទី ១ (ឪពុកម្តាយបានស្លាប់) នោះចំណែកមត៌កត្រូវធ្លាក់ទៅលើ ជីដូនជីតាខាងឪពុក និងជីដូនជីតាខាងម្តាយ។ ករណីជីតាខាងឪពុកបានទទួលមរណភាព ក្នុងករណីនេះសន្តតិជនលំដាប់ទី២ គឺ មានចំនួន ៣នាក់ គឺ ជីដូនខាងឪពុក, ជីដូនខាងម្តាយ និងជីតាខាងម្តាយ ដោយម្នាក់ៗទទួលបានចំណែកមត៌កស្មើៗគ្នា គឺ ក្នុងម្នាក់ទទួលបានចំណែក ១/៣ (មួយភាគបី)។

[98] មាត្រា ១១៥៩ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[99] មាត្រា ១១៥៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧




**ឧទាហរណ៍ទី៣៖** មតកជនជាកូនសុំធម៌តា នោះមតកជនមានញាតិខាងឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹមផង ព្រោះកូនសុំធម៌តាញាតិលោហិតគឺមិនបានផ្តាច់ចេញនោះទេ។ សន្តតិជនដែលទទួលបានចំណែកមត៌កគឺ ម្នាក់ទទួលបាន ១/៤ (មួយភាគបួន) នៃចំណែកមត៌ក ពោលគឺ ឪពុកបង្កើតបានចំណែក ១/៤ (មួយភាគបួន) ម្តាយបង្កើតបានចំណែក ១/៤ (មួយភាគបួន) ឪពុកចិញ្ចឹមបានចំណែក ១/៤ (មួយភាគបួន) និងម្តាយចិញ្ចឹមបានចំណែក ១/៤ (មួយភាគបួន)។




### គ. សន្តតិជនលំដាប់ទី៣

ករណីមតកជនមិនមានបច្ឆាញាតិ និងបុព្វញាតិក្នុងការទទួលសន្តតិកម្មទេ នោះក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានកំណត់យកបងប្អូនបង្កើតជាសន្តតិជន (សន្តតិជនលំដាប់ទី ៣)។ បើបងប្អូនបង្កើតមានចំនួនច្រើននាក់នោះចំណែកមត៌កត្រូវចែកឱ្យស្មើៗគ្នា ប៉ុន្តែក្នុងករណីដែលបងប្អូនបង្កើតដែលមានតែឪពុក ឬ ម្តាយរួមតែម្ខាង នោះបងប្អូនបង្កើតត្រូវទទួលបាននូវចំណែកមត៌ក ១/២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុកម្តាយរួម។[100]

**ឧទាហរណ៍៖** លោក **ក** បានទទួលមរណភាពដោយគ្មានបច្ឆាញាតិ និងបុព្វញាតិ ប៉ុន្តែគាត់មានបងប្អូនបង្កើតចំនួន ២នាក់ គឺ **ខ** និង **គ**។ ដោយ **ខ** គឺជាបងប្អូនបង្កើតដែលមានឪពុកម្តាយបង្កើតរួមគ្នា ចំណែកឯ

[100] មាត្រា ១១៦០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

**គ** គឺជាបងប្អូនបង្កើតដែលមានម្ដាយរួមតែម្ខាងជាមួយមតកជន **ក**។ នាពេលចាប់ផ្ដើមសន្តតិកម្មចំណែកមត៌ករបស់ **គ** ដែលជាបងប្អូនបង្កើតដែលមានឪពុកខុសគ្នា ប៉ុន្តែមានម្ដាយរួមគ្នាជាមួយមតកជនទទួលបាន ១/២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុកម្ដាយដូចគ្នា។ យើងអាចគណនាបានថា៖

- **ខ** ទទួលបានចំណែក ២/៣ នៃចំណែកមត៌ក
- **គ** ទទួលបានចំណែក ១/៣ នៃចំណែកមត៌ក




**២.៣.២. ករណីមានសន្តតិជន និងសន្តតិជនជានិច្ច**

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានបញ្ញត្តិអំពីសិទ្ធិរបស់សហព័ទ្ធក្នុងការទទួលបានសន្តតិកម្មដោយកំណត់យកសហព័ទ្ធជាសន្តតិជនជានិច្ច មានន័យថាទោះបីជាគាត់ស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ គាត់នៅតែមានសិទ្ធិក្នុងការប្រកួតប្រជែងជាមួយសន្តតិជនទាំង៣លំដាប់ខាងលើ។ មួយវិញទៀតបើទោះបីជាគ្មានសន្តតិជនទាំង៣លំដាប់ខាងលើក៏ដោយ សហព័ទ្ធនៅតែទទួលបានចំណែកមត៌កជានិច្ចដោយចូលរួមមកទទួលចំណែកមត៌ករបស់មតកជន[101] ពោលគឺសហព័ទ្ធគាត់ មិនស្ថិតនៅក្នុងលំដាប់សន្តតិជនណាមួយឡើយ។ លើកលែងតែសហព័ទ្ធនោះជា អភ័ព្វបុគ្គល ឬ ជនដែលបានផ្ដាច់ចេញពីមត៌ក។

**ក. សហព័ទ្ធ និងសន្តតិជនលំដាប់ទី១**

ករណីមតកជនមានសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់ដែលជាសន្តតិជន នោះសហព័ទ្ធនឹងធ្វើចូលរួមបែងចែកជាមួយបច្ឆាញាតិផ្ទាល់ (កូន) របស់មតកជន ដោយបែងចែកនូវចំណែកមត៌កស្មើៗគ្នា។[102]

**ឧទាហរណ៍ទី១៖** មតកជន **ក** មានសហព័ទ្ធ **ខ** និងមានកូនចំនួន ៣នាក់ X, Y និង Z។ នៅពេលចាប់ផ្ដើមសន្តតិកម្មជនដែលអាចក្លាយជាសន្តតិជនរួមមាន ខ, X, Y និង Z ដែលនឹងត្រូវទទួលបានចំណែកស្មើៗ

[101] មាត្រា ១១៦១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[102] មាត្រា ១១៦២ ចំណុច ក នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

គ្នា។ ដោយ ខ ជាសហព័ទ្ធ នឹងត្រូវមកចូលរួមបែងចែកជាមួយបច្ឆាញាតិរបស់មតកជន(កូន) ដូចនេះម្នាក់ៗត្រូវទទួលបានចំណែកស្មើៗគ្នាគឺ ១/៤ (មួយភាគបួន) នៃចំណែកមត៌កសរុប។




**ឧទាហរណ៍ទី២៖** ដូចគ្នានឹងឧទាហរណ៍ខាងលើដែរ បើសិនជា X ស្លាប់ ហើយមានកូនចំនួន ៣នាក់ ហើយ Z បានក្លាយជាអភ័ព្វបុគ្គល ហើយមានកូនចំនួន១នាក់។ ក្នុងករណីនេះ សន្តតិជនម្នាក់ៗត្រូវទទួលបានចំណែកមត៌កដូចខាងក្រោម៖

- **ខ** ជាសហព័ទ្ធ (សន្តតិជនជានិច្ច) ទទួលបាន ១/៤ (មួយភាគបួន)
- ចំណែកមត៌ករបស់ X (១/៤) នឹងត្រូវធ្លាក់ទៅលើកូនរបស់ X (សន្តតិជនជំនួស) គឺ **X១, X២ និងX៣** នោះចំណែកមត៌ករបស់កូន X គឺម្នាក់ៗទទួលបាន ១/១២ ស្មើៗគ្នា
- Y ជាបច្ឆាញាតិ (កូន) របស់មតកជនទទួលបាន ១/៤ (មួយភាគបួន)
- ចំណែកមត៌ករបស់ Z (១/៤) នឹងត្រូវធ្លាក់ទៅលើកូនរបស់ Z (សន្តតិជនជំនួស) គឺ **Z១** ដោយសន្តតិជនជំនួសមានតែម្នាក់នោះចំណែកមត៌ករបស់ Z គឺត្រូវធ្លាក់ទៅលើ **Z១** ទាំងអស់ គឺទទួលបាន ១/៤ (មួយភាគបួន)។



### ខ. សហព័ន្ធ និងសន្តតិជនលំដាប់ទី២

ប្រសិនបើមានសហព័ទ្ធ និងបុព្វញាតិរបស់មតកជនជាសន្តតិជន នោះក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានកំណត់ថាសហព័ទ្ធទទួលបាន ១/៣ (មួយភាគបី) ឯចំណែកឪពុក១/៣ (មួយភាគបី) ម្ដាយវិញទទួលបាន ១/៣ (មួយភាគបី) ។[103] ប៉ុន្តែបើមតកជនមានឪពុក ឬ ម្ដាយតែម្ខាងដែលនៅរស់ នោះចំណែកមត៌កត្រូវបែងចែកត្រឹមចំនួនសហព័ទ្ធ និងឪពុក ឬ ម្ដាយដែលនៅរស់តែប៉ុណ្ណោះ ពោលគឺសហព័ទ្ធទទួលបាន ១/២ (មួយភាគពីរ) និងឪពុក ឬ ម្ដាយទទួលបាន ១/២ (មួយភាគពីរ) ដូចគ្នា។ ប៉ុន្តែបើក្នុងករណីមាន ឪពុកម្ដាយច្រើននាក់ ក៏សហព័ទ្ធនៅតែទទួលបាន ១/៣ (មួយភាគបី) ។

**ឧទាហរណ៍១៖** មតកជន **ក** មានសហព័ទ្ធឈ្មោះ **ខ** មានឪពុក **X** និងម្ដាយ **Y** ប៉ុន្តែមិនមានបច្ឆាញាតិ (កូន)។ ក្នុងករណីនេះ **ខ** ត្រូវទទួលបានចំណែក ១/៣ (មួយភាគបី) នៃចំណែកមត៌កសរុប ហើយចំណែក ២/៣ (ពីរភាគបី) ទៀត គឺជាចំណែករបស់ ឪពុក **X** និងម្ដាយ **Y** ដែលម្នាក់ៗទទួលបានចំណែក ១/៣ (មួយភាគបី) នៃចំណែកមត៌កសរុប។




ក្នុងករណីដែលមតកជនមិនមានឪពុកម្ដាយ និងមិនមានបងប្អូនបង្កើតជាសន្តតិជននោះ ជីដូនជីតារបស់មតកជននឹងត្រូវទទួលបានចំណែកបន្ត ដោយសហព័ទ្ធរបស់មតកជនត្រូវទទួលបានចំណែកមត៌ក ១/២ (មួយភាគពីរ) នៃចំណែកមត៌កទាំងអស់ ហើយជីដូនជីតាត្រូវទទួលបានចំណែក ១/២ (មួយភាគពីរ) ដែរ ប្រសិនបើជីដូនជីតា មានចំនួនច្រើននាក់នោះត្រូវទទួលបានចំណែកស្មើៗគ្នា។

**ឧទាហរណ៍២៖** មតកជន **ក** មានសហព័ទ្ធ **ខ** នឹងមានជីដូនជីតាខាងឪពុក (ជីដូន **X** និងជីតា **Y**) និងជីដូនជីតាខាងម្ដាយ (ជីដូន **A** និងជីតា **B**) ។ ចំណែកមត៌ករបស់សហព័ទ្ធ (សន្តតិជនជានិច្ច) **ខ** ត្រូវទទួលបាន ១/២ (មួយភាគពីរ) ចំណែកឯជីដូនជីតាគឺទទួលបាន ១/២ (មួយភាគពីរ) ដូចគ្នា ប៉ុន្តែត្រូវបែងចែកជា ៤ ចំណែកទៅតាមចំនួន ជីដូនជីតាដែលនៅមានជីវិត ដូចនេះម្នាក់ៗទទួលបាន ១/៨ (មួយភាគប្រាំបី) ស្មើៗគ្នា។

[103] មាត្រា ១១៦២ ចំណុច ខ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧




### គ. សហព័ទ្ធ និងសន្តតិជនលំដាប់ទី៣

ប្រសិនបើមតកជនមានតែបងប្អូនបង្កើត និងសហព័ទ្ធ មិនមានបុព្វញាតិ និងបច្ឆាញាតិនោះចំណែកមត៌ករបស់សហព័ទ្ធគឺ ១/២ (មួយភាគពីរ) ចំណែកឯមត៌ករបស់សហសន្តតិជនខាងលើគឺ១/២ (មួយភាគពីរ) ត្រូវយកមកចែកឱ្យសហសន្តតិជនលំដាប់ទី៣ឱ្យស្មើៗគ្នា។[104] ក្នុងករណីសន្តតិជនលំដាប់ទី៣នេះ គោលការណ៍សន្តតិជនជំនួសត្រូវបានយកមកអនុវត្ត បានន័យថាបើសិនជាបងប្អូនបង្កើតនោះបានទទួលមរណភាព ឬ ជាអភ័ព្វបុគ្គល ឬ ជនដែលត្រូវបានផ្តាច់ចេញពីសន្តតិជន ដូចនេះកូនរបស់ជននោះនឹងក្លាយជាសន្តតិជនជំនួសបានត្រឹមតែមួយតំណាប៉ុណ្ណោះ។[105]

**ឧទាហរណ៍៖** មតកជន **ក** មានសហព័ទ្ធ **ខ** និងមានបងប្អូនបង្កើតឪពុកម្តាយរួមគ្នា A, B និង C ហើយមានបងប្អូនបង្កើតឪពុករួមចំនួន ២នាក់ គឺ M និង N និងមានបងប្អូនបង្កើតរួមម្តាយ ២នាក់គឺ Y និងZ។ នៅពេលបើកសន្តតិកម្មសហព័ទ្ធ **ខ** ទទួលបាន ១/២ (មួយភាគពីរ) នៃចំណែកមត៌កសរុប។ ចំណែកដែលនៅសល់គឺ ១/២ (មួយភាគពីរ) ត្រូវបែងចែកទៅឱ្យបងប្អូនរបស់មតកជននោះ ដោយធ្វើការបែងចែកដូចខាងក្រោម៖

- ចំណែកមត៌កដែលនៅសល់សរុប ១/២ (មួយភាគពីរ) ត្រូវបែងចែកទៅបងប្អូនបង្កើតដែលមានឪពុកម្តាយរួមស្មើៗគ្នា និងបែងចែកទៅបងប្អូនបង្កើតដែលមានតែឪពុក ឬ ម្តាយតែម្ខាង ពាក់កណ្តាលនៃចំណែករបស់បងប្អូនបង្កើតដែលមានឪពុកម្តាយរួមគ្នា។
- តាង X ជាចំណែកសន្តតិជននីមួយៗ៖

  ចំណែកមត៌កនៅសល់សរុប ១/២ = A + B + C + M + N + Y + Z

[104] មាត្រា ១១៦២ ចំណុច គ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[105] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្ថីទី៨-ទី៩, មាត្រា១១៦០, ទំ.១៩

- ដោយ **M, N, Y** និង**Z** មានឪពុក ឬ ម្តាយរួមតែម្ខាង នោះចំណែកមត៌កត្រូវទទួលបានពាក់កណ្តាលនៃ **A, B** និង **C** ដោយ **M = N = Y= Z = ១/២ (A) = ១/២ (B) = ១/២ (C)**

  គេបាន **១/២ = X + X + X + ១/២X + ១/២X + ១/២X + ១/២X**

  **=> ១/២ = ៥X**

  **=> X = ១/១០**

  ដូចនេះពួកគេម្នាក់ៗទទួលបានចំណែកមត៌កដូចខាងក្រោម៖

  - ចំណែកមត៌ករបស់បងប្អូនបង្កើតឪពុកម្តាយរួម **A, B** និង **C** ម្នាក់ៗទទួលបាន ១/១០ (មួយភាគដប់) នៃចំណែកមត៌កសរុប
  - ចំណែកមត៌ករបស់បងប្អូនរួមឪពុក **M** និង **N** ម្នាក់ៗទទួលបាន ១/១០ (មួយភាគដប់)ចែកនឹង ២ នាំឱ្យម្នាក់ៗទទួលបាន ១/២០ (មួយភាគម្ភៃ)
  - ចំណែកមត៌ករបស់បងប្អូនរួមម្តាយ **Y** និង **Z** ម្នាក់ៗទទួលបាន ១/១០ ចែកនឹង២ នាំឱ្យម្នាក់ៗទទួលបាន ១/២០




## ២.៤. ការសម្រួលចំណែកមត៌ក

ការសម្រួលចំណែកមត៌ក គឺធ្វើឡើងដើម្បីឱ្យមានសមភាពត្រឹមត្រូវជាក់ស្តែងនៃចំណែករបស់សហសន្តតិជន ដើម្បីឱ្យសមស្របទៅនឹងករណីមានអ្នកទទួលផលប្រយោជន៍ពិសេសផ្សេងៗ ដោយតម្រូវឱ្យសងមកវិញនូវចំណែកទាំងនោះ។ នៅក្នុងក្រមរដ្ឋប្បវេណី បានកំណត់អំពីការសម្រួលចំណែកមត៌ក ដែលយើងនឹងធ្វើការសិក្សាទៅលើរួមមានដូចជាផលប្រយោជន៍ពិសេស ភាគនៃវិភាគទាន និងប្រទានកម្ម។

### ២.៤.១. ផលប្រយោជន៍ពិសេស

ផលប្រយោជន៍ពិសេស គឺមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដោយបានបញ្ញត្តិថា នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាដែលបានទទួលប្រទានកម្មនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ឬ ដើម្បីមូលធននៃជីវភាពរស់នៅ ឬ ដែលបានទទួលអច្ច័យទានពីមតកជននោះ តម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាននោះចេញពីចំណែកមត៌កដែលត្រូវបានគណនា គឺជាចំណែកមត៌ករបស់មតកជននោះ។ [106] ពោលគឺមាត្រានេះចែងឡើងក្នុងគោលបំណងសម្រួលនូវចំណែកមត៌កសម្រាប់អ្នកដែលទទួលផលប្រយោជន៍ពិសេស ក្នុងចំណោមសន្តតិជនទាំងអស់មានជនដែលទទួលបានទ្រព្យដោយប្រទានកម្ម ជាអាទិ៍ នៅពេលដែលមតកជននៅរស់ដើម្បីធ្វើឱ្យមានសមភាពត្រឹមត្រូវជាក់ស្តែងរវាងសហសន្តតិជន។ ក្នុងករណីដែលមានការទទួលផលប្រយោជន៍ពិសេសវិធីគណនាចំណែកមត៌កមានដូចខាងក្រោម៖

ដំបូង ត្រូវបូកទឹកប្រាក់នៃការទទួលផលប្រយោជន៍ពិសេសចំពោះមត៌ករបស់មតកជន ដែលហៅថា "ទ្រព្យសម្បត្តិដែលត្រូវចាត់ទុកជាមត៌ក"។ បន្ទាប់មកត្រូវគណនាទ្រព្យដែលត្រូវចាត់ទុកថាជាមត៌កឱ្យស្របតាមបញ្ញត្តិនៃចំណែកមត៌កដែលច្បាប់បានកំណត់ រួចគណនាចំណែកសន្តតិកម្មរបស់សន្តតិជននីមួយៗហៅថា "ចំណែកដែលត្រូវចាត់ទុកថាជាមត៌ក"។ បន្ទាប់មកត្រូវដកនូវទឹកប្រាក់នៃការទទួលផលប្រយោជន៍ពិសេសពីចំណែកដែលត្រូវចាត់ទុកថាជាមត៌ករបស់សន្តតិជនដែលបានទទួលផលប្រយោន៍ពិសេស។[107]

| |
|---|
| **រូបមន្ត៖ ទ្រព្យដែលចាត់ទុកជាមត៌ក = ប្រទានកម្ម + អច្ច័យទាន + តម្លៃសរុបនៃមត៌កពេលចាប់ផ្តើម** |

#### ក. ផលប្រយោជន៍ពិសេសមានតម្លៃតិចជាងចំណែកមត៌ក

ក្នុងករណីដែលប្រទានកម្មមានតម្លៃតិចជាងចំណែកមត៌ក សហសន្តតិជននឹងត្រូវទទួលបាននូវចំណែកមត៌កនៃចំណែកបន្ថែមក្រោយពីទទួលបាននូវផលប្រយោជន៍ពិសេសនោះ ដើម្បីបង្គ្រប់ចំណែកមត៌ករបស់បុគ្គលនោះ។

**ឧទាហរណ៍៖** មតកជន **ក** មានកូនចំនួន ៣នាក់ គឺ A, B និង C ដែល **ក** បានបន្សល់ទុកមត៌កចំនួន **១២០០ ដុល្លារអាមេរិក**។ មុនពេលគាត់ទទួលមរណភាព **ក** បានផ្តល់ផលប្រយោជន៍ពិសេសចំនួន **៣០០ ដុល្លារអាមេរិក** ឱ្យទៅ B។

---

[106] មាត្រា ១១៦៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[107] មេរៀនភាគ ៣ នៃក្រមរដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ សិក្ខាសាលាស្តីពីមូលដ្ឋានគ្រឹះនៃសន្តតិកម្ម ទំ. ១៩

យោងតាមមាត្រា ១១៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ទ្រព្យសម្បត្តិនាពេលចាប់ផ្តើមសន្តតិកម្មមានចំនួន **១២០០ ដុល្លាអាមេរិក** ដោយត្រូវបូក (+) នឹងចំនួនផលប្រយោជន៍ពិសេសគឺ **៣០០ ដុល្លារអាមេរិក** = **១៥០០ ដុល្លារអាមេរិក។**

ដូច្នេះ ចំណែកមត៌កសរុបដែលត្រូវបែងចែកទៅឱ្យ A, B និង C គឺម្នាក់ៗត្រូវទទួលបាន **៥០០ ដុល្លារអាមេរិក** ស្មើៗគ្នា។ ចំពោះ B បានទទួលនូវផលប្រយោជន៍ពិសេសចំនួន **៣០០ ដុល្លារអាមេរិក** នោះចំណែកមត៌កពិតប្រាកដរបស់ B គឺទទួលបានចំនួន **២០០ ដុល្លារអាមេរិក** ដែលជាសមតុល្យបន្ទាប់ពីការដកចំនួន **៣០០ ដុល្លារអាមេរិក ចេញពីទ្រព្យចាត់ទុកជាមត៌កចេញ។**

**ខ. ផលប្រយោជន៍ពិសេសមានតម្លៃស្មើនឹងចំណែកមត៌ក**

បើតម្លៃនៃប្រទានកម្ម ឬអច្ច័យទាន ស្មើគ្នានឹងតម្លៃនៃចំណែកមត៌ក សហសន្តតិជននោះពុំអាចទទួលយកចំណែកមត៌កនោះបានឡើយ។[108]

| |
|---|
| **រូបមន្តៈ** |
| **ចំណែកមត៌ករបស់សន្តតិជន = (ទ្រព្យដែលចាត់ទុកជាមត៌ក × ចំណែកមត៌ក) - ប្រទានកម្ម - អច្ច័យទាន** |

**ឧទាហរណ៍៖** មតកជន ក មានកូនចំនួន ៣នាក់ A, B និង C នឹងបានបន្សល់ទុកមត៌កចំនួន **២,០០០ ដុល្លារអាមេរិក។** មុនពេលទទួលមរណភាព **ក** បានផ្តល់ផលប្រយោជន៍ពិសេសឱ្យទៅ B ចំនួន **១,០០០ ដុល្លារអាមេរិក។**

តាមមាត្រា ១១៦៣ ទ្រព្យនាពេលចាប់ផ្តើមសន្តតិកម្មគឺ ២,០០០ + ១,០០០ = **៣,០០០ ដុល្លារអាមេរិក**

ដូច្នេះ ចំណែកមត៌កសរុបដែលត្រូវបែងចែកទៅឱ្យ A, B និង Cត្រូវទទួលបាន **១,០០០ ដុល្លារអាមេរិក** ស្មើៗគ្នា។ ចំពោះ B ដែលទទួលបាននូវផលប្រយោជន៍ពិសេសចំនួន **១,០០០ ដុល្លារអាមេរិក** ដែលស្មើនឹងចំណែកមត៌ក នោះចំណែកមត៌កពិតប្រាកដរបស់ B គឺមិនទទួលបានទៀតនោះទេ។

**គ. ផលប្រយោជន៍ពិសេសមានតម្លៃលើសពីចំណែកមត៌ក**

ទោះបីជាតម្លៃនៃផលប្រយោជន៍ពិសេសរួមមានប្រទានកម្ម ឬ អច្ច័យទានដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ សហសន្តតិជននោះពុំចាំបាច់បង្វិលមកវិញនូវទ្រព្យ

[108] មាត្រា ១១៦៣ ចំណុចទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

សម្បត្តិដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។[109]

**ឧទាហរណ៍ទី១៖** មតកជន ក មានកូនចំនួន ៣នាក់ A, B និង C នឹងបានបន្សល់ទុកមត៌កចំនួន **២,000 ដុល្លារអាមេរិក**។ មុនពេលទទួលមរណភាព **ក** បានផ្តល់អំណោយឱ្យទៅ B ចំនួន **២,៥00 ដុល្លារអាមេរិក**។

តាមមាត្រា ១១៦៣ ទ្រព្យនាពេលចាប់ផ្តើមសន្តតិកម្មគឺ ២,000 + ២,៥00 = **៤,៥00ដុល្លារអាមេរិក**

ដូច្នេះ ចំណែកមត៌កសរុបដែលត្រូវបែងចែកទៅឱ្យ A, B និង C ម្នាក់ៗត្រូវទទួលបានចំនួន **១,៥00 ដុល្លារអាមេរិក**។ ចំពោះ B ដែលទទួលបាននូវផលប្រយោជន៍ពិសេស **២,៥00 ដុល្លារអាមេរិក** ដែលលើសនឹងចំណែកមត៌ក នោះចំណែកមត៌កពិតប្រាកដរបស់ B គឺមិនទទួលបានទៀតនោះទេ ហើយចំណែកដែលលើស B ក៏មិនចាំបាច់បង្វិលមកវិញដែរ (B លើសចំនួន **១,៥00 ដុល្លារអាមេរិក**)។ ដូចនេះ A និងC ត្រូវទទួលបានចំណែកស្មើៗគ្នានៃចំណែកមត៌កជាក់ស្តែងគឺក្នុងម្នាក់ៗទទួលបាន **១,000 ដុល្លារអាមេរិក**។

ក្នុងករណីដែលមិនចាំបាច់ឱ្យបង្វិលនូវភាគលើសវិញទេ តម្លៃនៃចំណែកមត៌កជាក់ស្តែងរបស់សហសន្តតិជនផ្សេងទៀតនៅពេលសន្តតិជនចាប់ផ្តើមសន្តតិកម្ម ត្រូវគណនាដោយបែងចែកមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មនោះតាមសមាមាត្រនៃចំណែកមត៌ករបស់សន្តតិជនម្នាក់ៗ។[110]

**រូបមន្ត៖ ចំណែកមត៌កជាក់ស្តែងដែលសន្តតិជនត្រូវទទួលបាន = តម្លៃនៃទ្រព្យសម្បត្តិពេលចាប់ផ្តើមសន្តតិកម្ម ÷ តម្លៃសរុបនៃចំណែកមត៌ករបស់សន្តតិជន × ចំណែកមត៌ករបស់សន្តតិជន**

**ឧទាហរណ៍ទី២៖** មតកជន **ក** មានកូនចំនួន ៣នាក់ A, B និង C នឹងបានបន្សល់ទុកមត៌កចំនួន **២,000ដុល្លារអាមេរិក**។ មុនពេលទទួលមរណភាព **ក** បានផ្តល់ផលប្រយោជន៍ពិសេសឱ្យទៅ B ចំនួន **២,000 ដុល្លារអាមេរិក** និង C ក៏បានទទួល **៨00 ដុល្លារអាមេរិក**។

តាមមាត្រា ១១៦៣ ទ្រព្យនាពេលចាប់ផ្តើមសន្តតិកម្មគឺ ២,000 + ២,000 + ៨00 = **៤,៨00 ដុល្លារអាមេរិក**

ដូច្នេះ ចំណែកមត៌កសរុបដែលត្រូវបែងចែកទៅឱ្យ A, B និង C ត្រូវទទួលបានម្នាក់ៗចំនួន **១,៦00 ដុល្លារអាមេរិក** ស្មើៗគ្នា។ ចំពោះ B ដែលទទួលបាននូវផលប្រយោជន៍ពិសេស **២,000 ដុល្លារអាមេរិក** ដែល

[109] មាត្រា ១១៦៥ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២00៧

[110] មាត្រា ១១៦៥ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២00៧

លើសនឹងចំណែកមត៌ក នោះចំណែកមត៌កពិតប្រាកដរបស់ B គឺមិនទទួលបានទៀតនោះទេ ចំពោះ C ដែលទទួលបានប្រទានកម្មចំនួន **៨០០ ដុល្លារអាមេរិក** ដូចនេះ C នៅខ្វះចំនួន **៨០០ ដុល្លារអាមេរិក** និង ចំណែកមត៌ករបស់ A គឺ **១,៦០០ ដុល្លារអាមេរិក**។ ចំនួនមត៌កសរុបរបស់សន្តតិជននីមួយៗមានចំនួន (៨០០+១,៦០០= **២,៤០០**) ដែលលើសចំនួនមត៌កសរុប (ទ្រព្យនាពេលចាប់ផ្តើមសន្តតិកម្ម **២០០០ ដុល្លារអាមេរិក**)។

ដូចនេះ A និង C ត្រូវទទួលបានចំណែកមត៌កតាមការធ្វើសមាមាត្រ $\frac{៨០០}{១,៦០០}$ នៃ ២,០០០ ដុល្លារអាមេរិក (១/២) រវាង A **និងC**។

=> C (៨០០ ÷ ២,៤០០ × ២,០០០ = ៦៦៦.៦៦) => C ទទួលបានមត៌ក **៦៦៦ ដុល្លារអាមេរិក** និង

=> A (២,០០០ - ៦៦៦.៦៦ = ១៣៣៣.៣៤) => A ទទួលបានមត៌ក **១៣៣៣.៣៤ ដុល្លារអាមេរិក។**

### ២.៤.២. ភាគនៃវិភាគទាន

ភាគនៃវិភាគទាននេះ ត្រូវបានចែងឡើងដើម្បីសម្រួលនូវចំណែកមត៌ក។ ភាគនៃវិភាគទាន គឺជាប្រភេទមួយនៃការសម្រួលចំណែកមត៌ក ដោយសារនៅក្នុងចំណោមសន្តតិជនមានបុគ្គលម្នាក់ ឬ ច្រើននាក់បានធ្វើសកម្មភាពថែរក្សា ឬ បង្កើនទ្រព្យសម្បត្តិរបស់មត៌កជន ឬ ថែទាំព្យាបាលមតកជន ឬ បានធ្វើសកម្មភាពផ្សេងៗដែលចម្រើនដល់មតកជន។ ភាគនៃវិភាគទាន គឺជាការបង្រួមចំនួនមត៌កដើម្បីឱ្យមានសមភាពជាក់ស្តែង នៅក្នុងចំណោមសន្តតិជន ដោយបុគ្គលណាម្នាក់ ឬ ច្រើននាក់បានចំណាយសម្រាប់មតកជនមុនពេលសន្តតិកម្មចាប់ផ្តើម។[111]

**រូបមន្ត៖**

| **មត៌កជាក់ស្តែង = មត៌កពេលចាប់ផ្តើមសន្តតិកម្ម - ភាគនៃវិភាគទាន** |
|---|

| **ចំណែកមត៌កនៃអ្នកធ្វើភាគនៃវិភាគទាន = (មត៌កជាក់ស្តែង ÷ ចំនួនសន្តតិជន) + ភាគនៃវិភាគទាន** |
|---|

**ឧទាហរណ៍ទី១៖** មតកជន **ក** មានសហព័ទ្ធ **ខ** និងកូនចំនួន ៣នាក់គឺ A, B និង C។ ពេល ក នៅរស់ A បានចូលរួមវិភាគទានដល់លោក **ក** ចំនួន **១,០០០ ដុល្លារអាមេរិក**។ នៅពេលដែល **ក** ទទួលមរណភាពបានបន្សល់ទុកមត៌កចំនួន **៣,០០០ ដុល្លារអាមេរិក**។

[111] មាត្រា ១១៦៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

មត៌កជាក់ស្តែង = ៣,០០០ - ១,០០០ = **២,០០០ ដុល្លារអាមេរិក**

ដោយសន្តតិជនមានចំនួន បួននាក់ គឺ **ខ**, **A**, **B** និង **C** នោះចំណែកមត៌កត្រូវបែងចែកជា៤ ចំណែក ប៉ុន្តែដោយ A បានចូលរួមវិភាគទានចំនួន **១,០០០ ដុល្លារអាមេរិក**

នោះ ចំណែកមត៌ករបស់ A = (២,០០០÷៤) + ១,០០០ = **១,៥០០ ដុល្លារអាមេរិក**

ចំពោះ **ខ**, B និង C គឺទទួលបានចំណែកស្មើៗគ្នាគឺ => **ខ**= B = C = ២,០០០÷៤ = **៥០០ ដុល្លារអាមេរិក**

ដូចនេះ ចំណែកមត៌ករបស់ A គឺ **១,៥០០ ដុល្លារអាមេរិក**, ចំណែកមត៌ករបស់ ខ, B និង C គឺ **៥០០ ដុល្លារអាមេរិក**។

សហសន្តតិជន ត្រូវកំណត់តម្លៃភាគនៃវិភាគទានដោយការពិភាក្សានៅពេលបែងចែកមត៌ក ប៉ុន្តែប្រសិនបើក្នុងករណីដែលការពិភាក្សានេះមិនចុះសម្រុងគ្នាជាអាទិ៍ត្រូវឱ្យតុលាការកំណត់។ ចំពោះករណីភាគច្រើនការបែងចែកមត៌កជាអាទិ៍ នេះក៏មិនសូវមានការចុះសម្រុងគ្នាទេ។ ដូច្នេះជាទូទៅពេលដាក់ពាក្យសុំឱ្យតុលាការធ្វើការវិនិច្ឆ័យនូវការបែងចែកចំណែកមត៌ក គេច្រើនតែសុំឱ្យតុលាការកំណត់តម្លៃភាគនៃវិភាគទានព្រមគ្នាដែរ។ ក្នុងករណីដែលសហសន្តតិជនទាំងអស់អាចធ្វើការបែងចែកមត៌កបានដោយខ្លួនឯង បន្ទាប់ពីបានកំណត់តម្លៃភាគនៃវិភាគទានរួចរាល់ នោះគេអាចដាក់ត្រឹមតែពាក្យសុំឱ្យទៅតុលាការកំណត់បាន ប៉ុន្តែករណីបែបនេះកម្រមានណាស់។[112]

- **ករណីភាគនៃវិភាគទាន** > ចំណែកមត៌កដែលមានកំណត់ក្នុងបណ្តាំមត៌ក ត្រូវយកបណ្តាំមត៌កជាគោល យោងតាមមាត្រា ១១៦៦ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

**ឧទាហរណ៍៖** មតកជន **ក** មានសហព័ទ្ធ **ខ** និងកូនចំនួន ៣នាក់គឺ **A, B** និង **C** បានបន្សល់ទុកមត៌កចំនួន **៣,០០០ ដុល្លារអាមេរិក**។ មុនពេល ក ស្លាប់ A បានចូលរួមវិភាគទាន **២,០០០ ដុល្លារអាមេរិក**។

- ប្រសិនបើបណ្តាំបានកំណត់ថា A = **១,២០០ ដុល្លារអាមេរិក**, B = **៨០០ ដុល្លារអាមេរិក**, C = **១,០០០ ដុល្លារអាមេរិក** ដោយសារមតកសាសន៍ ឬ បណ្តាំមត៌កមានអានុភាពជាង ហេតុនេះត្រូវអនុវត្តតាមបណ្តាំនាំឱ្យ A មិនទទួលបានភាគនៃវិភាគនោះទេ។
- ប្រសិនបើបណ្តាំបានកំណត់ថា A = **៦០០ ដុល្លារអាមេរិក**, B = **៨០០ ដុល្លារអាមេរិក**,

[112] មាត្រា ១១៦៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

C = **១,000 ដុល្លារអាមេរិក** ដោយសារមតកសាសន៍ ឬ បណ្តាំមត៌កមានអានុភាពជាង ហេតុនេះត្រូវអនុវត្តតាមបណ្តាំនាំឱ្យ A អាចទទួលបានភាគនៃវិភាគទានតែ **៦00 ដុល្លារអាមេរិក** ប៉ុណ្ណោះ។ បន្ទាប់ពីបែងចែកទ្រព្យ A = **៦00 ដុល្លារអាមេរិក**, B = **៨00 ដុល្លារអាមេរិក**, C = **១,000 ដុល្លារអាមេរិក** => (៣,000-៦00-៨00-១,000 = **៦00 ដុល្លារអាមេរិក**)

- **ករណីមានភាគនៃវិភាគទាន និងផលប្រយោជន៍ពិសេសក្នុងពេលតែមួយ**

**ឧទាហរណ៍៖** មតកជន **ក** មានកូនចំនួន ៣នាក់ គឺ A, B និង C។ មុនពេល ក ស្លាប់បានឱ្យលុយ A ចំនួន **១0,000 ដុល្លារអាមេរិក** និង B ចំនួន **២,000 ដុល្លារអាមេរិក** ហើយ C បានចេញថ្លៃព្យាបាល **ក** ដោយចំណាយអស់ **៨,000 ដុល្លារអាមេរិក**។ នៅពេលបើកសន្តតិកម្ម **ក** បានបន្សល់ទុកមត៌កចំនួន **១៤,000 ដុល្លារអាមេរិក។**

មត៌កសរុប = ១៤,000 + ១0,000 + ២,000 - ៨,000 = **១៨,000**

- ចំណែកមត៌ករបស់ A = (១៨,000÷៣) - ១0,000 = **-៤,000**
- ចំណែកមត៌ករបស់ B = (១៨,000÷៣) - ២,000 = **៤,000**
- ចំណែកមត៌ករបស់ C = (១៨,000÷៣) + ៨,000 = **១៤,000**

ដោយ A ទទួលបាននូវផលប្រយោជន៍ពិសេសលើសនូវចំណែកមត៌ក ប៉ុន្តែ A មិនចាំបាច់បង្វិលសងវិញនោះទេ។ មត៌កជាក់ស្តែងមាន **១៤,000 ដុល្លារអាមេរិក** ហេតុនេះមិនអាចឱ្យទៅ B និង C ទាំងអស់បានទេ ត្រូវធ្វើតាមវិធានសមាមាត្រ ដូចខាងក្រោម៖

ចំណែករបស់ B = (៤,000 × ១៤,000) ÷ ១៨,000 = **៣១១១.១១ ដុល្លារអាមេរិក**

ចំណែករបស់ C = (១៤,000 × ១៤,000) ÷ ១៨,000= **១0,៨៨៨.៨៩ ដុល្លារអាមេរិក**

**២.៤.៣. ប្រទានកម្ម**

កិច្ចសន្យាដែលភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល គេហៅថា “**ប្រទានកម្ម**”។[113] អ្នកដែលទទួលទ្រព្យហៅថា “**បដិគ្គាហក**” និងអ្នកឱ្យទ្រព្យហៅថា “**ទាយក**”។ ក្នុងករណី បដិគ្គាហកបានចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនទទួលដោយប្រទានកម្ម នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បើទ្រព្យសម្បត្តិនោះត្រូវបានបាត់ ឬ វិនាសនៅមុនពេលចាប់ផ្តើមសន្តតិកម្ម។ គេត្រូវគណនា ដោយគិតតម្លៃនៅពេលដែលបានចាត់ចែង ឬ នៅពេលបាត់បង់ ឬ វិនាសនោះ។ ប្រសិនបើតម្លៃនៃប្រទានកម្មនោះត្រូវបានផ្លាស់ប្តូរ ដោយសារលទ្ធផលដែលបដិគ្គាហកបានផ្លាស់ប្តូរទ្រព្យសម្បត្តិនោះមួយផ្នែក

[113] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២00៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ១៤, លេខ ៩៩

តម្លៃនៃប្រទានកម្មត្រូវគណនាដោយចាត់ទុកថាមានស្ថានភាពដើមនៅពេលចាប់ផ្ដើមសន្តតិកម្ម។ ការប្រាក់ និង ផលចំណេញកើតចេញពីប្រទានកម្ម ដែលសន្តតិជននោះបានទទួលពុំត្រូវគណនាចូលក្នុងតម្លៃនោះឡើយ។

តម្លៃផលប្រយោជន៍ពិសេស៖

- **ផលប្រយោជន៍ពិសេសកើនឡើង៖** យកតម្លៃថ្ងៃធ្វើប្រទានកម្មមកធ្វើការគណនា
- **ផលប្រយោជន៍ពិសេសធ្លាក់ចុះ៖** យកតម្លៃថ្ងៃបើកសន្តតិកម្មមកធ្វើការគណនា

**ឧទាហរណ៍៖** មតកជន **ក** មានកូនចំនួន ៣ នាក់ គឺ A, B និង C ដែលជាសន្តតិជន។ មុនពេល **ក** ទទួលមរណភាពបានឱ្យដីទៅ A ដែលមានតម្លៃ **២០,000 ដុល្លារអាមេរិក** និងបានឱ្យរថយន្តដែលមានតម្លៃ **៣0,000 ដុល្លារអាមេរិក** ទៅ B ។ ពេល **ក** ទទួលមរណភាពបានបន្សល់ទុកមត៌កចំនួន **៤0,000 ដុល្លារអាមេរិក**។ ដល់ថ្ងៃបើកសន្តតិកម្ម ដីដែលជាប្រទានកម្មបានកើនឡើងដល់ **៤0,000 ដុល្លារអាមេរិក** រីឯតម្លៃនៃរថយន្តនៅថ្ងៃបើកសន្តតិកម្មបានធ្លាក់ចុះសល់ **១0,000 ដុល្លារអាមេរិក**។

យោងតាមមាត្រា ១១៦៤ នៃក្រមរដ្ឋប្បវេណី៖

- ការគណនាតម្លៃដីដែល **ក** បានធ្វើប្រទានកម្មមកឱ្យ A គឺត្រូវយកតម្លៃនៅថ្ងៃធ្វើប្រទានកម្មគឺ **២0,000 ដុល្លារអាមេរិក**
- ការគណនាតម្លៃរថយន្តដែល **ក** បានធ្វើប្រទានកម្មមកឱ្យ B គឺត្រូវយកតម្លៃនៅថ្ងៃបើកសន្តតិកម្មគឺ **១0,000 ដុល្លារអាមេរិក**

ចំណែកមត៌កសរុប = ៤0,000 + ២0,000 + ១0,000 = **៧0,000 ដុល្លារអាមេរិក**

## ២.៥. ស្ថានភាពពិសេស

ស្ថានភាពពិសេសនៃសន្តតិកម្ម គឺជាករណីដែលសន្តតិកម្មចាប់ផ្ដើម ដោយគ្មានសន្តតិជន ដែលជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចរបស់មត៌ក ដោយតម្រូវឱ្យមានការស្វែងរកសន្តតិជន ដើម្បីមកស្នងមត៌កទាំងនោះ និងនៅក្នុងករណីគ្មានសន្តតិជន នាំឱ្យមត៌កទាំងនោះអាចត្រូវធ្លាក់ទៅជនមាននិស្ស័យពិសេស (នត្ថិភាពនៃសន្តតិជន)។ មួយវិញទៀត ស្ថានភាពពិសេសនៃសន្តតិកម្ម អាចកើតឡើងបានផងដែរ នៅក្នុងករណី ជនដែលមើលខាងក្រៅហាក់ដូចជាសន្តតិជន បានស្នងមត៌ក និងកាន់កាប់មត៌កនោះដោយគ្មានមូលហេតុគតិយុត្ត ដែលជាមូលហេតុនាំឱ្យសន្តតិជនពិតប្រាកដ អាចទាមទារឱ្យធ្វើបដិទានសន្តតិកម្ម បានផងដែរ។

### ២.៥.១. នត្ថិភាពនៃសន្តតិជន

#### ក. នីតិបុគ្គលមត៌ក

ប្រសិនបើពុំច្បាស់ថាមានសន្តតិជន មត៌កទាំងនោះត្រូវក្លាយជានីតិបុគ្គល។[114] អ្នកគ្រប់គ្រងទ្រព្យសម្បត្តិសន្តតិកម្ម ហៅថា "នីតិបុគ្គលមត៌ក" ត្រូវជ្រើសតាំងដោយតុលាការ តាមរយៈពាក្យសុំរបស់បុគ្គលណាម្នាក់ដូចជា៖

- បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍
- មេឃុំ ឬ ចៅសង្កាត់នៃលំនៅដ្ឋានចុងក្រោយរបស់មតកជន ឬ
- តំណាងអយ្យការ។[115]

នីតិបុគ្គលមត៌កត្រូវគ្រប់គ្រងដោយអ្នកគ្រប់គ្រងមត៌ក។ ការងារសំខាន់ៗរបស់អ្នកគ្រប់គ្រងមត៌ក គឺការក្តាប់ឱ្យដឹងពីមត៌កទាំងអស់ ការសងបំណុលរបស់មតកជន ហើយការបែងចែកមត៌កដែលនៅសល់ទៅឱ្យអ្នកមាននិស្ស័យពិសេស ឬ បង្វិលមត៌កនោះទៅឱ្យរដ្ឋ ហើយដើម្បីធ្វើការទាំងនោះក្នុងករណីចាំបាច់ត្រូវចាត់ចែងប្តូរមត៌កនោះឱ្យទៅជាប្រាក់ ដោយត្រូវមានការអនុញ្ញាតពីតុលាការ។ អ្នកគ្រប់គ្រងមត៌ក ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌទាក់ទងនឹងមត៌ក ហើយការធ្វើបញ្ជីនេះត្រូវធ្វើដោយរាប់បញ្ចូលទាំងទ្រព្យសកម្ម និងរាល់កាតព្វកិច្ចនៃសន្តតិកម្មដែលអាចដឹងឮបាន។[116] តុលាការអាចផ្តល់កម្រៃសមរម្យចេញពីក្នុងចំណោមមត៌កឱ្យទៅអ្នកគ្រប់គ្រងបាន ដោយយកតម្លៃមត៌កអំឡុងពេលគ្រប់គ្រងកិច្ចការដែលត្រូវធ្វើមកធ្វើជាមូលដ្ឋាននៃការគណនា ដើម្បីសម្រេចនូវកម្រៃដោយលក្ខណៈសត្យានុម័ត។[117] ប្រសិនបើដឹងថាមានសន្តតិជន ក្រោយពេលជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក នោះនីតិបុគ្គលមត៌កត្រូវចាត់ទុកថាពុំមានអត្ថិភាពតាំងពីដំបូង។[118] ករណីនេះសិទ្ធិអំណាចនៃអ្នកគ្រប់គ្រងមត៌កត្រូវផុតរលត់ដរាបណាសន្តតិជនយល់ព្រមទទួលសន្តតិកម្ម ហើយអ្នកគ្រប់គ្រងមត៌កត្រូវបង្ហាញឱ្យបានច្បាស់លាស់នូវស្ថានភាពដែលខ្លួនបានគ្រប់គ្រងតាំងពីពេលចាប់ផ្តើមរហូតដល់ពេលសន្តតិជននោះយល់ព្រមទទួលសន្តតិកម្ម។[119]

អ្នកគ្រប់គ្រងមត៌ក ត្រូវជូនដំណឹងជាសាធារណៈ បន្ទាប់ពីរយៈពេល ២ (ពីរ) ខែ បានកន្លងផុត ទៅម្ចាស់បំណុលរបស់មតកជន និងអច្ច័យលាភីទាំងអស់អំពីការណ៍ដែលម្ចាស់បំណុល និងអច្ច័យលាភីទាំងនោះត្រូវស្នើ

---

[114] មាត្រា ១២៩០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[115] មាត្រា ១២៩១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[116] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្ថីទី៨-៩ មាត្រា១២៩២, ទំ.១៥៣
[117] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្ថីទី៨-៩ មាត្រា១២៩៣, ទំ.១៥៤
[118] មាត្រា ១២៩៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
[119] មាត្រា ១២៩៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

សុំអំពីការទាមទារក្នុងអំឡុងពេលដែលបានកំណត់។ អំឡុងពេលនេះមិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ។[120] បន្ទាប់ពីរយៈពេលនៃការជូនដំណឹងកន្លងផុត ប្រសិនបើនៅតែគ្មានដំណឹងពីសន្តតិជន គេអាចដកហូតសិទ្ធិសន្តតិជនបាន។ ការដកហូតសិទ្ធិសន្តតិជន គឺជារបបមួយដែលបង្កើតឡើងដើម្បីធ្វើការសម្រេចឱ្យបានឆាប់រហ័សនូវអ្នកដែលត្រូវទទួលមត៌ក ក្នុងករណីដែលមានមត៌ក ហើយក្នុងករណីដែលប៉ាន់ប្រមាណឃើញថាគ្មានសល់មត៌ក បន្ទាប់ពីការសងបំណុលរបស់មតកជនទេ បើទោះបីជាខិតខំស្វែងរកសន្តតិជនក៏គ្មានប្រយោជន៍ដែរ ដូចនេះតុលាការមិនចាំបាច់ស្វែងរកសន្តតិជនទេ។[121]

### ខ. ចំណែកចំពោះជនដែលមាននិស្ស័យពិសេស

ជនដែលមាននិស្ស័យពិសេស អាចដាក់ពាក្យសុំទៅតុលាការបាន បន្ទាប់ពីអំឡុងពេលស្វែងរកសន្តតិជនបានផុតទៅក្នុងអំឡុងពេល ៣ (បី) ខែ ដើម្បីឱ្យតុលាការចែកមួយផ្នែកនៃមត៌កដែលនៅសេសសល់ឱ្យខ្លួនបាន តាមរយៈដីកាសម្រេច។[122]ជនដែលមាននិស្ស័យពិសេស ត្រូវបង្ហាញភស្តុតាងពីនិស្ស័យពិសេសរបស់ខ្លួនជាមួយនឹងមតកជន ទោះបីជាជននោះពុំមានទំនាក់ទំនងញាតិជាមួយមតកជនក៏ដោយ លុះត្រាណាជននោះបានបង្ហាញភស្តុតាងដូចខាងក្រោម៖

- មានជីវភាពជាមួយគ្នានឹងមតកជន
- បានខិតខំមើលថែទាំព្យាបាលមតកជន
- មាននិស្ស័យពិសេសផ្សេងទៀត។

ចំនួនសរុបនៃតម្លៃទ្រព្យដែលត្រូវចែកឱ្យទៅជនដែលមាននិស្ស័យពិសេស មិនត្រូវលើសពីចំនួនពាក់កណ្តាលនៃមត៌កដែលនៅសេសសល់នោះទេ។

### គ. មត៌កដែលក្លាយជារបស់រដ្ឋ

ចំពោះមត៌ក (អចលនវត្ថុ) ដែលជាកម្មវត្ថុនៃសន្តតិកម្ម ប្រសិនបើគ្មានសន្តតិជនស្នងលើអចលនវត្ថុនោះទេ ត្រូវក្លាយជាទ្រព្យសម្បត្តិរបស់រដ្ឋ រីឯចំណែកដែលនៅសល់ពីការបែងចែកទៅឱ្យជនដែលមាននិស្ស័យពិសេស និងក្លាយជារបស់រដ្ឋផងដែរ។[123] អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ហើយដាក់ជូនទៅតុលាការដោយគ្មានការយឺតយ៉ាវ។

---

[120] មាត្រា ១២៩៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[121] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្លឹះទី៨-៩ មាត្រា១២៩៧, ទំ.១៥៧

[122] មាត្រា ១២៩៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[123] មាត្រា ១៣០០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

### ២.៥.២. ការធ្វើបដិទាននៃសន្តតិកម្ម

បដិទានសន្តតិកម្ម គឺជាការទាមទារមួយដែលជាសិទ្ធិរបស់សន្តតិជនពិតប្រាកដធ្វើការទាមទារចំណែកមត៌កនៃសន្តតិកម្ម ពីបុគ្គលដែលត្រូវបានគេឃើញថាជាសន្តតិជន ប៉ុន្តែការពិតជននោះពុំមែនជាសន្តតិជនពិតប្រាកដនោះទេ ដូច្នេះសន្តតិជនពិតប្រាកដអាចទាមទារឱ្យជននោះប្រគល់ចំណែកមត៌កនៃសន្តតិកម្មនោះមកវិញ។[124] ហើយការទាមទារឱ្យធ្វើបដិទាននេះទៀតសោត មានភាពខុសគ្នានឹងករណីដែលសន្តតិជនធ្វើការទាមទារដើម្បីយកមត៌កមកវិញ ព្រោះថាតតិយជនដែលមិនពាក់ព័ន្ធបានកាន់កាប់មត៌កនោះដោយគ្មានសិទ្ធិនាំឱ្យមានមូលដ្ឋានគតិយុត្តក្នុងការកាន់កាប់ ហើយការទាមទារដើម្បីយកមត៌កមកវិញគឺអាចទាមទារតាមបញ្ញត្តិស្តីពីសិទ្ធិប្រត្យក្ស ជាអាទិ៍។ ស្ថានភាពដែលអាចឱ្យកើតមានការធ្វើបដិទានសន្តតិកម្មមានដូចខាងក្រោម៖

**ទី១៖** ការក្លែងបន្លំសំបុត្រកំណើតរបស់កូន ដែលមិនមែនជាកូនរបស់មតកជនពិតប្រាកដ។

**ទី២៖** ករណីដែលមតកជនមានកូនជាមួយអ្នកផ្សេង ហើយមិនបានទាក់ទងជាមួយគ្នាយូរ ហើយសន្តតិកម្មធ្វើឡើងតែក្នុងរង្វង់គ្រួសារថ្មី ជាអាទិ៍។

**ទី៣៖** សន្តតិជនណាមួយបានទទួលនូវសន្តតិកម្មលើសចំណែកមត៌ករបស់ខ្លួន។[125]

ក្នុងករណីដែលជនដែលមិនមែនជាសន្តតិជនពិតប្រាកដបានទទួលនូវចំណែកសន្តតិកម្ម ហើយបានលក់ទ្រព្យនោះទៅឱ្យតតិយជនបាត់ហើយ ជាគោលការណ៍គឺមិនអាចទាមទារឱ្យធ្វើបដិទានចំពោះអ្នកទិញបានទេ ដោយអាចត្រឹមតែទាមទារនូវថ្លៃលក់ដែលជាវត្ថុជំនួសមត៌កនោះប៉ុណ្ណោះ។[126] ប្រសិនបើអ្នកទិញដឹងថា សន្តតិជនដែលជាអ្នកលក់នោះគ្មានសិទ្ធិសន្តតិកម្មនៅលើមត៌កនេះ ហើយនៅតែធ្វើកិច្ចព្រមព្រៀងលក់ទិញទៀត សន្តតិជនពិតប្រាកដអាចទាមទារនូវវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញបានមកវិញ ដោយអះអាងថាកម្មសិទ្ធិនៃវត្ថុនោះមិនត្រូវបានផ្ទេរទៅអ្នកទិញឡើយ ព្រោះអ្នកទិញទុច្ចរិត និងមានកំហុស។[127] ម្យ៉ាងទៀត ជនដែលមិនមែនជាសន្តតិជនពិតប្រាកដ ត្រូវប្រគល់មកវិញនូវទ្រព្យដែលជាកម្មវត្ថុនៃសន្តតិកម្មទៅឱ្យសន្តតិជនពិតប្រាកដតាមរយៈការទាមទារ។ ប្រសិនបើជនដែលមិនមែនជាសន្តតិជនពិតប្រាកដនោះជាបុគ្គលសុចរិត ជននោះមានសិទ្ធិរក្សាទុកនូវផល និងការប្រាក់ដែលបានទទួល និងមានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលខ្លួនបានសងតាមរយៈសន្តតិកម្មនោះបាន។[128] ផ្ទុយទៅវិញ ប្រសិនបើជននោះទុច្ចរិត ជននោះមានកាតព្វកិច្ចប្រគល់មក

[124] មាត្រា ១៣០២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[125] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្លឹះទី៨-៩ មាត្រា១៣០២, ទំ.១៦២-១៦៣

[126] មាត្រា ១៣០២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[127] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្លឹះទី៨-៩ មាត្រា ១៣០២, ទំ.១៦៣

[128] មាត្រា ១៣០៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

វិញនូវផល និងការប្រាក់ដែលបានទទួល ហើយមិនត្រឹមតែគ្មានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្មនោះទេ ថែមទាំងគ្មានសិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះផង។[129] អ្នកដែលមានសិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ត្រូវអនុវត្តសិទ្ធិរបស់ខ្លួននៅក្នុងអំឡុងពេល ០៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលមត៌កត្រូវបានផ្ទេរទៅភាគីម្ខាងទៀតតាមរយៈមតកសាសន៍ ឬ ការពិភាក្សាបែងចែកមត៌ក ឬ នៅក្នុងករណីជនម្នាក់បានទទួលសន្តតិកម្មក្នុងនាមជាសន្តតិជនមានអំឡុងពេល ០៥ (ប្រាំ)ឆ្នាំ ដោយអាជ្ញាយុកាលនេះ ត្រូវគិតចាប់ពីថ្ងៃដែលមតកជនបានទទួលមរណភាព។[130]

[129] មាត្រា ១៣០៣ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[130] មាត្រា ១៣០៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងបកស្រាយប្រធានបទស្តីពី "**សន្តតិកម្មតាមច្បាប់**" រួចមក អាចធ្វើការសន្និដ្ឋានបានថា របបសន្តតិកម្ម គឺជារបបគតិយុត្តិមួយដែលក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បញ្ញត្តិឡើងដើម្បីគោរពសិទ្ធិរបស់ញាតិភាពនៃមតកជន ដែលកាលពីមតកជននៅរស់រានមានជីវិត មានសិទ្ធិ និងកាតព្វកិច្ចក្នុងឋានៈជាសាច់សាលោហិតពីធម្មជាតិផងពោរពេញទៅដោយមនោសញ្ចេតនាក្តីស្រឡាញ់ និងការជួយសង្គ្រោះគ្នា ឱ្យទៅជាអ្នកទទួលបានសិទ្ធិ និងផលប្រយោជន៍សក្តិសមនឹងការបន្តពូជពង្សវង្សត្រកូលឱ្យបានគង់វង្ស និងអភិវឌ្ឍន៍ទាំងកេរ្តិ៍ឈ្មោះ និងទ្រព្យសម្បត្តិ។ យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ជនដែលមានសិទ្ធិក្នុងការទទួលបន្តនូវចំណែកមត៌កដែលបន្សល់ទុកដោយមតកជនមុនគេ គឺជាជនដែលច្បាប់បានកំណត់តាមលំដាប់បន្តបន្ទាប់ ដោយកំណត់យកសន្តតិជនគឺជាញាតិលោហិតខ្សែផ្ទាល់របស់មតកជន មិនមែនជាញាតិពន្ធឡើយ។ មួយវិញទៀត ក្រៅពីសន្តតិជនដែលច្បាប់បានកំណត់ ក៏នៅមានសន្តតិជនមួយចំនួនទៀតដែលអាចនឹងមានសិទ្ធិទទួលបានចំណែកមត៌កបន្ទាប់ពីអវត្តមានរបស់សន្តតិជនដែលច្បាប់បានកំណត់ផងដែរ។ ករណីពិសេស គឺច្បាប់បានកំណត់យកសហព័ទ្ធរបស់មត៌កជនជាសន្តតិជនជានិច្ច មានន័យថាទោះបីស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ប្រសិនបើសហព័ទ្ធរបស់មតកជននោះនៅរស់ហើយមិនបានប្រព្រឹត្តខុសទៅនឹងអ្វីដែលច្បាប់បានកំណត់នោះទេ សហព័ទ្ធនោះគឺនៅតែមានសិទ្ធិចូលរួមបែងចែកចំណែកមត៌កជាមួយសន្តតិជនលំដាប់ផ្សេងៗទៀត។ មិនត្រឹមតែប៉ុណ្ណោះ សន្តតិជនអាចបង្ហាញឆន្ទៈ ថាយល់ព្រមទទួល ឬ បោះបង់នូវការស្នងសន្តតិកម្មនេះបាន ប្រសិនបើកាតព្វកិច្ចដែលត្រូវទទួលធ្ងន់ធ្ងរពេក (ទ្រព្យអកម្ម)។

ប្រសិនបើពិនិត្យមើលលើភាពជាក់ស្តែងនៅក្នុងសង្គមវិញ សន្តតិកម្មតាមច្បាប់មិនបានអនុវត្តឱ្យបានទូលំទូលាយនោះទេ ដោយមនុស្សភាគច្រើនមិនបានយល់ដឹងពីអត្ថន័យនៃពាក្យសន្តតិកម្មនេះ ប៉ុន្តែសកម្មភាពដែលយើងមើលឃើញរួមមានដូចជា ការប្រគល់ឱ្យនូវទ្រព្យណាមួយពីមត៌កជនទៅទាយាទរបស់ខ្លួន គឺជាសកម្មភាព និងការប្រព្រឹត្តទៅយ៉ាងពេញនិយមទៅវិញ។ តួយ៉ាងគេច្រើនអនុវត្តដូចជា កូនរបស់មតកជន (សន្តតិជន) មានកាតព្វកិច្ចមើលថែរក្សា ទំនុកបម្រុងឪពុកម្តាយចាស់ជរា ហើយពួកគេរំពឹងទុកថានៅពេលដែលម្តាយ ឬ ឪពុកស្លាប់ទៅ ទ្រព្យទាំងនោះនឹងត្រូវធ្លាក់លើពួកគេតែម្តង ឬ ខ្លះទៀតកូនៗជាសន្តតិជនមិនបានទទួលអ្វីទាល់តែសោះនៅពេលសន្តតិកម្មចាប់ផ្តើម ក្រោយមតកជនណាម្នាក់បានទទួលមរណភាព ព្រោះពួកគេទាំងនោះបាននូវចំណែករបស់ខ្លួនរួចទៅហើយនាពេលអាពាហ៍ពិពាហ៍ដូចជាការចងដៃ ហើយច្បាប់បានឱ្យឈ្មោះថា

ជាការទទួលបានប្រទានកម្ម ឬ ផលប្រយោជន៍ពិសេស។ បើទោះបីជាយ៉ាងនេះក្តី ចំពោះគ្រួសារខ្លះវិញទំនាស់ត្រូវបានកើតមានឡើង ដោយមូលហេតុនៃការបែងចែកមត៌កគ្មានភាពស្មើគ្នា ព្រោះសន្តតិជនម្នាក់ៗចង់បានចំណែកច្រើនរៀងៗខ្លួន ហើយអាចកើតមានការប្តឹងគ្នាដល់តុលាការទៀតផង។ ក្រៅពីសន្តតិជនដែលបានកំណត់ដោយច្បាប់ យើងសង្កេតឃើញថា ប្រសិនបើនត្ថិភាពនៃសន្តតិជន ក្រោយពីស្វែងរកអស់លទ្ធភាពហើយមត៌កនោះនឹងត្រូវធ្លាក់ជាទ្រព្យសម្បត្តិរដ្ឋដើម្បីបម្រើផលប្រយោជន៍សាធារណៈ។

ដូចនេះហើយទើបការសិក្សាពី "**សន្តតិកម្មតាមច្បាប់**" មានសារៈសំខាន់ណាស់ ព្រោះវាជាភាពចាំបាច់ក្នុងការអនុវត្តជាក់ស្តែងក្នុងជីវភាពសង្គម។ ប្រសិនបើប្រជាពលរដ្ឋបានទទួលនូវចំណេះដឹងទាក់ទងនឹងសន្តតិកម្ម នោះជម្លោះ ការប៉ះពាល់សិទ្ធិ និងផលប្រយោជន៍ផ្សេងៗត្រូវបានកាត់បន្ថយផងដែរ ដែលជាការរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការកសាង និងលើកកម្ពស់ការអនុវត្តស្របតាមច្បាប់ប្រកបដោយប្រសិទ្ធិភាព និរន្តរភាព តម្លាភាពលើប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជាដែលយើងគ្រប់គ្នាជាពលរដ្ឋមិនគួរមើលរំលងឡើយ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ "**សន្តតិកម្មតាមច្បាប់**" រួចមក យើងសង្កេតឃើញថាសន្តតិកម្មដែលបានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ គន្ថីទី ៨ គឺមានលក្ខណៈគ្រប់គ្រាន់ក្នុងការយកទៅអនុវត្តនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្នបាន ។ ប៉ុន្តែនាពេលអនាគត សង្គមនឹងមានការវិវឌ្ឍន៍ខុសពីពេលបច្ចុប្បន្ន ដែលយើងមិនអាចកំណត់បានជាមុន ហេតុនេះហើយ ច្បាប់ និងបទបញ្ញត្តិនានាក៏ត្រូវមានការវិវឌ្ឍន៍ដើម្បីឱ្យស្របទៅនឹងបរិបទសង្គមនាពេលអនាគតដែរ។

ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ យើងខ្ញុំសូមចូលរួមចំណែកក្នុងការបញ្ចេញមតិយោបល់ និងផ្តល់ជាអនុសាសន៍មួយចំនួន ដើម្បីធ្វើឱ្យមានភាពល្អប្រសើរឡើងនូវសន្តតិកម្មនៃប្រទេសកម្ពុជា។ ដោយតាមរយៈការស្រាវជ្រាវ យើងសង្កេតឃើញថា៖

១.បើពុំមានមតកសាសន៍ទេ ជាការពិតណាស់សន្តតិជនអាចនឹងពិភាក្សាដោយសន្តិវិធីដើម្បីបែងចែកមត៌កតាមការព្រមព្រៀងគ្នា។

២.ការពិភាក្សាអាចឈរលើមូលដ្ឋានច្បាប់ស្តីអំពីការបែងចែកមត៌ក ក្នុងករណីអវត្តមាននៃមតកសាសន៍នេះបាន ព្រោះនីតិករបានពិចារណារួចទៅហើយអំពីសាមគ្គីភាព ក៏ដូចជាឈរលើគោលការណ៍សមធម៌ផងយុត្តិធម៌ក្នុងការទទួលបានផលប្រយោជន៍របស់ញាតិទៅតាមលំដាប់ថ្នាក់ដែលបានសិក្សាអំពីលក្ខខណ្ឌធម្មជាតិនៃទំនាក់ទំនងញាតិផង និងជាកាតព្វកិច្ចផង។

៣.ជាចុងក្រោយនៃជម្រើសដែលមិនជាល្អនោះគឺក្នុងករណីពុំមានការឯកភាពគ្នាដូចមាននៅចំណុចទី១ និងទី២ ខាងលើ គឺប្តឹងទៅតុលាការ។

ដូចនេះដើម្បីកុំឱ្យខាតបង់ពេលវេលាក៏ដូចជាប្រាក់កាស សន្តតិជនទាំងឡាយគួរតែធ្វើការបែងចែកដោយព្រមព្រៀងគ្នា ទោះជាក្នុងរូបមន្តតាមច្បាប់ក្តី ឬ ដោយមានការព្រមព្រៀងផ្សេងទៀតក្តី។

ជាចុងក្រោយ យើងខ្ញុំស្នើសុំទៅស្ថាប័នដែលពាក់ព័ន្ធ សូមឱ្យមានការសិក្សា និងបកស្រាយបន្ថែម ដោយផ្តោតទៅលើបញ្ហាដែលបានកំណត់ខាងលើ ដើម្បីឱ្យមានវិសាលភាពគ្រប់ជ្រុងជ្រោយទៅលើប្រធានបទ "**សន្តតិកម្មតាមច្បាប់**" នេះ ក្នុងគោលបំណងឱ្យអ្នកសិក្សាស្រាវជ្រាវក្រោយៗទៀត ងាយយល់ និងអាចក្តោបអត្ថន័យបានពេញលេញ។

# ឯកសារយោង

# ឯកសារយោង

1. **បទដ្ឋានគតិយុត្ត**

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១
- សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ ៦ : រៀបចំដោយសមាជិកក្រុមការងារដែលរួមមានអនាគតគ្រូបណ្តុះបណ្តាលសាលាភូមិន្ទចៅក្រម រួមមានសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និងនាយកដ្ឋានសហប្រតិបត្តិការនៃវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន (ICD) ឆ្នាំ២០១២។
- សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ : គន្លឹទី៨ និងគន្លឹទី៩ រៀបចំដោយក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី ឆ្នាំ២០១០។

2. **សៀវភៅស្នាដៃ**

- ចាំង ស៊ីណាត, សៀវភៅមេរៀន "**នីតិមត៌ក**"
- ស៊ិន ច័ន្ទផល្គុន, ស្លាយ "**គោលការណ៍ទូទៅសន្តិកម្ម**" **ឆ្នាំ២០២១**
- អ៊ីវ ប៉ូលី, មេធាវី, សៀវភៅមេរៀន "**សន្តតិកម្ម**" **ឆ្នាំ២០១១**
- អ៊ឹង ភរិយា និង សេក សុវណ្ណា, មេធាវី, សៀវភៅមេរៀន"**អច្ច័យទាន និងភាគបម្រុង**" សិក្ខាសាលាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។
- សៀវភៅមេរៀនក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ៣ : សមិទ្ធផលរបស់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ របស់ក្រសួងយុត្តិធម៌ ឆ្នាំ២០១៧

# ឧបសម្ព័ន្ធ

# គំរូដីកាសម្រេច
# សម្រាប់
# បែងចែកមត៌ក

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

<u>គម្រូដីកាសម្រេចសម្រាប់ករណីសិក្សាទី១</u>

សាលាដំបូងរាជធានីភ្នំពេញ

## <u>ដីកាសម្រេចបែងចែកម៌ក</u>

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ១៥៩ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០១៧
ដីកាសម្រេចលេខ ១២៣ "ង" ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨

-បានឃើញច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី ១៦-០៧-២០១៤

-បានឃើញមាត្រា **២៦**នៃច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

-បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃ**ទី១៥ ខែមករា ឆ្នាំ២០១៨** និងបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃ**ទី០៧ ខែធ្នូ ឆ្នាំ២០១៧** ដោយមានសមាសភាព ៖

## ចៅក្រមជំនុំជម្រះ

លោក J ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជី

លោកស្រី C ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

## អង្គហេតុ និងការអះអាងរបស់ភាគី

**ក.ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារឲ្យតុលាការចេញ**

១. អ្នកដាក់ពាក្យសុំ A ធ្វើលទ្ធកម្មចំណែកអវិភាគ ១ភាគ២នៃអចលនវត្ថុដូចក្នុងបញ្ជីសារពើភ័ណ្ឌ១ និង រថយន្តដូចក្នុងបញ្ជីសារពើភ័ណ្ឌ៣។

២. ភាគីម្ខាងទៀតនៃពាក្យសុំ B ធ្វើលទ្ធកម្មប្រាក់ក្នុងគណនីដូចក្នុងបញ្ជីសារពើភ័ណ្ឌ២។

ទី៣ បង្គាប់ឲ្យអ្នកដាក់ពាក្យសុំ A បង់ប្រាក់ចំនួន 35,000$ ដែលជាប្រាក់សម្រួលនៃលទ្ធកម្មមត៌កខាងលើឲ្យទៅភាគីម្ខាងទៀតនៃពាក្យសុំ B។

**ខ. អង្គហេតុ**

**ខ.១ ការសង្ខេបរឿងក្តី**

កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤

**ខ.២. ការអះអាងរបស់ភាគី**

**-ការអះអាងរបស់អ្នកដាក់ពាក្យសុំ A**

អ្នកដាក់ពាក្យសុំបាន

**-ការអះអាងរបស់ភាគីម្ខាងទៀតនៃពាក្យសុំ B**

ភាគីម្ខាងទៀតនៃពាក្យសុំបានអះអាងថា

## សំអាងហេតុ

**ក. ស្ដីពីចំណុចទាមទារទី១**

**ក.១. អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់**

-ករណីរឿងក្ដីនេះ

-

**ក.២. ការវិនិច្ឆ័យអំពីចំណុចទាមទារ**

-ករណីនេះ

-

**ខ. ស្ដីពីចំណុចទាមទារទី២**

**ខ.១. អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់**

-ករណីនេះ

-

**ខ.២.ការវិនិច្ឆ័យអំពីចំណុចទាមទារ**

-ករណីនេះ

-

**គ. ស្ដីពីចំណុចទាមទារទី៣**

**គ.១. អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់**

២ (ពីរ) សប្ដាហ៍មុន

**គ.២.ការវិនិច្ឆ័យអំពីចំណុចទាមទារ**

សាក្សី B បានអះអាងថា

**ឃ.សេចក្ដីសន្និដ្ឋាន**

-

-

ជាសរុប តុលាការនឹងសម្រេចរឿងក្ដីនេះ ដូចខាងក្រោម ៖

## សេចក្តីសម្រេចបញ្ចប់

១.អ្នកដាក់ពាក្យសុំធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ។

២.ភាគីម្ខាងទៀត......ធ្វើលទ្ធកម្មនូវប្រាក់បញ្ញើដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ២ស្តីពីមត៌កនិងសាច់ប្រាក់ដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ៣ស្តីពីមត៌ក ដែលបានភ្ជាប់ជាមួយនេះ ។

ដីកាសម្រេចនេះប្រកាសជាសាធារណៈនៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨ ចំពោះមុខភាគី និងអ្នកតំណាងដោយអាណត្តិរបស់ភាគី។ ទុកសិទ្ធិឲ្យភាគីប្តឹងជំទាស់ក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតដីកាសម្រេចនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨

**ចៅក្រម**

# ដីកា

# សម្រេច

# បែងចែកមត៌ក

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

## ដីកាសម្រេចរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

យើង ........................ចៅក្រម នៃសាលាដំបូងរាជធានីភ្នំពេញ

**លេខ ..... "ណ" ភ.ព.មិ**

**ចុះថ្ងៃទី ..-..-២០១៥**

-បានឃើញមាត្រា **៣** , **២២** និងមាត្រា **៣៥** នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

-បានឃើញមាត្រា **១១៦១** , **១១៦២** , **១២៤៨** និងមាត្រា **១៣០៤** នៃក្រមរដ្ឋប្បវេណី ។

-បានឃើញប្រការ ៤០ នៃប្រកាសអន្តរក្រសួង ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណីលេខ **៥៩ ប្រក.ជនស / ១១** ចុះថ្ងៃទី .................................... រវាងក្រសួងយុត្តិធម៌ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

-បានឃើញសំណុំរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ......... ចុះថ្ងៃទី ........................ របស់សាលាដំបូងរាជធានីភ្នំពេញ ។

រវាងអ្នកដាក់ពាក្យសុំឈ្មោះ ....................... ភេទ........... អាយុ ......ឆ្នាំ ជាតិខ្មែរ របរ...... អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ.......ផ្លូវ...... ក្រុមទី..... ភូមិ...... សង្កាត់.............. ខណ្ឌ................. រាជធានីភ្នំពេញ ។

លោកស្រី ...............ជាមេធាវីតំណាងដោយអាណត្តិឲ្យអ្នកដាក់ពាក្យសុំឈ្មោះ .................. ការិយាល័យមេធាវី ............ ស្នាក់ការបច្ចុប្បន្ន ផ្ទះលេខ....... ផ្លូវលេខ....... សង្កាត់........ ខណ្ឌ........ រាជធានីភ្នំពេញ ។

លោក .............. ជាមេធាវីតំណាងដោយអាណត្តិឲ្យអ្នកដាក់ពាក្យសុំឈ្មោះ .................. ការិយាល័យមេធាវី ស្នាក់ការបច្ចុប្បន្ន ផ្ទះលេខ............ សង្កាត់............ ខណ្ឌ.......... រាជធានីភ្នំពេញ ។

និង ភាគីម្ខាងទៀតឈ្មោះ ................ ភេទ........ អាយុ ........ ជាតិខ្មែរ និងឈ្មោះ ............ ភេទ..... អាយុ ........ ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ....... ផ្លូវ......... ក្រុមទី.... ភូមិ....... សង្កាត់.... ខណ្ឌ....... រាជធានីភ្នំពេញ ។

លោក/កញ្ញា .............. ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីម្ខាងទៀតឈ្មោះ ........... ការិយាល័យ ........... ស្នាក់ការបច្ចុប្បន្ន ផ្ទះលេខ....... ផ្លូវលេខ......... សង្កាត់....... ខណ្ឌ....... រាជធានីភ្នំពេញ ។

លោក/កញ្ញា ........... ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីម្ខាងទៀតឈ្មោះ .......... ការិយាល័យច្បាប់កម្ពុជា ស្នាក់ការបច្ចុប្បន្ន ផ្ទះលេខ.......ផ្លូវលេខ............ សង្កាត់.......... ខណ្ឌ....... រាជធានីភ្នំពេញ ។

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេចបែងចែកចំណែកមត៌ក ផ្ទះលេខ......... ផ្លូវ...... ក្រុមទី........ ភូមិ....... សង្កាត់........ ខណ្ឌ........ រាជធានីភ្នំពេញ ពីមតកជនឈ្មោះ .............។

-បានឃើញពាក្យសុំ ចុះថ្ងៃទី ............. របស់ឈ្មោះ ................. ។

-បានឃើញសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី ..................... របស់លោក/លោកស្រី ........... ជាមេធាវីតំណាងដោយអាណត្តិឲ្យអ្នកដាក់ពាក្យសុំឈ្មោះ ..................... ។

-បានឃើញកំណត់ហេតុសាកសួរភាគី ចុះថ្ងៃទី ................. របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញកំណត់ហេតុសាកសួរភាគី ចុះថ្ងៃទី ................. របស់សាលាដំបូងរាជធានីភ្នំពេញ ។

-ក្រោយពីបានពិនិត្យភស្តុតាងរបស់គូភាគី ។

-ក្រោយពីបានពិនិត្យសំណុំរឿង និង ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

**<u>សាលាដំបូងរាជធានីភ្នំពេញ</u>**

**<u>សំអាងហេតុ</u>**

-តាមការអះអាងរបស់លោក/លោកស្រី......... ជាមេធាវីតំណាងដោយអាណត្តិឲ្យអ្នកដាក់ពាក្យសុំឈ្មោះ ............. ថា ខ្លួនសុំកែតម្រូវកម្មវត្ថុក្នុងពាក្យសុំចេញដីកាសម្រេច ចុះថ្ងៃទី ................ របស់កូនក្តីខ្លួន ដោយស្នើសុំឲ្យតុលាការបែងចែកចំណែកមត៌កពីសពមតកជនឈ្មោះ ....................... ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ............ ផ្លូវ ........... ក្រុមទី........ ភូមិ............ សង្កាត់.............. ខណ្ឌ.......... រាជធានីភ្នំពេញ និង សុំបដិសេធសេចក្តីថ្លែងការណ៍របស់ភាគីម្ខាងទៀត ចុះថ្ងៃទី .................. ដោយហេតុថា កូនក្តីខ្លួនឈ្មោះ ............ បានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវជាមួយឈ្មោះ ........... នៅថ្ងៃទី ............. ហើយក្នុងការរួមរស់ជាមួយគ្នា កូនក្តីខ្លួនមានកូនប្រុសម្នាក់ឈ្មោះ ................ លុះដល់ថ្ងៃទី ................ ប្តីរបស់កូនក្តីខ្លួនក៏បានទទួលមរណភាព ។ ខ្លួនសូមឲ្យតុលាការពិនិត្យភស្តុតាងដូចដែលខ្លួនបានដាក់ជូនក្នុងសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី .................. និងសូមបដិសេធចោលនូវការទាមទាររបស់ភាគីម្ខាងទៀត ក្នុងការស្នើសុំបែងចែកមត៌កដែលជាចំណែកពាក់កណ្តាល នៃទ្រព្យសម្បត្តិរួមរបស់មតកជនឈ្មោះ ............ ឲ្យឈ្មោះ ................ ដោយហេតុថា ឈ្មោះ ................ បានទទួលមរណភាពតាំងពីឆ្នាំ........... រហូតដល់ឆ្នាំ.................ទើបបានលក់ ដី- ផ្ទះលេខ............... ផ្លូវលេខ...........សង្កាត់............ ខណ្ឌ......... រាជធានីភ្នំពេញ ទៅទិញ ដី - ផ្ទះលេខ............... ផ្លូវ......... ក្រុមទី.....ភូមិ........... សង្កាត់...... ខណ្ឌ............ រាជធានីភ្នំពេញ គឺមានរយៈពេល .....ឆ្នាំ កន្លងមកហើយ ។ ដូច្នេះ ផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិឲ្យធ្វើបដិទានសន្តតិកម្ម ក្នុងករណីដែលមត៌កត្រូវបានផ្ទេរទៅឲ្យភាគីម្ខាងទៀត មានអំឡុងពេល **៥**ឆ្នាំ គិតចាប់ពីពេលនោះ ឬ ក្នុងករណីជនណាម្នាក់ដែលទទួលសន្តតិកម្មក្នុងនាមជាសន្តតិជន មានអំឡុងពេល **៥**ឆ្នាំ គិតចាប់ពីថ្ងៃមតកជននោះបានទទួលមរណភាព តាមមាត្រា **១៣០៤** នៃក្រមរដ្ឋប្បវេណី ។ ម៉្យាងទៀត ឈ្មោះ ............ ពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ជាមួយឈ្មោះ ................ ឡើយ ។ ហេតុនេះ ខ្លួនសុំឲ្យតុលាការបែងចែកមត៌កជា ........ចំណែក ស្មើគ្នា តាមផ្លូវច្បាប់ ហើយក្នុងអំឡុងពេលឈ្មោះ ............. រស់នៅជាមួយកូនក្តីខ្លួន នៅផ្ទះលេខ...... ផ្លូវ.......... ក្រុមទី..... ភូមិ....... សង្កាត់............. ខណ្ឌ........ រាជធានីភ្នំពេញ ភាគីម្ខាងទៀតឈ្មោះ ......... មិនបានរស់នៅជាមួយកូនក្តីខ្លួន និង មតកជនឈ្មោះ ............ ទេ ពីព្រោះថា ភាគីទាំងពីរបានរៀបការ និង ចាកចេញពីលំនៅឋាន ដោយទទួលបានចំណែកមត៌ករួចរាល់អស់ហើយ ។

-តាមការអះអាងតបរបស់កញ្ញា ................ និងលោក ........... ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីម្ខាងទៀតឈ្មោះ ................... និងឈ្មោះ ........... ថា កូនក្តីខ្លួនទទួលស្គាល់ការទាមទារសុំបែងចែកមត៌កតាមច្បាប់ ដោយក្នុងអំឡុងឆ្នាំ.................. ម្តាយរបស់កូនក្តីខ្លួនឈ្មោះ ......... បានទទួលមរណភាព ដោយបន្សល់ទុកអចលនវត្ថុ ដី - ផ្ទះ ចំនួន ...... កន្លែង ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ............... ផ្លូវលេខ............ សង្កាត់........... ខណ្ឌ......... រាជធានីភ្នំពេញ ជាទ្រព្យសម្បត្តិរួមរបស់ឪពុកម្តាយកូនក្តីខ្លួន ។ នៅឆ្នាំ....... ឪពុករបស់កូនក្តីខ្លួន និង កូនក្តីខ្លួនបានព្រម

ព្រៀងគ្នាលក់ ដី - ផ្ទះ នោះ ដើម្បីផ្លាស់ប្តូរទីលំនៅ ដោយយកប្រាក់ពីការលក់ ដី - ផ្ទះ ទៅទិញ ដី - ផ្ទះ ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ........ ផ្លូវ....... ក្រុមទី..... ភូមិ...... សង្កាត់...... ខណ្ឌ...... រាជធានីភ្នំពេញ និង រស់នៅទីនោះរហូតដល់សព្វថ្ងៃនេះ ។ លុះនៅឆ្នាំ....... ទើបឪពុករបស់កូនក្តីខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ........... និង មានកូនប្រុសម្នាក់ឈ្មោះ ................ ។ ការជាពិតណាស់ដែលចំណែកមត៌កចំនួនពាក់កណ្តាលរបស់ឪពុកឈ្មោះ ........... ត្រូវយកមកធ្វើការបែកចែកឲ្យសហសន្តតិជនទាំង ......នាក់ ប៉ុន្តែ ត្រូវធ្វើការបែងចែកចំណែកមត៌កចំនួនពាក់កណ្តាលរបស់ម្តាយឈ្មោះ ........ ជាមុនសិន តាមមាត្រា **១១៤៧** នៃក្រមរដ្ឋប្បវេណី ដែលមត៌កត្រូវតែជាចំណែកទ្រព្យសម្បត្តិផ្ទាល់របស់មតកជន ហើយសហសន្តតិជននឹងក្លាយជាម្ចាស់កម្មសិទ្ធិអវិភាគនៅលើចំណែកមត៌ក តាមមាត្រា **១១៤៨** នៃក្រមរដ្ឋប្បវេណី ដែលបញ្ជាក់ថា កូនក្តីខ្លួនជាម្ចាស់កម្មសិទ្ធិករអវិភាគទៅលើចំណែកពាក់កណ្តាលនៃមត៌ករបស់ម្តាយ ។ ចំពោះការលើកឡើងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឲ្យធ្វើបដិទានសន្តតិកម្ម គឺមិនត្រឹមត្រូវទៅតាមស្ថានភាពនៃការទាមទាររបស់កូនក្តីខ្លួនឡើយ ពីព្រោះជាសន្តតិកម្មតាមច្បាប់ ដែលមិនបានកំណត់អំពីអាជ្ញាយុកាលនៃការទាមទារ ហើយសន្តតិកម្មតាមច្បាប់ ចាប់ផ្តើមអនុវត្តនៅពេលណាដែលមានការទាមទារឲ្យបែងចែកចំណែកមត៌កនោះកើតឡើងតែប៉ុណ្ណោះ ។ កូនក្តីខ្លួន ក៏ដូចជាឪពុក ពុំដែលធ្វើការទាមទារបែងចែកមត៌ករបស់ម្តាយ និង ប្រពន្ធនោះឡើយ គឺបន្តរក្សាស្ថានភាពនៃមត៌កនោះដដែល ក្នុងនាមជាកម្មសិទ្ធិករអវិភាគ រហូតដល់មានការលក់ទិញ ដី - ផ្ទះ ថ្មី ។ ហេតុនេះ ដាច់ខាតទាល់តែមានការយល់ព្រមពីកូនក្តីខ្លួន ទើបអាជ្ញាធរអនុញ្ញាត និង យល់ព្រមឲ្យមានការផ្ទេរកម្មសិទ្ធិ ។ ចំពោះការធ្វើបដិទានសន្តតិកម្ម គឺធ្វើឡើងតែក្នុងករណីដែលសន្តតិជនត្រូវបានដកហូតសិទ្ធិសន្តតិកម្មក្នុងការទទួលមត៌កតែប៉ុណ្ណោះ តាមមាត្រា **១៣០១** នៃក្រមរដ្ឋប្បវេណី ។ ចំពោះអាជ្ញាយុកាល **៥ឆ្នាំ**នេះ មិនអាចអនុវត្តលើសន្តតិកម្មតាមច្បាប់ ដែលពុំទាន់មានការទាមទារឲ្យបែងចែកឡើយ ឯការលើកឡើងថា បានធ្វើការបែងចែកចំណែកមត៌ករួចរាល់អស់ហើយនោះ គឺជាការមិនត្រឹមត្រូវទេ ពីព្រោះទ្រព្យសម្បត្តិដែលបានមកពីការលក់ ដី - ផ្ទះ ចាស់ បានយកទៅទិញ ដី - ផ្ទះ ថ្មី ព្រមទាំងធ្វើការជួសជុល និងបង្កើតនូវមុខរបរថ្មីអស់ទៅហើយ គ្មានសេសសល់ចំណែកណាមួយ ដើម្បីយកមកធ្វើការបែងចែកនោះទេ ។ ខ្លួនសូមដាក់ជូនតុលាការនូវភស្តុតាង ដើម្បីបញ្ជាក់អំពីសិទ្ធិក្នុងការទាមទាររបស់កូនក្តីខ្លួន ដែលមានដូចជា សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ ......... ចុះថ្ងៃទី .............. របស់ឈ្មោះ .........., សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ ............ ចុះថ្ងៃទី ...........របស់ឈ្មោះ ................, លិខិតលក់ផ្ទះ ចុះថ្ងៃទី .................., លិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី .............., លិខិតស្នើសុំទិញ ចុះថ្ងៃទី .........................., លិខិតធានាអះអាង ចុះថ្ងៃទី .......................... និងសំណូមពរសុំឲ្យតុលាការចេញដីកាសម្រេចដូចខាងក្រោម ៖

**១**. បែងចែកចំណែកមត៌កចំនួនពាក់កណ្តាល នៃទ្រព្យសម្បត្តិរួមរបស់មតកជនឈ្មោះ ................ មកឲ្យឈ្មោះ .......... និងឈ្មោះ ................. តាមច្បាប់ ។

**២**. បែងចែកចំណែកមត៌កចំនួនពាក់កណ្តាលទៀត នៃទ្រព្យសម្បត្តិរួមរបស់មតកជនឈ្មោះ ................ មកឲ្យឈ្មោះ ............... , ............. , ............ និងឈ្មោះ ................ តាមច្បាប់ ។

**៣**. អនុញ្ញាតឲ្យអង្គភាពសុរិយោដី និង អង្គភាពពាក់ព័ន្ធ ចុះបញ្ជីផ្ទេរសិទ្ធិកម្មសិទ្ធិករពីឈ្មោះ ............... មកឲ្យសហសន្តតិជន ដូចខាងលើ ។

-តាមសេចក្តីចម្លងសំបុត្រមរណភាពលេខ ................. សៀវភៅមរណភាពលេខ ................ ចុះថ្ងៃទី .................. របស់មន្ត្រីអត្រានុកូលដ្ឋាន សង្កាត់................. ខណ្ឌ............. រាជធានីភ្នំពេញ បានបញ្ជាក់ថា ឈ្មោះ ............... ភេទ........... ថ្ងៃខែឆ្នាំកំណើត .................... បានទទួលមរណភាព កាលពីថ្ងៃទី .................. ដោយស្ថានភាពសព គឺមានប្រពន្ធ ។

-តាមសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍លេខ ......... សៀវភៅអាពាហ៍ពិពាហ៍លេខ ............... ចុះថ្ងៃទី ................ របស់មន្ត្រីអត្រានុកូលដ្ឋាន ឃុំ...... ស្រុក....... ខេត្ត....... បានបញ្ជាក់ថា ឈ្មោះ ................. និងឈ្មោះ ................... គឺជាសហព័ទ្ធនឹងគ្នា ពិតប្រាកដមែន ។

-តាមសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ ............. ចុះថ្ងៃទី .............. សៀវភៅបញ្ជាក់កំណើតលេខ .............. ចុះថ្ងៃទី ................ របស់មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ខណ្ឌ............ រាជធានីភ្នំពេញ បានបញ្ជាក់ថា ឈ្មោះ ............. ភេទប្រុស កើតថ្ងៃទី ................ មានឪពុកឈ្មោះ ................. និង ម្តាយឈ្មោះ .................. ។

-តាមសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ .............. ចុះថ្ងៃទី ........... សៀវភៅបញ្ជាក់កំណើតលេខ ..................... ចុះថ្ងៃទី .................. របស់មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ខណ្ឌ.............. រាជធានីភ្នំពេញ បានបញ្ជាក់ថា ឈ្មោះ ................ ភេទ............. កើតថ្ងៃទី ................ មានឪពុកឈ្មោះ ................. និង ម្តាយឈ្មោះ ................. ។

-តាមសេចក្តីចម្លងសំបុត្រកំណើតលេខ ................ ចុះថ្ងៃទី ................. សៀវភៅកំណើតលេខ .................ចុះថ្ងៃទី ......................... របស់មន្ត្រីអត្រានុកូលដ្ឋាន សង្កាត់................ ខណ្ឌ.............. រាជធានីភ្នំពេញ បានបញ្ជាក់ថា ឈ្មោះ ................. ភេទ........... កើតថ្ងៃទី ................... មានឪពុកឈ្មោះ ............... និង ម្តាយឈ្មោះ .............. ។

-តាមបង្កាន់ដៃទទួលប័ណ្ណកម្មសិទ្ធិ និង ទទួលប្រាក់ ចុះថ្ងៃទី ............... បានបញ្ជាក់ថា លិខិតផ្ទេរសិទ្ធិលេខ .......................... លើអចលនវត្ថុ ដែលមានទីតាំងស្ថិតនៅផ្ទះលេខ............... ផ្លូវ............. ក្រុមទី................. ភូមិ............ សង្កាត់................ ខណ្ឌ............... រាជធានីភ្នំពេញ គឺជាកម្មសិទ្ធិរបស់ឈ្មោះ ..........។

-តាមការអះអាងរបស់លោកស្រី .............. ជាមេធាវីតំណាងដោយអាណត្តិឲ្យអ្នកដាក់ពាក្យសុំឈ្មោះ ............ , ការអះអាងតបរបស់កញ្ញា ............... និងលោក ............... ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីម្ខាងទៀត ឈ្មោះ ....................... និង ការពិនិត្យភស្តុតាងរបស់គូភាគីក្នុងនីតិវិធីសាកសួរភាគីរួចមកឃើញថា ឈ្មោះ ............... និង អ្នកដាក់ពាក្យសុំឈ្មោះ .................. គឺជាសហព័ទ្ធនឹងគ្នា ហើយនៅក្នុងចំណងអាពាហ៍ពិពាហ៍នេះ សហព័ទ្ធមានកូនប្រុសម្នាក់ឈ្មោះ .............. ។ នៅថ្ងៃទី .......... ឈ្មោះ ......... ក៏បានទទួលមរណភាពទៅ ដោយបន្សល់ទុកនូវមត៌កជាអចលនវត្ថុ ចំនួន ....កន្លែង ដែលមានទីតាំងស្ថិតនៅផ្ទះលេខ....... ផ្លូវ......... ក្រុមទី..... ភូមិ....... សង្កាត់..... ខណ្ឌ....... រាជធានីភ្នំពេញ ហើយមតកជនឈ្មោះ .......មានកូនប្រុស ....នាក់ ទៀត ...... និងឈ្មោះ ........... ។ ហេតុនេះ តុលាការគប្បីទទួលស្គាល់ការទាមទាររបស់លោកស្រី ......... ក្នុងការស្នើសុំឲ្យតុលាការចេញដីកាសម្រេចបែងចែកមត៌កតាមច្បាប់ ពីព្រោះអ្នកដាក់ពាក្យសុំឈ្មោះ ........... ដែលជាសហព័ទ្ធរបស់មតកជនឈ្មោះ ........... ត្រូវក្លាយជាសន្តតិជនជានិច្ច តាមមាត្រា **១១៦១** នៃក្រមរដ្ឋប្បវេណី ហើយឈ្មោះ ........ និងឈ្មោះ ....... ដែលត្រូវជាបច្ឆាញាតិផ្ទាល់របស់មតក

ជនឈ្មោះ ......... ត្រូវក្លាយជាសន្តតិជន ដែលមានលំដាប់ស្មើគ្នានឹងឈ្មោះ ......... តាមមាត្រា **១១៦២** កថាខណ្ឌ "**ក**" នៃក្រមរដ្ឋប្បវេណី និង ច្រានចោលការទាមទាររបស់កញ្ញា ......... និងលោក ........ ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីម្ខាងទៀតឈ្មោះ ............ ក្នុងការស្នើសុំបែងចែកមត៌កដែលជាចំណែកពាក់កណ្ដាល នៃទ្រព្យសម្បត្តិរួមរបស់មតកជនឈ្មោះ ......... មកឲ្យឈ្មោះ ....... និងឈ្មោះ ......... និងសុំបែងចែកមត៌កដែលជាចំណែកពាក់កណ្ដាលទៀត នៃទ្រព្យសម្បត្តិរួមរបស់មតកជនឈ្មោះ ....... មកឲ្យឈ្មោះ ........ និងឈ្មោះ ........ ដោយហេតុថា ឈ្មោះ ......... ដែលត្រូវជាម្ដាយរបស់ភាគីម្ខាងទៀតឈ្មោះ ............ និងមតកជនឈ្មោះ.......... ពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាទេ ហើយក៏គ្មានភស្តុតាងណាមួយបញ្ជាក់ថា ដី-ផ្ទះចាស់លេខ........ ផ្លូវលេខ....... ភូមិ....... សង្កាត់....... ខណ្ឌ........ រាជធានីភ្នំពេញ គឺជាទ្រព្យសម្បត្តិរួមរបស់ឈ្មោះ ........ និង មតកជនឈ្មោះ ........... នោះទេ ។ ម៉្យាងវិញទៀត ក្រោយពេលដែលឈ្មោះ .......... បានទទួលមរណភាពទៅក្នុងអំឡុងឆ្នាំ........មត៌កបានធ្លាក់នៅក្រោមការកាន់កាប់របស់ឈ្មោះ ....... រហូតឈ្មោះ ............បានលក់ដី-ផ្ទះចាស់លេខ.......... ផ្លូវលេខ......... ភូមិ....... សង្កាត់....... ខណ្ឌ......... រាជធានីភ្នំពេញ ទៅទិញដី-ផ្ទះថ្មី............ ផ្លូវ......... ក្រុមទី...... ភូមិ......... សង្កាត់........ខណ្ឌ........ រាជធានីភ្នំពេញ ក៏ភាគីម្ខាងទៀតឈ្មោះ .......... និងឈ្មោះ .......... ដែលត្រូវជាកូនរបស់ឈ្មោះ ........... ពុំបានដាក់ពាក្យសុំមកតុលាការ ដើម្បីបែងចែកមត៌កពីឈ្មោះ .......... នោះទេ ដែលអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឲ្យធ្វើបដិទានសន្តតិកម្ម នៅក្នុងករណីមត៌កត្រូវបានផ្ទេរទៅភាគីម្ខាងទៀត នៃការទាមទារឲ្យធ្វើបដិសន្តតិកម្ម តាមការបែងចែកមត៌ក មានអំឡុងពេល **៥** ( **ប្រាំ** ) **ឆ្នាំ** គិតចាប់ពីពេលនោះ តាមមាត្រា **១៣០៤** នៃក្រមរដ្ឋប្បវេណី ហើយសន្តតិជនត្រូវធ្វើការយល់ព្រម ឬ បោះបង់សន្តតិកម្មទាំងស្រុង ឬ ដោយកម្រិត នៅក្នុងអំឡុងពេល **៣** ( **បី** ) **ខែ** គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្ដើម តាមមាត្រា **១២៤៨** នៃក្រមរដ្ឋប្បវេណី និង បន្តរហូតមកដល់ពេលមតកជនឈ្មោះ ............. បានទទួលមរណភាព នៅថ្ងៃទី ..........ទៀត ក៏ភាគីម្ខាងទៀតឈ្មោះ ......... និងឈ្មោះ .......... ពុំបានដាក់ពាក្យសុំបែងចែកមត៌ក ឬ ពាក្យសុំពន្យារពេលបែងចែកមត៌កពីមតកជនឈ្មោះ ........ មកកាន់តុលាការដែរ ។

-ចំពោះការទាមទាររបស់កញ្ញា ....... និងលោក ............ ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីម្ខាងទៀតឈ្មោះ .......... និងឈ្មោះ ........ ត្រង់ចំណុចទី**៣** ក្នុងការសុំអនុញ្ញាតឲ្យអង្គភាពសុរិយោដី និង អង្គភាពពាក់ព័ន្ធ ចុះបញ្ជីផ្ទេរសិទ្ធិកម្មសិទ្ធិករពីឈ្មោះ ........... មកឲ្យសហសន្តតិជន តុលាការគប្បីទទួលស្គាល់ តាមប្រការ **៤០** នៃប្រកាសអន្តរក្រសួងលេខ **៥៩ ប្រក.ជនស** / **១១** ចុះថ្ងៃទី **៣០-០៥-២០១១** រវាងក្រសួងយុត្តិធម៌ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី ។

-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ តាមមាត្រា **២២** នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ។

**<u>សាលាដំបូងរាជធានីភ្នំពេញ</u>**

**<u>សម្រេចសេចក្តីបញ្ចប់</u>**

**១**/. ទទួលស្គាល់ការទាមទាររបស់លោកស្រី ......... ជាមេធាវីតំណាងដោយអាណត្តិឲ្យអ្នកដាក់ពាក្យសុំឈ្មោះ .......... ក្នុងការស្នើសុំឲ្យតុលាការបែងចែកមត៌ក ។

២/. បែងចែកមត៌ករបស់មតកជនឈ្មោះ ......... ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ........ ផ្លូវ....... ក្រុមទី.... ភូមិ....... សង្កាត់....... ខណ្ឌ...... រាជធានីភ្នំពេញ ជា ........ ចំណែក ស្មើគ្នា រវាងសន្តតិជនឈ្មោះ .........។

៣/. អនុញ្ញាតឲ្យអង្គភាពសុរិយោដី ចុះបញ្ជីផ្លាស់ប្តូរសិទ្ធិកម្មសិទ្ធិករលើអចលនវត្ថុ ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ........ ផ្លូវ...... ក្រុមទី...... ភូមិ.......... សង្កាត់........ ខណ្ឌ...... រាជធានីភ្នំពេញ ពីឈ្មោះ ......... ឲ្យមកឈ្មោះ .... ។

៤/. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំឈ្មោះ ........... ។

- ទុកសិទ្ធិឲ្យគូភាគីប្តឹងជំទាស់ក្នុងអំឡុងពេល ......**សប្តាហ៍** គិតចាប់ពីថ្ងៃ ដែលបានទទួលការជូនដំណឹងអំពីដីកាសម្រេចនេះ ៕

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និង ត្រា : ............**

---

" បានចម្លងត្រឹមត្រូវតាមច្បាប់ដើម "

រាជធានីភ្នំពេញ, ថ្ងៃទី .......ខែ ...... ឆ្នាំ .......

បានឃើញ **ក្រឡាបញ្ជី**

**ចៅក្រម**